# ១- រឿងបុរសកាប់អុស

## និទានដោយលោក អ៊ឹម ឈាង [1]



[1] ភូមិសំរោងស្នោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង

ការដែលគេប្រដៅណែនាំពីរឿងសាសនាហ្នឹងគឺមានច្រើន វាមានហេតុជារឿងព្រេងរបស់វាដែរ ដូចជារឿងមួយដែលគេនិទានថា គ្រានោះមានប្ដីប្រពន្ធកម្សត់ទុរគតដែលគេទាំងពីររកស៊ីតែមុខរបរកាប់អុសទេ។ ពេលពួកគេទៅក្នុងព្រៃកាប់អុសអញ្ចឹងទៅ ស្រាប់តែនៅថ្ងៃមួយនោះពួកគាត់ក៏បានប្រទះឃើញរូបសំណាកព្រះមួយអង្គដែលសាងឡើងពីស៊ីម៉ង់ ហើយបាក់ព្រះហស្ដម្ខាង ពួកគាត់យកមកជួសជុលតព្រះហស្ដម្ខាងនោះវិញ។ ពេលតរួចរាល់ហើយ ពួកគាត់ក៏រៀបចំដាក់លើអសនៈថ្វាយបង្គំជារៀងរាល់ថ្ងៃ គឺមុនពេលដែលគាត់ចេញទៅកាប់អុស។ ការថ្វាយបង្គំរបស់គាត់ហ្នឹងគឺក្នុងគោលបំណងចង់ទៅឋានសួរនិព្វាន។

និយាយពីសេដ្ឋីម្នាក់ដែលជាមនុស្សមិនមានជំនឿលើបាបបុណ្យអីទេ។ គាត់មិនសូវធ្វើបុណ្យទានអីឡើយ។ មុនពេលស្លាប់ គាត់បានប្រាប់កូនចៅថា៖ "បើអញស្លាប់ទៅប្រាកដជាទៅកើតនៅឋានសួគ៌ហើយ មិនដែលនៅទីទាបទេ មិនបាច់ធ្វើបុណ្យអីក៏បានដែរ ព្រោះអញជាសេដ្ឋី។"

មិនយូរប៉ុន្មានគាត់ក៏ទទួលមរណៈភាពទៅមែន។ ចំណែកឯកូនវិញ ក៏ដើរសួររកនរណាដែលធ្លាប់ទៅឋានសួគ៌ ដើម្បីផ្ដាំឲ្យគេសួររកឪពុកឲ្យខ្លួនផង។ ពេលគេសួរទៅ ក៏ទៅជួបនឹងប្រពន្ធបុរសកាប់អុស ហើយនាងនោះប្រាប់ថា៖ "ប្ដីខ្ញុំធ្លាប់ទៅឋានសួគ៌។"

ប្ដីខ្លួនជាអ្នកកាប់អុស តាមពិតកុហកគេសោះ។ លុះមកដល់ផ្ទះវិញ ប្រាប់រឿងនោះដល់ប្ដីថា៖ "ធ្វើម៉េចបើអូនកុហកគេថាបងឯងធ្លាប់ទៅឋានសួគ៌ទៅហើយ គេប្រាប់ថា នៅពេលបងត្រឡប់មកវិញ គេឲ្យបងទៅជួបគេ។"

ប្ដីឆ្លើយថា៖ "បងមិនដែលទៅឋានសួគ៌ទេ!"

ប្រពន្ធឆ្លើយថា៖ "ចុះបើខ្ញុំប្រាប់គេជ្រុលទៅហើយ ដូច្នេះកុហកទាំងអស់គ្នាទៅ បើអញ្ចឹងប្រាប់គេទៅថាបងទៅ!"

ក្រោយមក គេហៅបុរសនោះទៅជួបហើយសួរថា៖ "អ្នកឯងធ្លាប់បានទៅឋានសួគ៌មែនទេ?"

គាត់ឆ្លើយថា៖ "ទៅមែន"

កូនចៅសេដ្ឋីប្រាប់វិញ៖ "បើអញ្ចឹង ពេលទៅលើកក្រោយសូមសួររកឪពុកខ្ញុំផង ឪពុកឈ្មោះនេះ សេដ្ឋីនេះ សួររកសេដ្ឋីហ្នឹងទៅ។"

បុរសតបថា៖ "ទៅឋានសួគ៌ ផ្លូវឆ្ងាយណាស់ មិនងាយទៅដល់ទេ តោងតែរកលុយកាក់ទិញម្ហូបអាហារស្បៀង ម្ហូបក្រៀមក្រោះទុកតាមផ្លូវ ទំរាំទៅដល់។"

កូនសេដ្ឋី៖ "ចុះឯងយកប៉ុន្មាន?"

ប្រហែលជារាប់ពាន់កហាបណៈ រាប់ពាន់តម្លឹងអីអញ្ចឹងទៅ។ តែក្នុងចិត្តនឹកឃើញថា៖ "អញមុខតែស្លាប់ហើយ ដោយសារតែបោកសេដ្ឋីហ្នឹង។"

ដល់ដឹងខ្លួនថាអញ្ចឹងក៏ទៅប្រាប់ប្រពន្ធថា៖ "យើងទាំងពីរនាក់បែកគ្នាហើយ បងត្រូវទៅស្លាប់ទៅដេកស្លាប់នៅក្នុងព្រៃស្មសាន ដើម្បីកុំឲ្យជួបគេ បើជួបគេ គេប្រាកដជាសម្លាប់យើង ព្រោះយើងកុហកសេដ្ឋីហ្នឹង។"

ឮដូច្នេះ ប្រពន្ធក៏យំតាមដំណើរហ្នឹងទៅហើយស្រណោះថា៖ "បែកគ្នាយ៉ាងម៉េចបងអើយ!"

ប្តីថា៖ "បងសុំយកបាយតែមួយកញ្ចប់ទៅជាមួយទេ!"

ប្រពន្ធក៏រៀបចំបាយមួយកញ្ចប់ឲ្យទៅ។ ដល់អញ្ចឹងក៏ទៅបន់ព្រះដែលប្តីបានតព្រះហស្ដថាអញ្ចេះមួយៗ

អញ្ជឹងទៅ។ បន្ទាប់មកក៏អស់កម្លាំង ហើយណាមួយបាយរួចផងក៏ដេកលក់កន្លែងមុខព្រះហ្នឹងទៅ។

និយាយពីពួកទេវតាគេអាណិតបុរសហ្នឹង ក៏ទៅពន្យល់សប្ដិដល់បុរសនោះថា៖ "អ្នកឯងកុំភ័យអី ចាំយើងជួយ ចូរអ្នកឯងទៅប្រាប់គេថាឥឡូវខ្ញុំដើររកអស់ហើយនៅឋានសួគ៌ហ្នឹងគឺរកមិនឃើញទេ មានតែអ្នកផ្សេង ចំពោះឪពុកអ្នកឯងមិនមាននៅឋានសួគ៌ទេ ប្រាកដជាធ្លាក់នរកហើយ ហើយគាត់បានផ្ដាំមកទៀតថាបើមិនជឿទេ អ្នកឯងទៅគាស់កំណប់មួយពាងនៅក្រោមជណ្ដើរ គឺសេដ្ឋីគាត់ផ្ដាំមកអញ្ជឹង កាលខ្ញុំទៅឋាននរក។"

ប្ដីភ្ញាក់ឡើង ក៏អរកខិបកខុបមកប្រាប់ប្រពន្ធ។ ប្រពន្ធថា៖ "ម៉េច? ម៉េចថាទៅស្លាប់ ម៉េចក៏មកវិញ?"

ប្ដីប្រាប់ពីយល់សប្ដិនោះទៅប្រពន្ធ ហើយយល់ព្រមទៅជួបសេដ្ឋី។

ទៅដល់ សេដ្ឋីសួរថា៖ "យ៉ាងម៉េច ដើររកឪពុកខ្ញុំឃើញទេ?"

បុរសជាប្ដីថា៖ "ខ្ញុំដើររកឃើញហើយ។ តែនៅឋានសួគ៌ហ្នឹង គ្រប់ទីកន្លែង គ្រប់ច្រកល្ហកអស់ហើយ រាប់ជាន់ទាំង១៦ជាន់ហ្នឹងនៅតែរកមិនឃើញទេ។ ស្រាប់តែចុះពីឋានសួគ៌ មកមើលនៅឋាននរក ក៏ឃើញនៅឋាននរក បើមិនជឿទេ សូមធ្វើតាមបណ្ដាំគាត់ទៅ ព្រោះគាត់បានផ្ដាំមកថា ឲ្យយកកំណប់មាសមួយពាងនៅក្រោមជណ្ដើរទៀតផង។"

គេចាប់ចងបុរសហ្នឹង បើសិនជាជីករកមិនឃើញទេ បុរសនោះនឹងត្រូវស្លាប់។ ដល់គាស់ទៅឃើញកំណប់មួយពាងមែន។ បានគេយកកំណប់នោះមកហើយ គេក៏ឲ្យឡើងជាសេដ្ឋី ដោយចែកទ្រព្យពីសេដ្ឋីពាក់កណ្ដាល។

រឿងនេះបង្ហាញថាគាត់ហ្នឹងបានបោកប្រាស់គេតែបានសម្រេចដែរ។ នេះដោយសារប្រពន្ធជ្រុលកុហក

ហើយ ក៏ចេះតែកុហកតាមគ្នាទៀតទៅកុំឲ្យវាខូចមួយៗ បើថាប្រពន្ធកុហកហើយ ខ្លាចគេយកប្រពន្ធទៅសម្លាប់ ក៏សុខចិត្តយកខ្លួនទៅជួសប្រពន្ធវិញ។

# ២- រឿងទន្សាយសាកប៉ោលថ្មី

## និទានដោយលោក អ៊ុំ ឡឿន [2]

*រឿងនេះជារឿងមួយមាននៅក្នុងសាស្ត្រាដែរ។ មានមេខ្លាមួយរស់នៅក្នុងរូងជាមួយកូនពីរក្បាល។ មេខ្លាហ្នឹងមុននឹងចេញទៅរកស៊ី វាផ្ដែផ្ដាំកូនទាំងពីរថា៖ "កូនទាំងពីរនៅចាំម្ដាយក្នុងរូងហ្នឹងហើយ កុំទៅណាមកណាឲ្យសោះណា!"*

*កូនខ្លាក៏យល់ព្រមស្ដាប់តាមបង្គាប់ម្ដាយវា។ លុះដល់ពេលមេខ្លាទៅបាត់ មានទន្សាយកំហូចមួយវាដើរចូលទៅរកកូនខ្លាទាំងពីរ។ ទៅដល់ទន្សាយ វាធ្វើជាសួររកថា៖ "អ្នកម៉ែឯងទៅណាទៅ? ម៉ែឯងផ្ដាំឲ្យអញមកណា ថាបើអញមកឲ្យអញជិះណាស់ ចុះឥលូវទៅណាបាត់ហើយ អញផ្ដាំប្រាប់ម៉ែឯងផងថាអញមករក ហើយឲ្យទៅជួបអញកុំខាន!"*

*ផ្ដាំរួច ទន្សាយហ្នឹងទៅបាត់ទៅ។ ពេលមេខ្លាត្រលប់មក កូនខ្លាក៏ប្រាប់ម៉ែវាតាមដំណើរទន្សាយផ្ដាំ។ ស្ដាប់រួចហើយមេខ្លាខឹងខ្លាំងណាស់ក៏សួរទៅកូនថា៖ "អាសត្វហ្នឹងធំប៉ុនណាទៅបានជាវាហ៊ាននិយាយដូច្នេះ?"*

*កូនខ្លាថា៖ "សត្វហ្នឹងមិនដឹងជាសត្វអ្វីទេ ស្ទឹកត្រចៀកវាវែងៗ!"*

*ព្រហើយ មេខ្លាក៏ប្រាប់កូនទាំងពីរថា៖ "ម៉ែចង់ទៅរកអាហ្នឹងមើល បើជួបហើយ ម៉ែនឹងខ្វះយកថ្វើមវាមកឲ្យពួកកូនធី កូនឯងនៅចាំផ្ទះ កុំដើរទៅណាឲ្យសោះ!"*

---

2 *ភូមិថ្មី ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម*

មេខ្លាក៏ចេញដំណើរទៅៗ ដើរបន្តិចក្រោយមក ក៏ទៅជួបទន្សាយហ្នឹងៗ ទន្សាយក្រឡេកឃើញមេខ្លាភ្លាមស្រែកថា៖ "អ្នកនាងឯង មកហើយអ្នកស អញប្រាប់ឲ្យមកៗមែន!"

ឮទន្សាយនិយាយដូច្នោះ មេខ្លាខឹងណាស់ ក៏ស្ទុះហក់ទៅចាប់ទន្សាយទាំងកំរោលៗ មេខ្លាហក់ទៅហក់មក ឯទន្សាយហ្នឹងក៏លោតផុតប្រឡោះឈើមួយ មេខ្លាហក់ទៅតាមក៏ជាប់នៅនឹងប្រគាបឈើនោះៗ ទន្សាយបានឱកាសក៏លេងប៉ោល ក្រោមកន្ទុយមេខ្លាហ្នឹងមួយផ្អែត រួចក៏គេចខ្លួនបាត់ទៅៗ ចំណែកមេខ្លាវិញ លុះដល់វាស្រកពោះទៅ វាក៏រួចពីប្រគាបឈើហើយខំប្រឹងដើរត្រលប់ទៅរូងវិញៗ

ទៅដល់ កូនខ្លានោះសួរមេខ្លាថា៖ "ម៉ែៗឯណាថ្លើម ឯណាថ្លើមអាកញ្ជើបហ្នឹង?"

មេខ្លាតប៖ "ថ្លើមអីកូនអើយ ម្ដាយខ្ទួចអស់រលីងហើយ នៀក កូនដឹងទេ!" ។

# ៣- រឿងអាដោកអាជាល

## និទានដោយលោកតា អិន អៀន [3]



3 ភូមិសំបូរមាស២ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម

និយាយពីបុរសពីរនាក់បងប្អូន បងឈ្មោះអាជាលនិងអាប្អូនឈ្មោះអាដោក។ ពីរនាក់បងប្អូននេះកំព្រាកំព្រាស្លាប់ឪពុកម្ដាយអស់ហើយ រស់នៅតែជាមួយនឹងជីដូន។ លុះវាធំទៅ វាតែងដើររករបស់របរផ្លែឈើ ផ្លែព្រៃ បរបាញ់សត្វតូចសត្វធំ យកមកចិញ្ចឹមជីដូនវាវិញ។ ថ្ងៃមួយជីដូនរបស់វាក៏ធ្លាក់ខ្លួនឈឺ។ នៅក្នុងព្រៃដាច់ស្រយាលចុងកាត់មាត់ញកនោះ មានយក្សឈ្មោះថាអាចារ្យយក្សពីព្រោះគាត់រក្សាសីលមិនចេះស៊ីមនុស្សទេ ហើយយក្សនេះមានកូនក្រមុំពីរនាក់ទៀតផង។

ពេលយាយវាឈឺដូចនេះ អាដោកសួរបងវាថា៖ "អាបងជាលឯងគិតយ៉ាងម៉េចដែរ បើយាយយើងឈឺគ្រុនអត់បាយអត់ទឹកយ៉ាងនេះ? បើអញ្ចឹងយើងគិតទៅរកអាចារ្យយក្សដើម្បីសុំឲ្យគាត់មកមើលកែកុនយាយយើងឲ្យបានជាសះស្បើយណា។"

ហើយអាជាលថា៖ "អើស្រេចតែឯងទេ ឯងជាប្អូនពូកែជាងអញហើយរហ័សរហួនដៃជើងជាងអញ អញនៅទ្រាំមើលយាយឯហ្នេះចុះ!"

អាដោកជាប្អូនហ្នឹងក៏រត់ទៅដល់ជម្រាបដល់អាចារ្យយក្សនោះថា៖ "យាយខ្ញុំឈឺខ្លាំងណាស់ សូមលោកអាចារ្យយក្ស ឯងអញ្ជើញទៅឥឡូវហ្នឹងជួយមើលយាយខ្ញុំផង។"

អាចារ្យក៏តបថា៖ "អើមិនអីទេ! បើអញ្ចឹងចាំយើងទៅ!"

ហើយកូនក្រមុំយក្សពីរនាក់នោះក៏សុំលោកឪពុកទៅជាមួយដែរ។ អាចារ្យយក្សថា៖ "អើ! បើកូនឯងចង់ទៅក៏ទៅចុះ!"

ទាំងអស់គ្នាក៏នាំគ្នាមកផ្ទះអាជាល ហើយអាចារ្យយក្សហ្នឹងក៏ឡើងទៅមើលយាយទៅ ដល់មើលយាយ

រួច អាជាលថា៖ "អាជោកឯងមើលបាយកកបាយក្ដាំងអីនៅក្នុងឆ្នាំងមើល មានដែរឬទេ? យកមកឲ្យកូនលោកអាចារ្យយក្សទាំងពីរស៊ីចុកបុកទំពារផងមើល អាជោក!"

អាជោកថា៖ "មិនអីទេ បងឯងនៅជាមួយលោកអាចារ្យយក្សចុះ មើលយាយយើងឲ្យជាចាំខ្ញុំនាំកូនអាចារ្យដើរលេងកម្សាន្តទៅតាមរបងផ្ទះយើងខាងក្រៅ។ ចំណែកឯអាចារ្យយក្សឯហ្នេះក៏ទំប្រឹងមើលជីដូននោះជាមួយនឹងអាជាល។

ឯអាជោកនេះក៏នាំកូនក្រមុំដើរលេងតាមរបងសព្វគ្រប់។ រួចបានអាចារ្យយក្សថា៖ "រឿងនេះត្រូវទៅយកក្អមមកដាំទឹកឲ្យគាត់មុជពីព្រោះគាត់រងារញាក់ខ្លាំងណាស់។"

អាជោកឮដូចនេះ ក៏នាំកូនក្រមុំយក្សមកសម្រាកនៅផ្ទះសិន ហើយវាស្ទុះទៅរកក្អម។ វាទិញបានក្អមមួយអំរែករួចចងប្រតែងប្រតោងគ្នា រែកមកយ៉ាងប្រញាប់ប្រញាល់ ដូចនេះអាក្អមទាំងនោះក៏ទង្គិចឈ្លោះគ្នាម៉េងមៅ៉ងៗៗ។ អាជោកឃើញដូចនេះ វាស្រែកដាក់ក្អមថា៖ "អញថាកុំឈ្លោះគ្នាវើយ! តិចអញវាយឯងឥឡូវហ្នឹងណាស់!"

តែក្អមនៅតែទង្គិចគ្នាឮសូរម៉េងម៉ាំងៗដដែល ពេលដែលអាជោកកំពុងរែករត់យ៉ាងលឿន។ អាជោកក៏ស្រែកទៀតថា៖ "អ្ហែអានេះចំមែនតម្រង់វើយ! អញប្រាប់ថាកុំឲ្យឈ្លោះគ្នា អាវែងនេះនៅតែឈ្លោះគ្នា តិចអញវាយឥឡូវហ្នឹងណា អញប្រាប់ហើយនៅតែមិនព្រមស្ដាប់សោះមើល! អញវាយអាហ្នឹងម្ដងមើល!"

ថាហើយ អាជោកខឹងផងព្រោះក្អមនៅតែប៉ះបុកទង្គិចគ្នា ក៏ដាក់ក្អមចុះ ហើយហូតដងរែកចេញមកវាយក្អមនោះប្រាវហើយវាបន្លឺថា៖ "អូ! ស្រេចតែម្ដង ឆាប់អស់រលីង!"

វាយហើយក៏រត់ត្រលប់មកផ្ទះវិញ។ លុះអាដោកមកដល់ផ្ទះ អាជាលជាបងស្រែកថា៖ "ឯណាក្អមដែលអញឲ្យទៅទិញនោះ?"

អាដោកតបថា៖ "ខ្ញុំរែកមកតាមផ្លូវយកវាមក វាចេះតែឈ្លោះគ្នា ខ្ញុំប្រាប់វាហើយតែវានៅតែឈ្លោះទៀត ខ្ញុំខឹងពេកខ្ញុំវាយវាងាប់អស់រលីងហើយ។"

អាជាលថា៖"អើ! បើអញ្ចឹង អាប្អូនឯងនៅមើលយាយជាមួយលោកអាចារ្យម្ដងទៅ ទុកឲ្យអញទៅវិញម្ដង។"

ថាហើយក៏ទៅទិញក្អម។ ដល់ទិញក្អមបានមក វាប្រើប្អូនវាឲ្យទៅដាំទឹកក្ដៅទុកសំរាប់ឲ្យយាយវាមុជ ពីព្រោះលោកអាចារ្យឲ្យដាំឲ្យ ហើយឥឡូវគាត់នាំកូនទៅផ្ទះបាត់ហើយ ប្រហែលជាថ្ងៃរសៀលទើបគាត់ត្រលប់មកវិញ។ ហើយអាជាលជាបងក៏ដើរទៅរកបរបាញ់សត្វនៅក្នុងព្រៃដើម្បីធ្វើជាចំណីអាហារ ទុកឲ្យអាដោកដាំទឹកទុកមុជឲ្យយាយ។

លុះអាដោកដាំទឹកពុះហើយ វាក៏យកទៅចាកលើយាយវាដែលកំពុងតែដណ្ដប់ភួយញ័រញាក់ៗ ចាក់ហើយ យាយនោះក៏ដាច់ខ្យល់ទៅ។ អាដោកខ្សឹបថា៖ "ថាអ្ហីយាយ! ដល់ត្រូវទឹកក្ដៅអញ្ចឹង ដេកសម្ងំឈឹងស្រួលតែម្ដង អើ អាហ្នឹងអញ្ចឹងតើ! បើអញ្ចឹងអញគ្របភួយគ្របអីឲ្យគាត់ស្រួលបួលសិន។"

ដល់ពេលថ្ងៃរសៀលអាចារ្យយក្សនាំកូនគាត់មកដែរ ឯអាជាលក៏មកពីព្រៃបានសត្វបានអីមកជាមួយផង។ អាជាលក៏ប្រាប់អាដោកថា៖ "អើ! ឥឡូវ អាចារ្យយក្សនាំកូនគាត់មកទៀតហើយ អាឯងនាំកូនគាត់ដើរកំសាន្តទីនេះទីនោះទៅ រួចឲ្យបាយឲ្យទឹកស៊ីផង!"

ឯអាចារ្យយក្សក៏ឡើងទៅមើលយាយ ហើយថា៖ "ម៉េចទៅយាយ យ៉ាងម៉េចហើយយាយ?"

អាចារ្យយក្សចេះតែមើលនេះ មើលនោះ ហើយទាញភួយមើលឃើញ ក៏សួរទៅអាជាលថា៖ "ស្បែកនិង សាច់ម៉េចទៅជាអញ្ចឹងអាជាល?"

អាជាលថា៖ "ទេ លោកអាចារ្យមិនដឹងយ៉ាងម៉េចដែរ ខ្ញុំឲ្យអាជោកដាំទឹកក្ដៅទុកមុជឲ្យគាត់ ឥឡូវស្រាប់ទៅជាអញ្ចឹងទៅ!"

អាជាលឃើញដូចនេះឡប់ៗបន្ទឹឡើងថា៖ "អូ! មិនកើតទេ ឯណាអាជោក? វានាំកូនអាចារ្យយក្សទៅដើរលេងទីណាខ្លះអញ្ចេះ?"

ឯអាជោកនោះវិញកំពុងតែនាំកូនយក្សទាំងពីរនាក់ទៅដើរលេងនៅតាមរបងផ្ទះ ចែចង់នាង ហើយវាបបួលនាងទាំងពីរលេងកាត់កជាមួយវា តែអាជោកវាលេងកាត់កកូនក្រមុំយក្សទាល់តែស្លាប់មែនទែន ហើយយកក្បាលនាងទាំងពីរទៅព្យួរលើរបងផ្ទះដាក់ទល់មុខគ្នា។

និយាយពីអាជាលជាបងដើររកអាជោក។ ពេលឃើញហើយវាក៏ស្រែកសួរទៅអាជោកថា៖ "ឯណាកូនក្រមុំអាចារ្យយក្ស? ឥឡូវយាយយើងគាត់ស្លាប់ហើយ!"

អាជោកតប៖ "អូ! កំពុងតែដើរលេងសកវាទ៍ ច្រៀងរាំលើរបងនោះ បងឯងមិនមើលហ្ន៎!"

អាជាលភ្ញាក់ផ្អើលព្រឺត៖ "ងាប់តម្រងវែង! ម៉េចបានជាទៅធ្វើអញ្ចឹង? បើរឿងហ្នឹងបានដឹងដល់អាចារ្យយក្ស វែងនិងអញប្រាកដជាមិនរស់ទេ ងាប់ហើយវើយ ងាប់ទាំងអាវែងងាប់ទាំងអញវើយ!"

រួចមកទើបអាចារ្យស្រែកសួរពីលើផ្ទះថា៖ "យើ! អាជោកយកកូនក្រមុំអញមកវិញវើយ អញទៅផ្ទះទៅ

អី! ឯងយកយាយវែងទៅកប់ទៅអីទៅ យាយវែងងាប់ហើយ!"

ហើយអាជាលនៅឯក្រោមផ្ទះនេះក៏ខ្សិបប្រាប់អាដោកម្ដងទៀតថា៖ "វែងសម្លាប់កូនគាត់ អញ្ចឹងវែងក៏ងាប់ អញក៏ងាប់ បើអាចារ្យហ្នងដឹង ប្រាដកជាស៊ីយើងហើយ មើលទៅយក្សនឹងដាច់សីល ស៊ីអញ ស៊ីវែងមិនខាន ឥឡូវមានអីមានតែផ្លូវរត់ចេញពីកន្លែងហ្នឹង!"

អាជាលថា៖ "អញ្ចឹងបើរត់ក៏រត់ទៅ តោះ!"

ពេលដែលអាចារ្យយក្សចុះមក ក៏ឃើញខ្លួនកូនរបស់ខ្លួននៅផ្សេង ឯក្បាលនៅលើរបងទាំងពីរនាក់ អាចារ្យយក្សកើតទុក្ខទោរម្នេញ ខឹងប្រលោតតោតតោងយ៉ាងខ្លាំង រកមើលអាដោក តែពីរនាក់បងប្អូនអាដោកអាជាលនាំគ្នារត់ចូលព្រៃបាត់ទៅ។ អាចារ្យខឹងណាស់ យកខ្មោចកូនទៅទុកនៅផ្ទះខ្លួនឲ្យបានស្រួលបួលសិនរួចទើបប្រាប់ប្រពន្ធថា៖ "យាយប៉ិកឯងនៅចាំផ្ទះសំបែង អញទៅរកអាដោកអាជាល ឃើញពេលណាអញស៊ីអាពីរនាក់នោះឲ្យខ្ទេច គ្មានទុកវែងទេ វែងសម្លាប់កូនអញ អញខំទៅមើលជីដូនវា តែវាបែជាសម្លាប់កូនអញ។"

ថាទាំងខឹងហើយ អាចារ្យយក្សក៏ស្ទុះរឹងចេញទៅព្រៃ តែមិនដឹងព្រៃណាទេ ចេះតែដើរហែកព្រៃមើល តែរកមិនឃើញពួកវាទេ ។

និយាយពីអាដោកនិងអាជាលវិញម្ដង ពួកវាបានរត់មកដល់ក្នុងព្រៃធំមួយ។ អាជាលសួរទៅអាដោកថា៖ "នែ អាប្អូន វែងគិតយ៉ាងម៉េចនៅក្នុងព្រៃនេះធំណាស់?"

អាដោកថា៖ "អញគិតអញ្ចេះ យើងគិតនាំគ្នាដេកនៅក្នុងព្រៃនេះសិនចុះ ព្រោះឥឡូវយប់ហើយ តែអញចង់ដេកកណ្ដាល!"

អាជាលថា៖ "ដេកយ៉ាងម៉េចទៅ យើងមានតែពីរនាក់ ដេកកណ្តាលយ៉ាងម៉េចទៅ?"

ប្អូនវាតបថា៖ "ដេកទន្ទឹមជើងគ្នាទាំងពីរនាក់ ព្រោះពេលដែលសត្វកាចសាហាវអីវាមក យើងស្រណុក នាំគ្នារត់ទាំងអស់គ្នា មានរឿងអី ៗទាំងអស់គ្នានាំគ្នាតតាំងទាំងអស់គ្នា។"

អាជាលថា៖ "អ្ហ! អញមិនចេះទេ!"

អាដោកឆ្លើយទៅបងវាថា៖ "អ្ហ! បើបងឯងល្ងង់ចាំស្តាប់អញទៅ គេដេកអញ្ចេះ បាតជើងហើយនឹងបាត ជើងទល់គ្នា ហើយអាក្បាលចេញដោយខ្លួន អាមួយទៅលិចអាមួយទៅកើត។"

ថាហើយ ក៏នាំគ្នាដេកអញ្ចឹងទៅ។

ពាក់កណ្តាលអាធ្រាតស្ងាត់នៅក្នុងព្រៃនិយាយពីសត្វដំរី ខ្លា ពស់អីផ្សេងៗដើរឆ្លងនៅកន្លែងដែលអា ដោកអាជាលដេក ព្រោះវាជាផ្លូវដែលពួកសត្វទាំងនោះដើររកស៊ីនៅពេលយប់។ ពេលពួកសត្វទាំងនោះដើរ រកស៊ី ពួកវាវាក៏ឃើញអាដោកអាជាលដេកជើងទល់គ្នា តែពួកវាមិនដឹងថាជាសត្វអីទេ ព្រោះមិនដែលប្រទះ សត្វអីចម្លែកម្ល៉េះមានខ្លួនមួយតែក្បាលពីរ។ សត្វទាំងនោះឆ្ងល់ណាស់ហើយថា៖ "អ្ហ សត្វនេះចម្លែកណាស់ វើយ! បើអញ្ចឹងយើងកុំអាលទៅ ច្បាស់ជាមានការមិនស្រួលហើយ ឈប់ត្រឹមហ្នឹងហើយ!"

ហើយសត្វទាំងនោះក៏នាំគ្នីគ្នាមកឲ្យជួយមើលទៀត តែនៅតែមិនដឹង ហើយក៏ហៅដំរីដែលជាសត្វចាស់ ជាងគេនៅក្នុងព្រៃឲ្យមកជួយមើល។ ដំរីមកដល់នៅតែមើលមិនស្គាល់ ហើយនិយាយថា៖ "មើល! អ្នកណាខ្លះ មកទីនេះ!"

ម្នាក់តបថា៖ "មកគ្រប់គ្នាអស់ហើយ!"



តែម្នាក់ទៀតថា៖ "អ្ហ! យប់នេះដូចជាបាត់បងទន្សាយ បងទន្សាយដូចជាមិនទាន់ឃើញ។"
សត្វទាំងនោះកំពុងតែជំនុំគ្នា ស្រាប់តែទន្សាយក៏មកដល់។ ហើយសត្វមួយថា៖ "បងទន្សាយឯងមើល

ស្អីនេះ? ខ្លួនធំហើយមានក្បាលដល់ទៅពីរ?"

ទន្សាយថា៖ "ហ្អា បើអញ្ចឹងឈប់ៗ សត្វនេះយើងបានដឹងចេះចាំយូរណាស់មកហើយ ពីព្រោះព្រះឥន្ទ្រលោកមកប្រាប់ខ្ញុំថាប្រយ័ត្នម្ខាលទន្សាយឯង បើដើរទៅកាលណាជួបឃើញសត្វមួយខ្លួនពីរហ្នឹងប្រយ័ត្នសត្វហ្នឹងឲ្យមែនទែន វាសាហាវណាស់ មិនដូចសត្វធម្មតាទេ។

រួចទន្សាយក៏បញ្ជាទៅសត្វទាំងអស់ថា៖ "ឥឡូវបងប្អូនទាំងអស់ប្រុងប្រៀបប្រយ័ត្នប្រយែងឲ្យមែនទែន ចាំខ្ញុំរកមើលដើមដំបូកណាខ្ពស់ហើយ ខ្ញុំនឹងប្រកាសប្រាប់ឯងទាំងអស់គ្នា។"

ថាហើយដូចនេះហើយ ទន្សាយក៏ស្ទុះឡើងក្ងួតលើដំបូកខ្ពស់នៅក្បែរនោះហើយប្រកាស់ថា៖ "សត្វនេះជាសត្វខ្លួនមួយក្បាលពីរឈ្មោះហៅថា សត្វអង្គីអង្គា ឆាប់គេឯងរពល់គ្នានៅតែអញមួយ។"

គ្រាន់តែឮប៉ុណ្ណឹង អាដំរីវាបោលជាន់អាសត្វឯទៀត ឆាប់មីដេរជាសតែម្ដង មានតែទន្សាយមួយរត់រួចខ្លួន។ ពេលអាដោកអាជាលក្រោកឡើងឃើញសត្វផ្សេងៗឆាប់នៅក្បែរខ្លួនវាច្រើនណាស់ ពួកវាក៏ប្រលាត់អាំងឆ្អើរសព្វគ្រប់។ ដល់វាដុតអាំងសាច់អញ្ចឹងទៅ សាច់នោះឈ្ងុយណាស់ ឈ្ងុយមហាសែនឈ្ងុយ សាច់ភ្លើងដុត ដោតជ្រនួច អាំងឲ្យឡើងឈ្ងុយ។ ដល់ឈ្ងុយពេកទៅ ក្លិននោះជះទៅដល់នគរយក្សមួយហៅថា អារុលចក្រជាស្ដេចមហាយក្ស។ វាធំក្លិនឈ្ងុយពេកទ្រាំមិនបានក៏និយាយប្រាប់ប្រពន្ធថា៖ "នែ យាយប៊ុក! ឯងមានធំក្លិនអីទេហ្នឹង!"

យាយថា៖ "ដូចជាធំដែរតាប៊ុក។"

ស្ដេចយក្សថា៖ "អ្ហេ បើអញ្ចឹង យាយប៊ុកឯងនៅចាំផ្ទះ យើងនឹងត្រវីដំបងពេជ្រនេះហោះធ្មៀលតាមដាន

ម្ដងមើល តើវាជាក្លិនអ្វីបានជាឈ្ងុយម្ល៉េះ!"

ថាហើយយក្សក៏ហោះទៅស្រាប់តែឃើញអាជោកអាជាលកំពុងតែឆ្អើរសាច់ យក្សក៏វេចយកសាច់ដែលអាំងរួចយកទៅៗ អាជោកអាជាលថា៖ "ស្រេចតែម្ដង ឯងទើបតែបានស៊ីបន្តិចបន្តួច វាវេចយកអស់រលីង បើអញ្ចឹងយើងឆ្អើរទៀត ក៏ប៉ុន្តែឥឡូវយើងធ្វើអញ្ចេះ ធ្វើទំនេរឲ្យខ្ពស់ជាងមុនហើយឆ្អើរសាច់ទៀត ព្រោះថាបើយក្សបានស៊ីម្ដងហើយ វានឹងញ៉ាមមកស៊ីម្ដងទៀត យក្សនោះវាមានពុកចង្ការវែងៗណាស់ៗ"

ថាហើយ ពួកវាក៏ទៅកាប់ដើមឈើអាប៉ុនៗសសរ ហើយនាំគ្នាសែងលីយកមកធ្វើធ្នើឲ្យខ្ពស់ រួចអាជោកប្រាប់ទៅបងវាថា៖ "នែ! យើងគួរតែកាប់កម្លោតធ្វើទុកសម្រាប់ពួនទៅក្បែរទំនេរនោះ ពីព្រោះពេលយក្សនោះឱនមកស៊ីសាច់យើងម្ដងទៀត ពុកចង្កាវានឹងធ្លាក់ចុះមក រួចពេលដែលពុកមាត់វាធ្លាក់មកជិតដល់រងើកភ្លើងដែលយើងឆ្អើរ ខ្ញុំនឹងចាប់ពុកមាត់វា កាលណាប្អូនស្រែកឲ្យអាបងឯងជួយ បងឯងមកជួយខ្ញុំផង កុំភ្លេចណា!"

ពេលយក្សបានសាច់អាំងទៅ វាយកសាច់ទាំងនោះទៅឲ្យប្រពន្ធស៊ី វានិងប្រពន្ធសប្បាយចិត្តណាស់ព្រោះបានស៊ីគាប់ចិត្តម្ដងនេះៗ ឯអាជោកអាជាលវិញចាប់ផ្ដើមឆ្អើរសាច់បន្តទៀត ក្លិនក៏ជះទៅដល់យក្សមួយសារទៀត យក្សទ្រាំពុំបានវាមកចង់យកសាច់ស៊ីមួយម្ដងទៀតៗ អាយក្សមកដល់ វាគិតថា៖ "យី! អញស៊ីសាច់ទាំងនោះឲ្យឆ្អែតសិន បើសាច់សល់ប៉ុន្មានទើបអញវេចខ្ចប់យកទៅផ្ញើប្រពន្ធអញៗ គិតហើយវាឱនចុះមកត្របាក់ស៊ីក្រឹបៗៗ ហើយអាពុកចង្កាវាធ្លាក់ចុះមកក្រោមៗ ពេលឃើញធ្លាក់ចុះមកយ៉ាងនេះ អាជោកឃើញក៏ចូលផ្លឹបចាប់ទាញពុកចង្កាយក្សនោះ ហើយវាស្រែកហៅបងវាអាជាលឲ្យជួយទាញដើម្បីយកពុកចង្កានោះមក

ចងរុំជាមួយនឹងសសរទំនើរចង្អើរនោះ។ ស្រាប់តែពុកចង្កាយក្សជាប់នឹងទំនើរនោះ វារើមិនរួចហើយថែមទាំងធ្លាក់មកលើរងើកភ្លើងទៀត យក្សក៏ស្រែកយំអង្វរអាជោកអាជាលថា៖ "លោកឯងដោះលែងខ្ញុំទៅព្រោះខ្ញុំជាយក្សចាស់ហើយ។"

អាជោកថា៖ "អាឯងមកយកសាច់យើងពីរដងហើយ! លើកទី១ យកសាច់អញអស់ ឥឡូវលើកទី២ ត្រូវជាប់ អញចាប់បាន អញមិនលែងទេ អញនឹងផ្ទើរឯងទៀត មិនលែងឡើយ!"

ថាហើយអាជោករឹតតែបួងពុកចង្កាយក្សឲ្យជាប់។ យក្សចាស់ក៏អង្វរទៀតថា៖ "ឥឡូវអញ្ចេះលោក! ឲ្យតែលោកឯងលែងខ្ញុំទៅ ខ្ញុំឲ្យប្រពន្ធ ឲ្យកូនក្រមុំធ្វើជាប្រពន្ធ ហើយឲ្យនគរលោកសោយរាជ្យទៀត។"

អាជោកថា៖ "អញមិនជឿវែងទេ បើរួចទៅ ស្រាប់តែវែងរទៅបោកប្រាស់យើ! អញមិនលែងទេពេលហ្នឹង ឥឡូវអញ្ចេះបើពិតមែនយក្សឯងស៊ីញ្ញេ ផ្ដិតមេដៃមេអីមក ចុះកុងត្រាឲ្យពិតប្រាកដ។"

យក្សក៏យល់ព្រមហើយថា៖ "បានពិតប្រាកដមែនឲ្យតែលោកឯងលែងខ្ញុំ។" អាជោកអាជាលក៏ព្រមលែងយក្ស ហើយយក្សក៏ស្រាប់តែទៅប្រាប់ប្រពន្ធខ្លួនថា៖ បងត្រូវគេចាប់បាន បងចុះកុងត្រាកិច្ចសន្យាថានឹងលើកកូនក្រមុំយើងទាំងពីរទៅអាជោកនិងអាជាលហើយ ហើយឲ្យពួកវាសោយរាជ្យនៅទីនោះទៀត ដូចនេះយាយឯងកុំមាត់ តែខំ គេមិនលែងបងទេ។"

យាយជាប្រពន្ធយក្សក៏មិនថាអីដែរ។ ក៏ប៉ុន្តែដល់ទៅថ្ងៃមួយនោះ អាជោកអាជាលមនុស្សខូចខិលមិនសូវបានល្អបានប្រពៃប៉ុន្មានទេ វាធ្វើបាបកូនស្រីរបស់យក្សហ្នឹងទៀត។ អាយក្សនោះខឹងក៏ដេញតាមរកអាជោកអាជាល។ អាជោកអាជាលមិនដឹងជារត់ទៅណា ក៏រត់ទៅជ្រកក្រោមត្បាល់កិនយក្សក្រោមផ្ទះយក្សនោះឯង។

យក្សដើររកយូរទៅ មិនឃើញ ក៏ហត់ ទៅអង្គុយនៅពីលើត្បាល់កិនហិហាក់ៗហើយថា៖ "យើស! ដេញវែងមិនទាន់ទេហ្អា បើដេញវែងទាន់អញត្របាក់វែងស៊ីតម្រង!"

អាដោកអាជាលនៅពីក្រោមត្បាល់កិនឮ អាដោកចេះតែកេះអាជាលជាបងថា៖ "បងៗ! បងមើលបង!"

តាមពិតអាដោកកេះបងវាឲ្យមើលពងយក្សធ្លាក់សំយាកចុះមកៗ ថាហើយអាដោកក៏ស្ទុះក្ដេតចាប់ទាញពងយក្សចាប់មួលយកតែម្ដងៗ យក្សកំពុងតែហត់ផង អស់កម្លាំងផង ក៏ស្រែកប្រឡោតគោតតួងបើងទាំងត្បាល់កិនៗ អាពីរនាក់នោះ ក៏រត់រួចខ្លួនម្ដងទៀតៗ អាយក្សថា៖ "អញមិនសុខចិត្តទេ ពេលនេះអញដេញអាវែងទៀតៗ"

ឯប្រពន្ធយក្សដឹងរឿងខឹងណាស់ ក៏សុខចិត្តរត់ដេញតាមអាដោកអាជាលទៀតៗ អាពីរនាក់នោះក៏រត់ទៅឡើងដើមដូងៗ ដល់ខឹងរត់ដេញអា២នាក់ហ្នឹងៗ រត់ឡើងដើមដូង យាយនោះរត់ទៅតាមទាន់ឃើញអាដោកអាជាលឡើងដើមដូងដូច្នោះ យាយនោះបន្ទឺទាំងខឹងថា៖ "យឺស! អាវែងនៅត្រង់ហ្នឹងទេហ្អឺស!!"

អាដោកថា៖ "អើយាយ! ខ្ញុំនៅលើដើមដូងទេ ឥឡូវអញ្ចេះ យាយឯងកុំពិបាកពេក យាយឯងចង់ហូបដូងទេយាយ?"

យាយថា៖ "អើ! ឯងទម្លាក់មក អើអញស៊ីដែរៗ"

អាដោកតទៀតថា៖ "អើ! បើយាយឯងចង់ពិសា យាយឯងចំទិតគូថឡើងលើមក អាហ្នឹងបានដូងធ្លាក់ទៅ វាមិនបែកៗ"

យាយថា៖ "អើ! ធ្វើម៉េចក៏ដោយឲ្យតែទម្លាក់មកអញបានស៊ីដែរ អញស៊ីដូងរួច អញនឹងស៊ីវែងៗ"

វាស្រាប់តែឃាយយក្សនោះតាំងចំទិតគូថ ក្បាលចុះក្រោមតាមសំដីអាដោកមែន ហើយអាដោកអាជាលកាត់ដូងទាំងផ្កាយៗទម្លាក់ចុះមកចំកំប៉េះគូថឃាយយក្សនោះទាល់តែស្លាប់ៗ

បន្ទាប់មកអាដោកអាជាលពីរនាក់បងប្អូនក៏បបួលគ្នាចុះពីដើមដូង រត់ទៅផ្ទះរបស់ខ្លួនវិញៗ

# ៤- រឿងតាបសល្បួចប្រាក់

## និទានដោយលោក ប៉ែន អយ [4]

លោកពូចង់ឲ្យលោកពូនិទានដែលចេះចាំ ដូចជារឿងល្បិចកលអីជាដើម?

អឺ.....មានរឿងមួយដូចជារឿងនៅក្នុងគតិលោកភាគ១របស់សុត្តន្តប្រិយជាឥន្ទហ្នឹង រឿងហ្នឹងវាទាក់ទងនឹងការពិនិត្យពិច័យលើលក្ខណៈសម្បត្តិរបស់មនុស្ស រឿងហ្នឹងវាអញ្ចេះ ដំបូងចោទសួរគ្នារវាងគ្រូ និងសិស្សពីរនាក់ៗ គ្រូសួរកូនសិស្ស ក ថា៖ "មើល! អ្នែងខ្លាចមនុស្សប្រភេទណាៗ"

សិស្សកឆ្លើយថា៖ "ខ្ញុំខ្លាចសេដ្ឋី!"

គ្រូសួរបន្ថែម៖ "ចុះឯងជំពាក់លុយសេដ្ឋីអី បានជាខ្លាចសេដ្ឋី?"

សិស្សកថា៖ "អត់ទេ!"

"ចុះបើអត់ ម៉េចក៏ខ្លាចសេដ្ឋី?"

ថាហើយ លោកគ្រូក៏សួរទៅសិស្សម្នាក់ទៀត៖ "មើល! ឯងខ្លាចមនុស្សប្រភេទណា?"

សិស្សខថា៖ "ខ្ញុំខ្លាចស្ដេចៗ"

លោកគ្រូថា៖ "ហេតុដូចម្ដេចបានជាឯងខ្លាចស្ដេច ឯងប្រព្រឹត្តបទល្មើសអី ខុសក្នុងច្បាប់ផែនដីបានជា

4 នៅភូមិត្រពាំង ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ

ខ្លាចស្ដេច ខ្លាចស្ដេចយកទៅដាក់ធ្វើទណ្ឌកម្មអីឬ?"

សិស្សថា៖ "អ្ហា! ខ្ញុំអត់ទេ។"

ដល់អញ្ចឹងកូនសិស្សសួរបកមកលោកគ្រូវិញថា៖ "មើលលោកគ្រូ! បើមិនឲ្យខ្ញុំខ្លាចមនុស្ស ពីរប្រភេទហ្នឹងតើឲ្យខ្ញុំខ្លាចមនុស្សប្រភេទណាទៅវិញ?"

គ្រូឆ្លើយថា៖ "ទេ! អញខ្លាចតែមនុស្សពាលទេ ព្រោះចិត្តពាលនិងចិត្តអាក្រក់មានគ្រប់មនុស្សទាំងអស់ហើយ បើយើងនិយាយផ្លូវធម៌មកវិញគឺកុសល និងអកុសល អញ្ចឹងនៅក្នុងខ្លួនមនុស្សយើងមានចរិតពីរហ្នឹងគឺកុសល និង អកុសល។ អញ្ចឹងបានខ្លាចមនុស្សពាលហ្នឹង មិនដឹងកើតនៅពេលណាទេ។"

អញ្ចឹងបានលោកគ្រូចាប់និយាយរឿងពីតាបសម្នាក់។ មានតាបសមួយអង្គតាបសហ្នឹងបួសនៅក្នុងព្រះពុទ្ធសាសនាតាំងពីតូច ប្រតិបត្តិស្វែងរកផ្លូវទៅកាន់រំលត់ទុក្ខក្នុងវាលវដ្ដសង្សារ ប្រព្រឹត្តធម៌បានល្អណាស់ រហូតបានក្លាយទៅជាទីពុំនាក់អាស្រ័យរបស់ពុទ្ធបរិស័ទ្ធជិតខាង។ គេមានជំនឿលើលោកព្រោះលោកប្រត្តិបត្តិធម៌បានល្អ អញ្ចឹងមានឧបាសកម្នាក់ដែលជា**ឧបដ្ឋាក**របស់លោកហៅថាជា**វេយ្យាវច** អ្នកឧបត្ថម្ភលោក។ ឧបាសកនោះលោកមានប្រាក់មួយកេះ អញ្ចឹងដោយមានជំនឿទុកចិត្តលើតាបសហ្នឹងខ្លាំងពេកក៏យកប្រាក់មួយកេះទៅផ្ញើនឹងលោកព្រោះកាលទុកនៅផ្ទះព្រោះភូមិករក្នុងសម័យកាលហ្នឹង មិនសូវមានសន្ដិសុខទេ អញ្ចឹងមានតែវត្តអារាមនិងយកទៅផ្ញើនិងលោកទេ អញ្ចឹងប្រាក់មួយកេះហ្នឹងអត់មានអ្នកណាដឹងក្រៅពីឧបាសកនិងតាបស។

តាបសក៏ព្រមទទួលបញ្ញើ ហើយយកប្រាក់នោះទៅកប់ក្រោមតូបរបស់ខ្លួន។ ថ្ងៃមួយ តាបសគិតថា៖ "

អញបួសយូរៗទៅ មគ្គមិនដល់ ផលមិនបាន ស្វែងរកនិព្វានអីមិនឃើញសោះ។" អញ្ចឹងតាបសមានគំនិតអាក្រក់ អន្ទុយគិតយូរៗ ទៅមានគំនិតមួយថា៖ "ទោះបីខំប្រឹងធ្វើធម៌អីក៏ដូចជាអត់បានផល រកផ្លូវទៅខាងមុខក៏មិនឃើញ វាដូចជាវិលវល់អស់ហើយ។ យី! អញបើសិនជាសឹកទៅវិញ ទៅរកស៊ីនឹងគេនឹងឯងជាឃរាវាសវិញ វាគ្រាន់បើជាងបួសយូរៗណាស់មកអញនឹងមានឱកាសបានប្រាក់ដែលឧបាសកទុកនឹងអញគឺអញយកទៅធ្វើដើមទុន។" គិតឃើញអញ្ចឹង។ នេះហើយគំនិតពាលចូលមកដល់។ អញ្ចឹងគិតរកពិធីយកប្រាក់មួយកេះហ្នឹងដោយ មិនឲ្យឧបាសកដឹង ដូចថាពាក្យបុរាណសុភាសិតមួយថា៖ "អុំទូកកុំឲ្យរអាន ចាប់ត្រីបានកុំឲ្យល្អក់ទឹក។"

អញ្ចឹងតាបសក៏ធ្វើដំណើរទៅផ្ទះឧបាសក។ ពេលឧបាសកឃើញតាបសហ្នឹងនិមន្តទៅដល់ ក៏ក្រាបថ្វាយបង្គំនិមន្តឡើងលើផ្ទះ រៀបចំកន្ទែងអីសមរម្យហើយបានសួរថា៖ "លោកម្ចាស់និមន្តមកជួបខ្ញុំករុណាហ្នឹងមានការអី?"

តាបសថា៖ "អាត្មាគិតសុំលាឧបាសកទៅនៅព្រៃ ព្រោះទីកន្លែងដែលនៅសព្វថ្ងៃហ្នឹង វាមិនស្ងប់ស្ងាត់ដូចនេះការប្រណិប័តន៍ធម៌ហ្នឹងវាមិនល្អ អញ្ចឹងអាត្មាគិតលាឧបាសកទៅនៅក្នុងព្រៃវិញដើម្បីងាយស្រួលប្រណិប័តន៍នៅធម៌ ហើយប្រាក់ដែលឧបាសកផ្ញើទុកនឹងអាត្មានោះ ឥឡូវសុំលោកឧបាសកអញ្ជើញទៅយកវិញចុះ។ តែប្រាក់មួយកេះរបស់ឧបាសកហ្នឹង តាបសបានដូរទីកន្លែងកប់ហើយ យកទៅកប់កន្លែងផ្សេងទៀត។

ឧបាសកក៏ឆ្លើយតបមកតាបសវិញថា៖ មិនអីទេលោកម្ចាស់ ព្រោះប្រាក់មួយកេះនេះគឺ មានតែលោកម្ចាស់និងខ្ញុំករុណាទេដែលដឹង កុំព្រួយបារម្ភអី ព្រះអង្គនិមន្តទៅក៏ទៅចុះ ចាំខ្ញុំករុណាទៅយកព្រោះអត់មានអ្នក

ដឹងក្រៅពីយើងទាំងពីនាក់ហ្នឹងទេ។"

និយាយអំពីព្រះពោធិសត្វព្រះអង្គយោនកំណើតជានាយស្ទូនផ្ទាំង គាត់បានធ្វើដំណើរលក់ដូរមក។ មកដល់កន្លែងផ្ទះឧបាសកឮសួរតាបសនិងឧបាសកជជែកគ្នាអញ្ចឹង គាត់ក៏នៅចាំស្ដាប់ដែរ។ ឮសួរអញ្ចឹងគាត់ពិចារណាវាយតម្លៃថា៖ "តាបសនេះប្រាកដជាយកប្រាក់របស់ឧបាសកហើយ។"

អញ្ចឹងនិយាយដល់រឿងតាបសនិងឧបាសកវិញ តាបសហ្នឹងមានល្បិចមួយទៀតដើម្បីចង់បញ្ជាក់ពីទឹកចិត្តដ៏បរិសុទ្ធរបស់ខ្លួនចំពោះឧបាសក ឲ្យឧបាសករឹតតែមានជំនឿលើខ្លួនថែមទៀត។ ពេលដែលចុះចេញពីផ្ទះរបស់ឧបាសកក៏លួចបេះយកស្បូវមួយសសៃយកមកដាក់លើក្បួងសក់របស់ខ្លួន ហើយចុះដើរចេញពីផ្ទះឧបាសកនោះទៅ។ ដើរបានប្រហែលជា ៤-១០ ជំហ៊ាន តាបសក៏ធ្វើដើរត្រឡប់មកផ្ទះឧបាសកវិញ។

ឧបាសកក៏សួរថា៖ "លោកម្ចាស់ហេតុដូចម្ដេចបានជាលោកម្ចាស់និមន្តមកវិញ?"

តាបសតបថា៖ "យាអ្អី! សូមអភ័យទោសពីលោកឧបាសកផង ព្រោះអាត្មាដើរចុះទៅអំមិញនេះបានជាប់អាជិញសសៃស្បូវមាសលើក្បួងសក់អាត្មា ឥឡូវអាត្មាយកមកជូនលោកឧបាសកវិញ កុំឲ្យអាត្មាហ្នឹងប៉ះពៀរលើសីលអី!"

ឧបាសកថា៖ "ដល់អញ្ចឹងមិនអីទេលោកម្ចាស់! ស្បូវមួយសសៃនេះមិនអាចប៉ះពារដល់សីលបរិសុទ្ធរបស់លោកម្ចាស់បានទេ!"

អញ្ចឹងតាបសធ្វើដំណើរចេញផុតមួយសន្ទុះទៅ ទទួលព្រះពោធិសត្វដែលជានាយស្ទូនផ្ទាំងដែលកំពុងពួនស្ដាប់នៅមាត់ច្រកចូលមក ក៏ដើរចូលមកសួរឧបាសកថា៖ "តាបសហ្នឹងត្រូវជាម៉េច?"

ឧបាសកហ្នឹងឆ្លើយថា៖ "តាបសហ្នឹងគឺរូបជាអ្នកប្រណិប័តន៍សីលបរិសុទ្ធណាស់ ព្រោះលោកប្រឹងរៀនបួសតាំងពីតូចមក លោកមិនដែលប្រព្រឹត្តផ្ដេសផ្ដាស់អីទេគឺមានតែសីលបរិសុទ្ធណាស់ៗ"

អញ្ចឹងព្រះពោធិសត្វនិងសួរទៀតថា៖ "ចុះឧបាសកឯងបានផ្ញើអីទឹងតាបសទេ ខ្ញុំហ្នឹងបានផ្ញើប្រាក់មួយកេះនៅនឹងលោកៗ"

ព្រះពោធិសត្វថា៖ "ឥឡូវទៅយកប្រាក់ពីតាបសវិញទៅ ប្រាក់ឧបាសកឯងតាបសហ្នឹងលួចហើយៗ"

ឧបាសកថា៖ "ឃើ ចុះអ្នកឯងនិយាយអញ្ចឹង! សូម្បីតែស្បូវមួយសសៃជាប់ក្នុងសក់លោក លោកត្រឡប់មកវិញ លោកមិនហ៊ានយកផងៗ"

"រឿងស្បូវមួយសសៃនេះ វាគ្មានអីសំខាន់ទេ តែអាប្រាក់ដែលឧបាសកឯងផ្ញើនឹងលោកនោះទើបសំខាន់ ឥឡូវលោកយកទៅហើយ តាមទៅ ក្រែងបានប្រាក់មកវិញ!" នាយស្នូទន្ទាំងប្រាប់ៗ

ទំរាំតែបានចេញទៅ តាបសចេញដំណើរទៅឆ្ងាយបាត់ហើយៗ ពេលឧបាសកទៅរកប្រាក់របស់ខ្លួនមិនឃើញ ក៏តាមរកតាបសៗ តាមទាន់តាបស ក៏ចាប់ធ្វើបាបដល់អាយុជីវិត ព្រោះតែខឹងពេកៗ

អញ្ចឹងសរុបមកវិញយើងនិយាយតាមផ្លូវធម៌បានថាចិត្តកុសលនិងអកុសនេះ បានន័យថាមនុស្សយើងប្រណិប័តិ៍បានល្អគឺជាកុសល តែបើកាលណាអំពើផ្ដេសផ្ដាស់គឺអកុសលចិត្តពាលហើយៗ បើកាលណាកុសលមានច្រើនអកុសលមិនបានចូលមកបានទេ បើកុសលមានតិច អកុសលចូលមកធ្វើឲ្យយើងធ្វើផ្ដេសផ្ដាស់តែម្ដងៗ អញ្ចឹងរឿងនេះ គេឲ្យមនុស្សម្នាក់ៗពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយៗ អញ្ចឹងយើងធ្លាប់ជាមនុស្សត្រឹមត្រូវតែងមានកុសលធម៌នៅក្នុងខ្លួន តែបើថ្ងៃណាកុសលធម៌ហ្នឹងធ្លាក់ចុះ អកុសលនឹងមានឥទ្ធិពល

ខ្លាំងចូលលុកលុយធ្វើឲ្យកើតចិត្តផ្តេសផ្តាស់ដូចតាបសហ្នឹងអញ្ចឹងដែលខំបួសរៀនតាំងពីតូច តែគិតថា៖ "មគ្គមិនដល់ ផលមិនបាន រកនិព្វានមិនឃើញ អញ្ចឹងមានតែសឹកមកវិញ បើសឹកមានអី មានតែមានតែយកមាសរបស់ឧបាសកអញ្ចឹង។" រឿងនេះរឿងប្រាកដជាតាបសល្មួចប្រាក់ដែលមានល្បិចល្អិតណាស់។ តែចំពោះអ្នកដែលមានបញ្ញាគេពិចារណាត្រូវ។

អញ្ចឹងហើយបានជាលោកគ្រូប្រាប់ថា៖ អញខ្លាចតែមនុស្សពាលទេ ព្រោះចិត្តពាលនោះមិនដឹងកើតនៅពេលណា។ រឿងនេះចប់ប៉ុណ្ណឹង។

# ៥- រឿងឪពុកក្មេករើសកូនប្រសារ

## និទានដោយលោក ជា ជឿន [5]



5 ភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម

ចំណែកឯរឿងឪពុកក្មេករើសកូនប្រសារ គឺគេចង់និយាយអំពីប្រពៃណីកាលនៅពីដើមដែលច្រើនតែកូនប្រុសជណ្ដឹងកូនស្រី រួចហើយឪពុកក្មេកក៏ដាក់តម្លៃបណ្ដាប់ដែលមានពាក្យគេនិយាយថា *បណ្ដាប់ស៊ីពោះលោះកំឡាំង*។ កូនប្រុសចង់បានកូនគេត្រូវតែប្រឹងហើយ ទោះបីគេបណ្ដាប់ដាក់ស្អីៗក៏ដោយ ក៏ចេះតែជូនគេទីបញ្ចប់គឺត្រូវទៅបម្រើគេសិនដើម្បីយកកូនគេ។ ហើយសារធាតុឪពុកក្មេកហ្នឹងទៀតគឺគាត់ជាមនុស្សក្រឡិចក្រឡុចពូកែខាងបោកប្រាសយុវជន គឺគាត់បោកបានច្រើននាក់មកហើយ គឺអ្នកដែលទៅជណ្ដឹងកូនគាត់ហ្នឹងគឺមិនបានជាប់ទេ បម្រើគាត់បានតែ២ឆ្នាំជិត៣ឆ្នាំ ជិតតែដល់ទឹងថ្ងៃការហើយ គាត់រកលេសចាប់កំហុសផ្ដាច់ចោល។ ដល់បានប៉ះកូនប្រសារជើងក្រោយ គេជើងគ្រាន់ដែរ គេក៏មានល្បិច គេដឹងចរិតគាត់រួចហើយ គេហៅថាអ្នកមានបញ្ញាសំរាប់ទប់ទល់។ ដល់អញ្ចឹងទៅឪពុកក្មេកហ្នឹងកំណត់ថា៖ "ឥឡូវកូនឯងត្រូវតែមកបម្រើយើងជាឪពុកក្មេក ម្ដាយក្មេកក្នុងក្រុមគ្រួសារ ទើបអ្នកឯងហ្នឹងមានសិទ្ធិរៀបការជាមួយនឹងកូនយើង រយៈពេលណាត់បម្រើនោះចំនួន៣ឆ្នាំ ហើយ៣ឆ្នាំហ្នឹងអ្នកឯងត្រូវតែលត់ដំឲ្យមែនទែន បើអ្នកឯងលត់ដំមិនបានទេ យើងនឹងផ្ដាច់ចោល។"

ខសន្យាត្រូវបានសម្រេចរៀងៗខ្លួន កូនប្រុសក៏ស្ម័គ្រចិត្តមកបម្រើតាមបណ្ដាប់ឪពុកក្មេក។

ថ្ងៃមួយឪពុកក្មេកដាក់ផែនការថា៖ "ព្រលឹមឡើងកូនឯងត្រូវដឹកក្របីយកទៅភ្ជួរស្រែ នៅពេលដែលព្រះអាទិត្យនៅក្បែរនោះយំតូតៗ ចាំកូនឯងដោះក្របីពីនឹមទៅ ហើយសម្រាកចុះ។"

កូនប្រសារនោះមិននិយាយអីទេ ក៏ដឹកក្របីយកទៅភ្ជួរទៅ។ កូនប្រសារហ្នឹងដឹងថាឪពុកក្មេកខ្លួនពួនលួចមើល ហើយគាត់ចាំតែចាប់កំហុសទេ។ ឪពុកក្មេកនឹងក្លែងខ្លួនធ្វើជាថ្មយំ ដើម្បីឃ្លាំចាំមើលកូនប្រសារ

ចំណែកឯងកូនហ្នឹងដឹងក៏ធ្វើជានិយាយថា៖ "ឱ! ក្របីអើយ ខ្ញុំអាណិតក្របីឯងណាស់ បើតាមខ្ញុំអត់អីទេ ទោះបីថ្ងៃហ្នឹងម៉ោង៣យំក៏ដោយ ក៏អត់អីដែរ ប៉ុន្តែក្របីឯងឲ្យតែថ្ងៃបន្តិចទៀត ក្របីឯងស្លាប់ហើយ ទំរាំថ្ងៃយំនោះ ព្រោះក្របីឯងត្រូវការទឹកៗ"

កូនប្រសារនោះមានបញ្ញាអញ្ចឹង ដល់ឪពុកក្មេកស្ដាប់ឮដូច្នេះក៏គិតថា៖ "ហ្អា! បើសិនជាអញមិនយំទេ ហើយចង់ធ្វើបាបកូនប្រសារ ច្បាស់ជាអញខាតហើយ ព្រោះក្របីត្រូវងាប់!"

អញ្ចឹងគាត់ក៏យំ៖ "តូតៗៗ!!"

កូនប្រសារហ្នឹងឮហើយក៏ដោះនឹមពីក្របីឲ្យស៊ីស្មៅ ដេកទឹកទៅ ចំណែកឯរូបគាត់ក៏ពិសាបាយដែរៗ ធ្វើអញ្ចឹងជាច្រើនលើកច្រើនគ្រា ហើយកូនប្រសារក៏រក្សាពាក្យនោះដដែលដែរ ចំណែកឯឪពុកក្មេកក៏ចេះតែគិតខ្លាចងាប់ក្របីហើយក៏ធ្វើតែអញ្ចឹងទៅៗ

ថ្ងៃមួយពេលមកដល់ផ្ទះ ឪពុកក្មេកហ្នឹងក៏និយាយជាមួយប្រពន្ធគាត់ថា៖ "អញថាចាប់កំហុសវា ប៉ុន្តែអានេះវាមានបញ្ញាណាស់ ចាប់វាមិនបានទេ វាមិនថាវាឃ្លានបាយទេ វាសុខចិត្តថាក្របីហ្នឹងក្ដៅតែក្ដៅវាងាប់ អញ្ចឹងបើអញមិនយំទេ ក្របីហ្នឹងងាប់ហើយម៉ែវា!"

ម៉ែហ្នឹងជំនុំជាមួយឪពុកហ្នឹងថា៖ "អញ្ចឹងឪវាឯងមានផែនការអីស្អែក?"

ឪពុកថា៖ "អ្ហេ អញ្ចឹងស្អែកហ្នឹងយើងត្រូវរកផែនការថ្មី អញគិតទៅរកអណ្ដើកនៅក្នុងព្រៃ អញឲ្យវាធ្វើផ្ដេករកអណ្ដើក អញធ្វើម្ចាស់ បើវារកមិនបានហើយទ្រាំមិនបានទៀត អញនឹងផ្ដាច់វា!"

ចំណែកឯកូនប្រសារនោះ វាបានមកលបស្ដាប់នៅក្រោមផ្ទះដឹងផែនការឪពុកក្មេកនោះអស់ ក៏ត្រឡប់

ទៅវិញ។ វាទៅរកទិញអណ្ដើកចងតាមគម្ពោតព្រៃ។ ព្រឹកឡើងក៏ដើរមកដល់ផ្ទះឪពុកក្មេក ឪពុកក្មេកថា៖ "ហ្អែងត្រូវធ្វើឆ្កែទៅរកអណ្ដើកក្នុងព្រៃ អញធ្វើម្ចាស់! អញ្ចឹងយើងនាំគ្នាទៅបណ្ដើរអណ្ដើក!"

ឪពុកក៏ស្ពាយបាយ ទឹកបំពង់ ស្នាព្រៃ មួអីទៅជាមួយ ធ្វើជាម្ចាស់បណ្ដើរកូនប្រសារធ្វើជាឆ្កែទៅ។ លុះមកដល់គម្ពោតព្រៃដែលវាចងអណ្ដើកទុកហ្នឹង វាស្រែកព្រូសវ៉ុសៗៗ។ អាពុកក្មេកហ្នឹងដើរទៅមើលឃើញអណ្ដើកមែន ក៏ស្រាយយកដាក់ក្នុងសម្ពាយពន់យកទៅ។ ដើរៗទៅមុខទៀត ចំគម្ពោតព្រៃមួយ ឆ្កែស្រែកវ៉ូសៗ ៗ ឪពុកក្មេកហ្នឹងទៅឃើញអណ្ដើក ធ្វើរបៀបហ្នឹងរហូតទាល់តែឪពុកក្មេករែកមិនចង់រួច។

ដល់វាធ្ងន់អញ្ចឹងពេក អាពុកក្មេកថា៖ "អ្ហា ឥឡូវកូនឯងអញ្ចេះចុះ កូនឯងមកធ្វើម្ចាស់វិញ ឪធ្វើឆ្កែម្ដង ព្រោះធ្ងន់ពេកស្ពាយស្ទើរមិនរួចទៅហើយ!"

តាមពិតឪពុកនោះមានចិត្តលោភលន់ចង់រកអណ្ដើកឲ្យបានច្រើនថែមទៀត ហើយចង់ធ្វើបាបកូនប្រសារឲ្យស្ពាយអណ្ដើកជាច្រើននោះផង។ កូនប្រសារក៏យល់ព្រមគ្នា។ ឪពុកក្មេកធ្វើឆ្កែ អាកូនប្រសារធ្វើម្ចាស់ម្ដង។ កូនប្រសារចេះតែបណ្ដើរអាពុកក្មេក ហើយឆ្កែឪពុកក្មេកហ្នឹងចេះតែដើរព្រូសតាមគម្ពោតព្រៃ វាមានអណ្ដើកមកពីឯណា បើអត់មានគ្រោងទុកមុនផង ចេះតែព្រូសៗទៅ ដល់តែព្រូសញយៗទៅ កូនប្រសារវាយឆ្កែ ព្រោះវាទៅរកអណ្ដើកមិនឃើញ។ ឪពុកស្រែកថា៖ "ម៉េចអ្ហែងវាយអញ?"

កូនថា៖ "អ្ហា! កុំចេះតមាត់ ឆ្កែមិនបានការ ព្រូសពេញតែគម្ពោតព្រៃ គ្រប់តែកន្ទែង បញ្ឆោតតែម្ចាស់ ឆ្កែបំបង់បាយទេតើ!!"

អាកូនប្រសារហ្នឹងថាឲ្យឪពុកក្មេកហ្នឹង។ ពេលហ្នឹងអន់ចិត្ត ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច បើខុសសន្យារវាងគ្នា

អញ្ចឹងទៅហើយ។ រួចក៏ដល់ពេលសំរាកពិសារបាយខាងក្រោមដើមឈើ កូនប្រសាជាក់បាយយកមកស៊ីៗ ដល់កំពុងតែស៊ីអញ្ចឹងទៅ ឪពុកក្មេកថា៖ "ម៉េចអ្ហែងមិនឲ្យអញស៊ីផង?"

កូនប្រសារថា៖ "អ្ហោ! ឆ្កែបំបង់បាយអញ្ចឹង មិនឲ្យស៊ីទេ! ស៊ីធ្អឹងស៊ីឆ្អែងអីទៅ កុំមកស៊ីបាយអី!"

កូនប្រសារក៏ស៊ីបាយទាល់តែអស់ទៅៗ ឆ្កែរកអណ្ដើកមិនបាន ម្ចាស់ហ្នឹងក៏វាយប្រមាថធ្វើឲ្យទ្រមខ្លួនទៀត រួចក៏នាំគ្នាមកផ្ទះវិញ។ អាកូនប្រសារត្រលប់ទៅផ្ទះវាទៅៗ ឪពុកក្មេករកល្បិចទៀត ហើយថា៖ "ស្អែកបណ្ដើរអណ្ដើកទៀត ម្ដងនេះអញចាប់កំហុសវា ធ្វើម៉េចឲ្យបានបន្អត់បាយវា វាយវាដូចជាវាបន្អត់អញអញ្ចឹង។"

ចំណែកឯកូនប្រសារហ្នឹង វានៅតែរៀបចំផែនការវាបាន វានៅតែធ្វើឆ្កែអញ្ចឹង ប៉ុន្តែដល់ទៅ បណ្ដើរបានអណ្ដើកបានច្រើន ធ្ងន់មិនអាចស្ពាយទៅមុខបាន ក៏សម្រាកហូបបាយ។ ដល់តែពេលសម្រាកហូបបាយហ្នឹង ឆ្កែហ្នឹងវាមិនមែននៅស្ងៀមឯណា វាឃើញក្របីគេកំពុងតែចងក្បែរវាលស្រែ ឆ្កែហ្នឹងវាទៅដោះក្របីគេហ្នឹង ហើយដេញអាក្របីហ្នឹងឲ្យចូលស៊ីស្រូវគេ។ ដល់អាក្របីចូលស៊ីស្រូវ ម្ចាស់ឆ្កែហ្នឹងគឺអាពុកក្មេកក័យខ្លាចគេឲ្យសង ព្រោះក្របីទៅស៊ីស្រូវរបស់គេដោយសារឆ្កែរបស់ខ្លួន អញ្ចឹងរត់ទៅដេញក្របីហ្នឹង។ អាឆ្កែនោះត្រឡប់មកវិញ ដាក់បាយកញ្ចប់ស៊ីអស់ មិនបានទុកឲ្យឪពុកក្មេកស៊ីផងទេ។ អាពុកក្មេកត្រឡប់វិញឃើញ ក៏ដេញឆ្កែវិញម្ដង តែកូនវាថា៖ "អ្ហោ សត្វឆ្កែវាដឹងអីវា!"

ឪស្ដីបន្ទោសថា៖ "ម៉េចក៏មិនទុកបាយឲ្យអញស៊ីផង?"

កូនថា៖ "អ្ហោ! ទុកបាយអី ឆ្កែវាមានដឹងអីទេ តែជាក់បាយចោលវាស៊ីអស់ហើយ!"

អាពុកក្មេកហ្នឹងអត់បាយមួយថ្ងៃទៀត មៀលមិញទៅទ្រមមួយសារហើយ ថ្ងៃហ្នឹងអត់បាយមួយសារ

ទៀត។ ដល់ត្រឡប់មកដល់ផ្ទះវិញ ដេកពិចារណារកផែនការទៀតតើត្រូវធ្វើអី ហើយក៏គិតឃើញផែនការមួយនិយាយប្រាប់ប្រពន្ធថា៖ "អេ្ហ លើកហ្នឹងអញ្ចេះចុះ ប្រាប់វាថាឲ្យវាវែកឥវ៉ាន់ទៅកាប់ចំការ ព្រោះឪពុកទៅមុនហើយ រួចម៉ែវាឯងចាំមើលណា អញចូលក្នុងបាវ រួចចងមាត់បាវឲ្យជិត ហើយម្ខាងទៀតដាក់អង្ករ ស្បៀងករវាថា ឪពុកទៅចំការមុនហើយ ទៅកាប់ចំការអញ្ចឹង ឲ្យវាវែកទៅ អញចាំស្ដាប់មើលតើវាថ្ងូរ តើវារអ៊ូ វាអីឬទេ បើរអ៊ូ អញព្ធ អញនឹងផ្ដាច់វាចោលតែម្ដង វាអត់ដឹងអ្ហាស។"

ចំណែកកូនប្រសារដឹងរឿងទៀត។ ព្រឹកឡើងក៏ត្រៀមខ្លួនមកវែក វែកអញ្ចឹងទៅ។ វាមានបញ្ហា វាក៏និយាយថា៖ "ពុកគាត់ចង់ឲ្យកូនមាន ហេតុតែគាត់ស្រលាញ់កូន ទោះចាស់ប៉ុណ្ណឹងហើយ ក៏គាត់ប្រឹងប្រែងទៅកាប់ចំការ ធ្ងន់កាត់កក់ ល្បាប់ ភ្នំ ថ្មអីសព្វបែបយ៉ាង គួរឲ្យអាណិតឪពុកខ្ញុំណាស់!"

ដើរបណ្ដើរនិយាយបណ្ដើរក៏ទៅដល់ស្ពាន ហើយក៏បន្តនិយាយទៀតថា៖ "បែបពុកចាំយូរហើយមើលទៅ តែណ្ហើយ! ពុកចាំមួយភ្លែតក៏ចាំចុះ ដល់កន្ទែងត្រជាក់ហើយ មុជទឹកបន្តិចសិន។"

ថាហើយ វាក៏ដាក់អំវែកឪពុកហ្នឹងទៅប៉ប្រះចុងស្ពាន ធម្មតាស្ពានបុរាណឥតមានបង្កាន់ដៃឯណា មិនដូចស្ពានយើងឥឡូវទេណ៎ា ស្ពានហ្នឹងគ្រាន់តែធ្វើឲ្យបានឆ្លងរួរ ឆ្លងព្រែកទៅ គឺមានតែចុងក្ដាប៉ុណ្ណឹងទេ មិនមានបង្កាន់ដៃពាំងទេ។ អញ្ចឹងគាត់ដាក់អំវែកនៅជិតចុងក្ដាហ្នឹង ហើយគាត់ចុះមុជទឹក។ ពេលត្រឡប់មកវិញគាត់ធ្វើជាដើរទន្ទ្រាំស្ពានព្ធស្ទូរ "ក្តួង១១" រួចទៅគាត់ដើរត្តួខ្លួនឯង រត់ទៅក្បាលស្ពានម្ខាងទៀត ហើយស្រែកថា៖ "អូ! លោកម្ចាស់ជំរីអើយ លោកកុំអាលបរជំរីមក ប្រយ័ត្នជាន់ឪពុកក្មេកខ្ញុំងាប់! អូ១១! ជាន់ស្បៀងខ្ញុំហើយនេះ។ មិនថាឪពុកក្មេកទេ។ គ្រាន់តែថាជាន់ឥវ៉ាន់ៗខ្ញុំហើយៗ កុំ១១!"

រួចក៏ធ្វើជាស្រែកពីចម្ងាយមក ដោយចេះតែទន្រ្ទាំ "ក្អួងៗៗ!!" ឪពុកក្មេកឯណោះភ័យខ្លាចដំរីជាន់ គាត់ចេះតែរមៀលប្រកិលបន្តិចម្តងៗៗ ក៏ផុតអាចុងស្ពានធ្លាក់ទឹកគ្រាំទៅ។ អាកូនប្រសារឯណោះក៏ទុកឲ្យឈ្ងក់ទឹកបន្តិចសិន មិនទាន់ទៅស្រង់ទេ  ហើយធ្វើជាស្រែកឆោឡោថា៖ "អ្ហា! ដំរីៗម៉េចក៏ឈូសអំរែកខ្ញុំធ្លាក់ក្នុងទឹកអញ្ចឹង ដំរីម៉េចធ្វើអញ្ចឹង ដំរីហ្នឹង?"

ហើយកូនប្រសារក៏រត់ទៅបណ្ដើរ ទំរាំតែទៅដល់ឪពុកក្មេកឈ្ងក់ទឹកក្អកៗចង់ស្លាប់ រួចទើបស្រង់ចេញមក។ ពេលស្រង់ចេញមក ស្រាប់តែដឹងថាឪពុកហ្នឹងក៏ស្រាយចំណងចេញទៅ។ ឪពុកហ្នឹងក៏មិនដឹងជាមានល្បិចអីធ្វើទៀត មកដល់ផ្ទះហ្នឹងក៏និយាយជាមួយប្រពន្ធនិងកូនថា៖ "យល់ព្រមរៀបផ្សំផ្គុំកូនស្រីយើងឲ្យទៅអាកូនប្រសារនោះទៅ ត្បិតអីអាអន្ទិតនេះមានបញ្ញាណាស់ ចាញ់បញ្ញាវាពល់តែដង។

# ៦- រឿង សត្វលលក កុក និងកណ្ដុរ

## និទានដោយលោកអាចារ្យ អឿង [6]



6 ភូមិទន្លេបាទី ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ

ចុះរឿងព្រេងផ្សេងៗទៀត ដូចជារឿងដែលលោកអ៊ុំធ្លាប់ឮចាស់ៗនិយាយកាលពីអ៊ុំនៅក្មេង គាត់និទានឲ្យអ៊ុំស្ដាប់ រឿងខ្លីៗដែលគេនៅចាំ ធ្លាប់និទាននៅតាមស្រុក តាមភូមិៗ

ខ្ញុំនិយាយពីរឿងមួយ តែរឿងហ្នឹងវាអត់ពិតទេ។ និយាយពីសត្វលលក កុកនិង កណ្ដុរ ខឹងនឹងគ្នា។

មានកណ្ដុរមួយមានប្ដីហើយមានកូនមួយសំបុក។ ឯសត្វលលកនិងកុកនោះវាអត់មានប្ដីទេ ពីរនាក់នេះជាសំឡាញ់នឹងគ្នា។ កុកតែងតែស្ដាប់បញ្ជាលលក។ លុះដល់ខែអំបុកស្រូវថ្មីមកដល់ វាចង់អំបុក លលកមិនដឹងធ្វើម៉េចបានហូប វាហៅកុកថា៖ "អើយបងកុក!!"

កុកគេថា៖ "ចាស៎! បងលលក!"

លលកបញ្ជាថា៖ "បងកុកឯងទៅខ្ចីអំបែងពីបងកណ្ដុរមក អញៗទៅកើបអំបុកយកមកឲ្យស៊ី!"

កុកសួរបន្ត៖ "រួចចុះហៅគេយ៉ាងម៉េចទៅ?"

លលកតប៖ "យីស! បើបងកុកឯងមិនចេះហៅកណ្ដុរទេ អត់បានអំបែងមកទេ! កណ្ដុរនឹងប្រកាន់ណាស់ បើហៅមិនសមរម្យ មិនលើកកំពស់ទេ មិនងាយឲ្យអំបែងខ្ចីទេ អញ្ចឹងបងកុកឯងគួរហៅថា *អ្នីអ្នកអន្ទែអន្ទាបស្មៀកសំពត់ផាមួងប្រកៀបប្រពន្ធនាយម៉ឺនញុម!* អញ្ចឹងបានគេឲ្យ គេមិនកំណាញ់ទេ។"

លុះកុកហើរមកដល់ផ្ទះកណ្ដុរ ក៏លាន់មាត់ថា៖ "យីចុះកណ្ដុរនៅឯណា?"

ក្រលេកឃើញពីចម្ងាយកុកថា៖ "នោះនៅក្រោមដើមឈើនោះតើ!"

ថាហើយ កុកក៏ហើរទៅ ទៅដល់ក៏ហារមាត់ខ្ចី តែវាភ្លេចពាក្យសំរាប់ហៅបងកណ្ដុរនោះ ភ្លេចអស់ពាក្យ

អន្ទែរអន្ទាបអន្ទែរអន្ទោយ[7]អីហ្នឹងអស់!

កុកលាន់មាត់ថា៖ "យី អាលលកផ្ដាំមកអម្បាញ់មិញឲ្យអញហៅយ៉ាងម៉េចអញ្ចេះ?"

កុកក៏ហៅ៖ "កណ្ដុរកណ្ដោច កណ្ដុរមុខខ្មោច អំបែងនៅឯណា លលកឲ្យខ្ញី !!"

លុះកុកស្រែកហៅនៅនឹងមុខគេអញ្ចឹង កណ្ដុរខឹងណាស់ វាធ្វើមិនដឹង អត់ឮអីទាំងអស់ៗ ឯកុកចេះតែហៅទៀតថាកណ្ដុរកណ្ដោច កណ្ដុរមុខខ្មោច អំបែងនៅឯណាខ្ញីដាល់អំបុកស៊ី លលកចង់ស៊ីអំបុកនៅតែឯង! ព្រោះមិនដឹងថាជាពាក្យមិនសមរម្យអីទេៗ កណ្ដុរនៅតែធ្វើមិនឮ គិតតែខំធ្វើការរបស់ខ្លួនទៅៗ ហើយប្ដីកណ្ដុរក៏អត់នៅផ្ទះដែរ វានៅមើលកូនបណ្ដើរ ធ្វើការបណ្ដើរទៅៗ កុកហៅយូរៗទៅ កណ្ដុរអត់ឮ កុកអស់ចិត្តក៏ហើរត្រលប់មកវិញ រួចលលកសួរថា៖ "ឯណាអំបែង? អំបែងឯណា?"

"គេអត់ស្ដីរកផងហ្នឹង!!" កុកថាៗ

"ចុះឯងហៅគេថាម៉េច??" លលកសួរ ៗ

"អញហៅកណ្ដុរកណ្ដោច កណ្ដុរមុខខ្មោច អំបែងនៅឯណា លលកឯងឲ្យខ្ញី!" កុកតបៗ

លលកហួសចិត្ត៖ "អូ! ទៅហៅគេអញ្ចឹង គេម៉េចនឹងនិយាយរក! អើ! ចាំផ្ទះម្ដងទៅ អញ្ចឹងអញទៅហៅម្ដង!"

លលកគេទៅហៅថា៖ "អើអ្នកអន្ទែរអន្ទាបស្នៀកសំពត់ផាមួងប្រកៀបប្រពន្ធនាយម៉ឺនញុម!"

កណ្ដុរគេឮសួរអញ្ចឹងឆ្លើយ៖ "ចាស៎ៗ ! អូ បងលលកមានការអី មកអញ្ជើញអង្គុយលេងៗ"

---

7 ពាក្យបុរាណថា អ្នកខ្ពង់ខ្ពស់

លលកថា៖ "ចុះកូនចៅបងកណ្ដុរឯងយ៉ាងម៉េចដែរ? និយាយអញ្ចឹង ខ្ញុំឃើញស្រូវថ្មី ចង់ហូបអំបុក ឃើញអំបែងបងកណ្ដុរឯងមាន ខ្ញុំចង់ខ្ចីទៅដាល់អំបុកហូបៗ"

កណ្ដុរថា៖ "សុខសប្បាយល្អជាទេ! អើ មិនអី អំបែងខ្ញុំទុកនៅក្រោមដើមម្ទេសឯណោះទៅយកចុះ!"

លលកក៏ទៅយកអំបែងទៅដាល់អំបុកៗ ដល់ដាល់អំបុកហើយ កុកវាស៊ីអំបុកដែរៗ ដាល់រួចរាល់ហើយលលកនិងកុកក៏ទៅផ្ទះកណ្ដុរទាំងអស់គ្នា យកអំបែងឲ្យគេវិញៗ ពេលទៅដល់ លលកក៏ស្រែកហៅកណ្ដុរថា៖ "អ៊ីអ្នកអន្ទេរអន្ទាបស្លៀកសំពត់ផាមួងប្រកៀបប្រពន្ធទាយម៉ឹនញុម! ប្ដីអ្នកឯងមកហើយឬនៅ?"

កណ្ដុរញីក៏ឆ្លើយ៖ "ហ៊ឺ! ប្ដីខ្ញុំអត់ទាន់មកទេអ្នកអើយ អង្គុយលេងសិនមក អំបែងទុកគុម្ពម្ទេសនោះចុះ!"

លលកនិងកុកក៏ចូលមកអង្គុយលេងៗ អញ្ចឹងមួយសន្ទុះក្រោយមកក៏នាំគ្នាចេញមកវិញៗ ដល់ពេលរៀបលាចេញមកវិញ លលកឃើញកូនកណ្ដុរមួយសំបុកក៏ថា៖" ហេកូនអ្នកឲ្យតំរៀបគ្នាល្អណាស់!!"

កណ្ដុរអួតថា៖ "កូនខ្ញុំវាមិនសូមយំ មិនសូវអីទេអ្នកអើយ!"

ថាអញ្ចឹង លលកក៏ដើរចេញបាត់ទៅ តែកុកវិញថា៖ "កូនកណ្ដុរវារំដើប មុខស្រួចល្អចដូចឪឯងអញ្ចឹង ឪឯងប៉ិនល្អចប៉ិនស៊ីណាស់!!"

ពូដូចនោះ កណ្ដុរខឹងកុកខ្លាំងណាស់ អត់ស្ដីរកកុកទេ ហើយបែរធ្វើជាទៅអ៊ុំអង្ករនៅឯក្រោមដើមឈើឯណោះវិញធ្វើមិនដឹងៗ ឯកុកវិញឃើញអញ្ចឹង វានៅតែថាឲ្យកូនកណ្ដុរ "មុខលេបមួយល្អចដូចឪពុក មុខលេបមួយល្អចដូចឪឯង" និយាយបណ្ដើរកុកលេបកូនកណ្ដុរបណ្ដើរ លេបពាំកូនកណ្ដុរម្ដងមួយៗទាល់តែអស់កូនកណ្ដុរមួយអង្រឹងហ្នឹងទៅៗ រួចក៏ថា៖ "អញលាសិនហើយវើយ!"

កណ្ដុរហ្នឹងរវល់តែជក់ការងារអុំអន្ទរអុំអីទៅ ក៏ក្មេចមើលកូនរបស់ខ្លួនមួយសំបុកហើយឆ្ងល់៖ "យី កូនអញអត់មានឮយំសោះ? អត់ឃ្លានអឹមទេអី?"

លុះកណ្ដុរឡើងមកមើល អត់ឃើញកូនរបស់ខ្លួនទេ ព្រោះមីកុកស៊ីកូនខ្លួនអស់ខ្ទេចអស់រលីង កណ្ដុរខឹងនឹងកុកខ្លាំងណាស់ ក៏ជេរវា៖ "អើមីចោរ ស្អុងយ៉ា! ហងតារើងទៅ ជើងហងតាក់ៗតារ! ស៊ីកូនអញអស់!"

តែកុកធ្វើជាមិនដឹងៗ រឿងហ្នឹងចប់ប៉ុណ្ណឹង នេះជារឿងចាស់ កុំសើចកុំយំអី ឪពុកម្ដាយខ្ញុំធ្លាប់និទានឲ្យស្ដាប់ពេល អង្គុយជុំៗគ្នា។

# ៧- រឿងក្អែក១ជាក្អែក១០

## និទានដោយលោក ប៉ែន អយ [8]

*រឿងក្អែក១ជាក្អែក១០*

*អូ! រឿងហ្នឹងមានអាខិលអាខូចហ្នឹងវាដើរតែរកស៊ីប្ញន់គេទេ វាជាជើងប្ញន់ វាដើរប្ញន់គេបានមាសប្រាក់យកមកមួយរទេះគោ។ ដល់បានមកអញ្ចឹងទៅ វាវាយដណ្ដើមគ្នាដល់វាយដណ្ដើមគ្នាអញ្ចឹងក៏ស្លាប់ទាំងពីរនាក់ទៅ។*

*និយាយពីបុរសម្នាក់ ជាអ្នកដើររកអុស រកវល្លិ៍ក្នុងព្រៃ គាត់ដើរទៅ ស្រាប់តែបានឃើញមាសមួយរទេះនេះ នៅក្នុងព្រៃ។ ឃើញដូច្នេះ គាត់នឹកឃើញគំនិតមួយឡើងថា៖ "យី បើមាសច្រើនម៉្លឹងៗ បើអញយកទៅផ្ទះប្រាប់ប្រពន្ធអញ ខ្លាចប្រពន្ធអញអត់ចេះលាក់ការ ដូច្នោះអញគួរទុកមាសនៅទីនេះសិន អត់ទាន់យកទៅផ្ទះទេ។"*

*ពេលត្រឡប់ទៅដល់ផ្ទះវិញ ប្រាប់ប្រពន្ធថា៖ "យីពេលជិតភ្លឺហើយហ្នឹង បងទៅបត់ជើងស្រាប់តែឃើញក្អែកមួយចេញពីរន្ធគូថបង!"*

*ការពិតវាករប្រពន្ធវាទេ ហើយវាតាមដានតើរឿងរបស់អញនិយាយប្រាប់ប្រពន្ធអញ នាងដើរនិយាយប្រាប់គេដែរឬអត់។*

---

8 *នៅភូមិត្រពាំង ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ*

ដល់អញ្ចឹង ស្រាប់តែប្រពន្ធហ្នឹងចេះតែដើរនិយាយប្រាប់គេថា៖ "យប់មិញប្ដីខ្ញុំបត់ជើងចេញដល់ក្អែកពីរឯណោះ អាមួយចេញហើយស្រាប់តែអាមួយចេញទៀត។ ចំណែកឯអ្នកដែលបានទទួលពត៌មាននោះ គេដើរទៅនិយាយប្រាប់គេតទៀតថា ប្ដីអានោះទៅបត់ជើង ចេញដល់ក្អែកបី គឺចេញពីគូថហ្នឹង ហើយចេះតែនិយាយតៗអញ្ចឹងពីក្អែកមួយនិងរហូតដល់ក្អែក១០ គឺចេះតែបន្តៗអញ្ចឹងទៅ។

បន្ទាប់មករឿងហ្នឹង ក៏បានដឹងដល់ស្ដេច ហើយស្ដេចក៏ឲ្យគេហៅបុរសហ្នឹងមកសួរឲ្យដឹងហេតុការណ៍មើលរឿងវាពិតមែនឬយ៉ាងម៉េច វាមិនដែលអាណាទៅបត់ជើងចេញដល់ក្អែកនោះទេ។

បុរសហ្នឹងទៅក្រាបទូលប្រាប់ព្រះមហាក្សត្រថា៖ "ទូលព្រះបង្គំហ្នឹងបានចូលទៅក្នុងព្រៃ ហើយបានឃើញមាសប្រហែលមួយរទេះគោ អញ្ចឹងទូលព្រះបង្គំមិនហ៊ានយកមកប្រាប់ប្រពន្ធ ខ្លាចប្រពន្ធហ្នឹងលាក់កិច្ចការមិនជិត ដូច្នេះទូលបង្គំក៏បង្កើតរឿងប្រឌិតមួយឡើងជាល្បិចមួយប្រាប់ប្រពន្ធទូលបង្គំ ដើម្បីចង់ដឹងថាតើនាងលាក់រឿងហ្នឹងជិតឬមិនជិត គឺថាទៅបត់ជើងហ្នឹងក្អែកវាមានតែមួយទេ តាមពិតប្រពន្ធទូលបង្គំទៅប្រាប់គេថាក្អែកដល់ទៅពីរ អញ្ចឹងរឿងហ្នឹងចេះតែប្រឌិត តៗគ្នា រហូតដល់ក្អែក១០។"

ស្ដេចក៏បានដឹងពីហេតុការណ៍ពិតទាំងនេះ។ បុរសនោះក៏យកមាសហ្នឹងមកថ្វាយដល់ព្រះមហាក្សត្រ។ ចំណែកឯស្ដេចក៏ចែកទ្រព្យសម្បត្តិទៅឲ្យបុរសហ្នឹងវិញហើយលើកឲ្យធ្វើជាអ្នកមាន ដែលមានការគាំទ្រ និងរាប់អានពីស្ដេចជារៀងរហូតទៅ។ នេះហៅថាអ្នកមានគំនិតបញ្ញាឈ្លៀសវៃគឺអញ្ចឹងឯង៕

# ៨- រឿងអាខ្វាក់អាខ្វិន

## និទានដោយ ស្រីលក្ខណ៍ [9]

*រឿងអាខ្វាក់អាខ្វិនហ្នឹងខ្ញុំដឹងតើ!*

*អញ្ចឹងនិទានឲ្យបងស្តាប់បន្តិចមើល។*

*មុនដំបូងអាខ្វាក់អាខ្វិនហ្នឹងនៅជាមួយម្ចាស់ស្រី តែពិបាករស់នៅជាមួយ ព្រោះម្ចាស់កាចពេក ដូច្នោះអាខ្វាក់និយាយទៅកាន់អាខ្វិនថា៖ "អាខ្វិនអើយ យើងនៅទៀតមិនបានទេ យើងរត់ចេញទៅ។"*

*ដល់ពេលព្រលប់ អាខ្វាក់អាខ្វិនយកប្រវាមកអុំទូកឆ្លងទៅត្រើយម្ខាងដើម្បីរត់។ ដល់អុំទៅមួយសន្ទុះធំ អាខ្វិនថា៖ "វើយជិតដល់ស្រុកគេហើយ!"*

*តាមពិតពីរនាក់អាខ្វាក់អាខ្វិនហ្នឹងវាចែវទូកបញ្ច្រាសគ្នា ហើយចេះតែស្រម៉ៃថាបានដល់ស្រុកគេហើយ។ ដល់ភ្លឺទៅអាខ្វិនឃើញស្រីៗកំពុងតែចុះងូតទឹកនៅក្នុងកំពង់អាខ្វិនថា៖ "យីអាខ្វាក់កន្លែងនេះដូចជាកំពង់ទឹកយើងដដែល យើងអុំមួយយប់ហើយ តែដូចជានៅមួយកន្លែង មកពីយើងអត់ស្រាយខ្សែផង!"*

*ស្រាប់តែម្ចាស់វាមកស្រែកថា៖ "អាពីរនាក់ហ្នឹងមកធ្វើអីនៅកំពង់ទឹកហ្នឹង។ ចុះឯងធ្វើការរួចរាល់ហើយឬនៅ?"*

*អាខ្វាក់អាខ្វិនឆ្លើយ៖ "បាទជិតរួចហើយ!"*

---

*9 ភូមិហនុមាណខាងត្បូង ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ*

អាខ្វិនវាយកខោអាវអីមកបោក រួចវាងាកមើលម្ចាស់វា។ ម្ចាស់អាខ្វាក់អាខ្វិនហ្នឹងមានកូនមួយ កូននឹង ប៉ិនយំណាស់ ហើយម្ចាស់ហ្នឹងបានឲ្យអាខ្វាក់អាខ្វិនបុកស្រូវ។ អាខ្វិនបុកមិនកើតវាយក ចង្អេរទៅនទាលដូច កន្ត្រែប។ ចំណែកឯកូននោះចេះតែយំ អាខ្វិនបំពេរកូននោះថា៖ "កូនអើយដេកទៅកុំយំអី។!"

ប៉ុន្មានថ្ងៃក្រោយមក វាគិតរកល្បិចលួចរត់ម្តងទៀត ម្តងនេះវាអៀវគ្នារត់។

ម្ចាស់វាបាត់អាខ្វាក់អាខ្វិនមិនឃើញក៏ដើររក តែរកមិនឃើញទេ។ អាខ្វាក់អាខ្វិនដើរទៅៗ ក៏ទៅជួបតា ចាស់រកឃ្មុំម្នាក់ វាធុំក្លិនឃ្មុំ អាខ្វិនថា៖ "អូយ! អាខ្វាក់មានអ្នកយកឃ្មុំមកហើយ! តោះយើងទៅសុំគេស៊ី!"

អាខ្វាក់អាខ្វិន វាអត់ដឹងតាចាស់អី វាស្រែកថា៖ "ហ្អើយ ឯងមានឃ្មុំទេ អញសុំស៊ីផង?"

ស្រាប់តែតាហ្នឹងថា៖ "ចុមអានេះអត់ដឹងចាស់ទេតើ!"

តាហ្នឹងខឹងក៏ជុះអាចម៍ដាក់ក្នុងបំពង់រួចឲ្យអាខ្វាក់អាខ្វិនហ្នឹងទៅ។ ហើយវាទាំងពីរនាក់ក៏ចេះតែដើរទៅៗ ចេញពីព្រៃទៅដល់វាលស្រែ អាខ្វិនក៏ឃើញពេងចាំស្រែមួយ។ អាខ្វាក់ថា៖ "អើមានអីខ្លះវើយ?"

អាខ្វិនថា៖ "មានចង្អេរ ខ្សែពួរ រនាស់ អណ្តើក និងឆ្នាំង។"

អាខ្វាក់ថា៖ "អញ្ចឹងប្រមូលយកទាំងអស់ហ្នឹងមក។"

អាខ្វិនក៏យកតាមអាខ្វាក់ប្រាប់ រួចនាំគ្នាដើរមុខទៀត។ អាខ្វាក់ឃ្លានបាយណាស់ វាថា៖ "អើ! ឈប់ស៊ី បាយសិនទៅ យើងឃ្លានបាយណាស់។"

អាខ្វាក់ថា៖ "អើ! ចាំដល់កន្លែងម្លប់សិន!"

ពេលដល់កន្លែងម្លប់ហើយ វាទាំងពីរនាក់ក៏ឈប់ហើយស្រាយបាយមកស៊ី ស្រាប់តែធុំក្លិនស្អុយ វាក៏

ដើរទៅមុខរកកន្លែងទៀត។ កន្លែងនោះធំក្លិនស្អុយជាងកន្លែងមុនទៀត។ ពួកវាក៏ដើរទៅរកកន្លែងមួយទៀត។ នៅជិតនោះមានត្រពាំងឈូកមួយ។ អាខ្វាក់ប្រាប់អាខ្វិនឲ្យមើល៖ "ឯងបើកមើលឲ្យអស់មើល មានអីក្នុងហ្នឹងក៏ស្អុយម្ល៉េះ?"

អាខ្វិនមើល វាឃើញសុទ្ធតែអាចម៍និងទឹកនោម ហើយវានាំគ្នាក្អួតទាំងអស់គ្នាទៅ។

"អើចុះយើងបានអីស៊ី បើទឹកឃ្មុំស្អុយអស់ទៅហើយ។" អាខ្វាក់សួរ។

"អើមានអណ្ដើកមួយដែរ!" អាខ្វិនថា។

"ទេអាហ្នឹងទុកធ្វើពូជ មិនអាចស៊ីបានទេ យើងស៊ីអីផ្សេងទៅ!" អាខ្វាក់ថា។

អាខ្វិនស៊ីបណ្ដើរ សម្លឹងមើលអណ្ដើកបណ្ដើរ។ ពេលពួកវាស៊ីហើយ ក៏បន្តដំណើរតទៅទៀត។ មកដល់ក្បែរទឹកជ្រោះ អាខ្វិនឃើញស្រីកំពុងតែងូតទឹក ក៏សូត្រកំណាព្យឌឺដងដាក់នាងនោះ ព្រោះមើលទៅ នាងស្អាតគួរឲ្យចាប់ចិត្តស្រលាញ់ដែរ។

ស្រីនោះប្រាប់ថា៖ "កុំនៅទីនេះអីប្រយ័ត្នខ្លាវាមកស៊ី។"

អាខ្វាក់ថា៖ "ទៅខ្លាចអីខ្លា!"

លុះដើរមកដល់ភូមិមួយ ក្នុងភូមិនេះតែងមានខ្លាចូលកស៊ីអ្នកស្រុក។ អ្នកស្រុកនាំគ្នាឡើងលើផ្ទះអស់ ព្រោះខ្លាចខ្លាស៊ី។ វាទាំងពីរនាក់ដើរសួរគេ តែគ្មាននរណាឆ្លើយប្រាប់ថាមានហេតុអីទេ។ ដើរៗទៅ ស្រាប់តែទៅជួបនឹងក្មេងកំពុងតែយំ អាខ្វិនថា៖ "យើងមានសង្ឃឹមហើយ!"

ពេលដើរទៅជិតដល់ ម្ដាយវាលើកចូលក្នុងផ្ទះបាត់ វាអស់សង្ឃឹមក៏ដើរទៅមុខទៀត។ វាខ្វិនថា៖ "នែ!

យើងរកមើលមើល៍ ក្រែងមានសល់គោទុកខ្លួរស្រែ!"

ពីរនាក់នោះក៏នាំគ្នាដើរទៅមុខទៀត ដើរៗទៅ ឃើញមានក្រោលគោមួយ អាខ្វាក់ក៏ដាក់អាខ្វិនចុះ ហើយអាខ្វាក់ដើរទៅស្ទាបប៉ះចំក្រោលគោ វាស្ទាបៗទៅប៉ះចំក្បាលគោ វាថា៖ "ជានេះស្គមណាស់!"

ដល់អាខ្វាក់ស្ទាបប៉ះចំគូថគោវាថា៖ "អានេះស្វិតណាស់!"

វាក៏ស្ទាបបន្តទៀត ប៉ះចំខ្វា វាថា៖ "អូអានេះធំល្អ មាំល្អ ហើយអត់មានស្នែងទៀត!"

ហើយវាស្រែកប្រាប់អាខ្វិនថា៖ "អេ! ឯងយកកន្ទុះមកឲ្យអញៗខ្ទុះវាទុក វាអត់ដឹងថាខ្វា វាស្មានតែគោ។ អាខ្វិនវាទៅខ្សឹបស្រាប់អាខ្វាក់ថា៖ "មិនមែនគោទេ គឺខ្វាទេ!"

អាខ្វាក់វាថា៖ "ខ្វាចអីខ្វាចខ្វា ឃ្មេមិនខ្វាចផងទៅខ្វាចអីខ្វា ទៅខ្វាចអី យកតែកន្ទុះមកឲ្យអញ អញខ្ទុះវា។ ពេលដាក់ខ្ទុះវាទៅ វាឈឺក៏រត់បាត់ទៅ ហើយអាខ្វាក់ថា៖ "យីស្ដាយអានុបកូនក្រោលណាស់វ៉ី!"។

និយាយពីភូមិមួយទៀតតែងមានយក្សមកស៊ីមនុស្សម្ដងម្នាក់ៗជារៀងរាល់ថ្ងៃ។ ថ្ងៃនេះប៉ះចំវេណកូនក្រមុំសេដ្ឋី គេយកនាងនោះទៅដាក់នៅក្នុងស្គររងចាំឲ្យយក្សស៊ី។

បន្ទាប់ពីដេញខ្វាហើយ អាខ្វាក់អាខ្វិនក៏ដើរទៅមុខទៀត។ ដើរៗទៅ ក៏ប្រទះនឹងថ្មប្រាសាទមួយយ៉ាងធំ អាខ្វិនបញ្ជាឲ្យអាខ្វាក់ឡើងលើថ្មនោះ។ លុះឡើងលើថ្មហើយ អាខ្វិនងាកទៅក្រោម ស្រាប់តែឃើញប្រាសាទអង្គរហើយវាអួតប្រាប់អាខ្វាក់ថា៖ "អូអាខ្វាក់អើយបើឯងភ្នែកភ្លឺ បែបឃើញស្អាតណាស់ណា ស្អាតអត់ខ្ចោះ"

"ឃើញអី ហ្អា?" អាខ្វាក់សួរ។

"នោះប្រាសាទអង្គរវត្តឡើងចាំងភ្លូក!" អាខ្វិនតប។

អាខ្វាក់ថា៖ "ហ្អែងអួតអញទេដឹង?"

"អួតអី មែនតើ!" អាខ្វិនតបៗ

ដល់និយាយហើយ ក៏ធ្វើដំណើរទៅទៀត ឆ្លងពីថ្នាក់ខ្លែងប្រាសាទហ្នឹង ដើរៗទៅ ដល់កន្លែងសំណាក់យក្សៗ ហើយយក្សហ្នឹងទាល់តែយប់បានមក អាខ្វិនឃើញផ្ទះសំណាក់នេះវាប្រាប់អាខ្វាក់ថា៖ "អញ្ចេះអើអាខ្វាក់អើយ! មានសំណាក់មួយ យើងចូលឬអត់? ក្រែងលោមានអីស៊ីណា!"

អាខ្វាក់ថា៖" អើចូលទៅ!"

អញ្ចឹងក៏នាំគ្នាបើកទ្វារដើរចូលទៅ ហើយអាខ្វិនលាន់មាត់ថា៖ "អូយមានមាសកែវកងច្រើនណាស់!!"

ស្រាប់តែអាខ្វាក់ថា៖ "មានអីប្រមូលឲ្យអស់មកៗ!!"

អាខ្វិនក៏យកបង្វិចវាមកប្រមូលប្រកដាក់ឡើងពេញថង់ៗ កំពុងរៀបៗ អាខ្វិនហ្នឹងឃើញស្គរ ស្រាប់តែវាយកស្គរនោះមកទូងលេង ទូងរហូតដល់ស្រីនៅក្នុងស្គរហ្នឹងថា៖ "បានហើយ! ដំប៉ុណ្ណឹងបានហើយ ខ្ញុំថ្ងង់ណាស់!"

អាខ្វិនហ្នឹងក៏ឈប់ដំ ហើយឆ្ងល់៖ "ចុម! សម្លេងអីគេ??"

លើកទីមួយដំតិចៗទេ លើកចុងក្រោយដំខ្លាំង ផូសៗ! នាងស្រីនោះក៏ថាម្ដងទៀត៖ "បានហើយឈប់ដំខ្ញុំថ្ងង់ណាស់!!"

ស្រាប់តែអាខ្វិនវាព្រួ វាទម្លាក់ដំបងសម្រាប់ទូងស្គរចោលហើយថា៖ "អាខ្វាក់អើយ! ខ្មោច! អាខ្វាក់! ខ្មោចក្នុងស្គរ!"

លុះអាខ្វាក់ស្ដាប់ឮថាជាសម្លេងមនុស្សស្រី វាដើរស្ទាបចុះស្ទាបឡើង ប៉ះចំកន្ទែងសម្រាប់បើកស្គរ ហើយទៅវាបើកគម្របស្គរទៅ ប៉ះស្រី វាស្ទាបទៅសក់អន្ទាយ ហើយអាខ្វាក់ហ្នឹងថា៖ "ចុះអ្នកនាងមកកន្ទែងហ្នឹងធ្វើអី?"

"គេយកខ្ញុំទុកឲ្យយក្សស៊ី!!" នាងនោះតប។

"ហើយយក្សហ្នឹង វាមកថ្មើរណា?" អាខ្វាក់សួរ។

"វាមកពេលយប់!" នាងតប។

អាខ្វាក់ថា៖ "នាងកុំភ័យ អញ្ចឹងទុកខ្ញុំកាប់វា!"

ថាហើយអាខ្វាក់ប្រើអាខ្វិនហ្នឹងទៅយកកាំបិត។ អាខ្វាក់ស្ទាបកាំបិតទៅលាន់មាត់ថា៖ "ហឺ អាហ្នឹងតូចណាស់!"

ស្រាប់តែអាខ្វាក់ប្រើឲ្យនាងនោះទៅយកកាំបិតវិញម្ដង។ នាងនោះយកកាំបិតអាធំជាងគេមកតែម្ដង។ យកកាំបិតមកទុកហើយ អាខ្វាក់បញ្ជានាងនោះទៀតថា៖ "ទៅយកផ្លែឈើមកឲ្យយើងស៊ីឲ្យឆ្អែតសិន យើងនឹងសម្លាប់យក្សនោះចោល!"

ស៊ីផ្លែឈើមិនទាន់អស់មួយផង អាខ្វាក់ប្រើនាងនោះទៀត៖ "ទៅបិទបង្អួច បិទទ្វារបិទឲ្យជិត!"

អាខ្វាក់អាខ្វិនកំពុងតែស៊ីនំ យក្សក៏មកដល់។ នាងនោះឃើញយក្សមកក៏ស្រែកថា៖ "អូយ! យក្សមកហើយ!"

គ្រាន់តែឮ អាខ្វិននេះញ័រទទ្រើតចូលក្នុងក្រណាត់បាត់ទៅ។ អាខ្វាក់វិញមិនខ្លាចអីទាំងអស់ ហើយស្រែក

ថា៖ "អញវ៉ើយ!!"

យក្សសួរវិញថា៖ "ហ្អែងហ្នឹងនរណាគេ?"

"អញម្ចាស់ផ្ទះហ្នឹង?" អាខ្វាក់តប។

អាខ្វាក់សួរ ៖"ចុះហ្អែងជាអ្នកណា?"

"អញយក្ស ហ្អែងអត់ខ្លាចអញទេហ្អី?

"អញអត់ខ្លាចហ្អែងទេ" អាខ្វាក់តបដោយក្លាហាន។

យក្ស ៖ "បើហ្អែងអត់ខ្លាចអញទេ ចៃពោះវៀនហ្អែងប៉ុនណា?" ស្រាប់តែអាខ្វាក់យកអណ្ដើកដែលវារើសបានគប់បង្ហាញយក្ស។

យក្សលាន់មាត់ថា៖ "ចុម! ចៃវាធំណាស់តើ! អញ្ចឹងបានជាវាមិនខ្លាចអញ!"

"ចុះពោះវៀនហ្អែងប៉ុនណាដែរ បានហ្អែងអត់ខ្លាចអញ?" យក្សឆ្ងល់ក៏សួរបន្តទៀត។

ស្រាប់តែអាខ្វាក់បោះខ្សែព្ួរទៅយក្ស។ យក្សឃើញ ក៏លាន់មាត់ថា៖ "ចុម! វាធំជាងអញទៅទៀត! អួយអញខ្លាចវាណាស់!"

គិតហើយស្រាប់តែយក្សហ្នឹងគ្រញ៉ែងខ្លួន ហើយដើរចូលមកសំដៅរកអាខ្វាក់អាខ្វិនដែលនៅក្នុងផ្ទះ។ អាខ្វាក់កាន់កាំបិតធំហ្នឹងរួចហើយ ស្រាប់តែយក្សបើកទ្វារមក អាខ្វាក់កាប់មួយកាំបិតតែកាប់ខុស។ លុះយក្សបើកទ្វារម្ដងទៀត វាអើតកទៅ អាខ្វាក់ក៏កាប់មួយកាំបិតដាច់ក ហើយខ្វាតឈាមឡើងពេញខ្លួនវា ហើយស្រែកប្រាប់អាខ្វិនថា៖ "អាខ្វិនមកនេះ មើលយក្សងាប់ហើយឬនៅ?"

អាខ្វិនថា៖ "អញអត់ហ៊ានចេញទេ អញខ្លាចយក្សណាស់!"

ថាហើយអាខ្វិនរឹតតែលោតចូលក្នុងស្គរទៀតៗ អាខ្វាក់ថា៖ "ហើយចុះហ្អែងទៅខ្លាចអីយក្សធ្វើអី? ហ្អែងសាកចេញមកមើលមួយភ្លែតមើល!"

អាខ្វិនក៏ដាច់ចិត្តអើតចេញមកមើល មើលទៅឃើញយក្សដាច់កសល់តែឈាមហើយថា៖ "អាខ្វាក់អើយយក្សងាប់ហើយអាខ្វាក់!!

អាខ្វាក់សួរបញ្ជាក់៖ "យក្សងាប់មែន?"

"យក្សងាប់មែន អាខ្វាក់!"

នាងនោះដោយសារភ័យស្ទន់ស្មោពេក ក៏សន្លប់មិនទាន់ដឹងខ្លួនទេៗ ពេលអាខ្វិនងាកទៅឃើញនាងនោះដេកសន្លប់នៅឡើយ វាប្រាប់ទៅអាខ្វាក់ថា៖ "អាខ្វាក់អើយងាប់ហើយ!"

អាខ្វាក់សួរថា៖ "ងាប់អីហ្អាក?"

"នាងហ្នឹងបែបងាប់ហើយ" អាខ្វិនតបៗ ឮថាងាប់ អាខ្វាក់ក៏យកត្រចៀកហ្នឹងទៅស្ដាប់នៅទ្រូងនាងនោះឮនាងនោះនៅដកដង្ហើមក៏ថា៖ "នាងមិនទាន់ស្លាប់ឯណា!"

មិនទាន់ស្លាប់អញ្ចឹងទៅ អាខ្វិនថា៖ "អញមានមធ្យោបាយមួយ!"

"មធ្យោបាយអី?" អាខ្វាក់សួរៗ ស្រាប់តែអាខ្វិនស្ទុះទៅទាំកែងជើងនាងនោះៗ នាងនោះក៏ដឹងខ្លួនហើយថា៖ "អ្នកជួយខ្ញុំបានផុតពីយក្សហ្នឹង ខ្ញុំអរណាស់ ខ្ញុំនឹងឲ្យមាសប្រាក់កែវកងទាំងអស់ទៅអ្នក!" អាខ្វាក់ឮដូចនោះវាអរណាស់លើកពរអាខ្វិនជាច្រើនលើកច្រើនសារដោយមិនដឹងខ្លួនៗ

ក្រោយបានមាសប្រាក់ហើយ អាខ្វាក់អាខ្វិនធ្វើដំណើរបន្តទៀត។ ដើរៗទៅ ទៅដល់ដើមក្រសាំងមួយ វាក៏បបួលគ្នាចែកមាស ប្រាក់។ អាខ្វាក់ហេតុតែមើលមិនឃើញ អាខ្វិនខូចវាចង់បានទាំងអស់ត្បិតអីវាមើលឃើញមាសប្រាក់ច្រើន។ វាក៏ស្រាយមាសចេញមក ហើយចែកដាក់មាសព្រេជអីនៅមុខវា ឯផ្លែឈើក្រណាត់អីដាក់មុខអាខ្វាក់។ លុះចែកដូចនេះហើយ អាខ្វិនសួរទៅអាខ្វាក់ថា៖ "អាខ្វាក់ មុខហ្អែងមុខអញ ហ្អែងយកមួយណា?"

អាខ្វាក់ថា៖ "អញយកមុខហ្អែង!"

អាខ្វិនថា៖ "យីហ្អែងនិយាយលេងឬមែន?"

"អញនិយាយមែនណា" អាខ្វាក់បញ្ជាក់។

ស្រាប់តែអាខ្វិនបង្វែរមាសដាក់មុខអាខ្វាក់ ហើយយកផ្លែឈើអីដាក់មុខអាខ្វិនវិញ ហើយអាខ្វិនសួរអាខ្វាក់ម្ដងទៀត៖ "មុខអញ មុខហ្អែងយកអាណា?"

អាខ្វាក់ឆ្លើយ៖ "អញយកមុខអញ!"

អាខ្វិនថា៖ "ហីអានេះ ម្ដងយកមុខអញ ម្ដងយកមុខវា!"

និយាយប្រកែកឈ្លោះគ្នាចុះឡើងៗ ស្រាប់តែផ្លែក្រសាំងទុំធ្លាក់ចុះចំក្បាលអាខ្វាក់គឹស។ អាខ្វាក់ថា៖ "យីអានេះវើយ! ឈ្លោះគ្នាតែមាត់បានហើយ ចាំបាច់ប្រើកម្លាំងអី!"

ស្រាប់តែខ្វិនតបថា៖ "អញមានបានវាយហ្អែងឯណា?"

អាខ្វាក់ខឹងពេកស្ទុះទៅចាប់ជើងអាខ្វិនគ្រវី ឯអាខ្វិនវិញដាក់មួយដៃចំភ្នែកម្ខាងរបស់អាខ្វាក់។ ស្រាប់

តែភ្នែកអាខ្វាក់ភ្លឺព្រឹមៗ វាក៏ប្រាប់ទៅអាខ្វិនថា៖ "អូអាខ្វិនហ្អែងដាក់ភ្នែកអញមិញ ឥឡូវអញមើលឃើញវិញ ហើយអញ្ចឹងហ្អែងដាក់អញម្ខាងទៀតមក!"

ពេលមើលឃើញជើងអាខ្វិន អាខ្វាក់សួរថា៖ "ចុមអាខ្វិន ជើងហ្អែងជាវិញ? ជើងហ្អែងជាវិញហើយ?"

អាខ្វិនថា៖ "ឥឡូវអញជាល់ភ្នែកហ្អែង ហ្អែងទាញជើងអញទៅ!"

ស្រាប់តែអាខ្វិនដាក់ភ្នែកអាខ្វាក់មួយដៃ ហើយអាខ្វាក់ទាញជើងអាខ្វិនដាក់គុម្ពជើងប្រាំងវិញ។ អាខ្វាក់អាខ្វិននោះបានជាដៃជាជើងហើយអរណាស់ ក៏ប្រលែងគ្នាលើកៀនជើងប្រាំង ហើយមាសដែលបានមកហ្នឹងចែកគ្នាម្នាក់ៗបន្តិចអញ្ចឹងទៅ។ រួចក៏នាំគ្នាធ្វើដំណើរទៅមុខទៀត។

និយាយពីនាងកូនសេដ្ឋីបានរួចពីសេចក្ដីស្លាប់ហើយ នាងក៏ត្រលប់មកផ្ទះវិញ ហើយក៏បញ្ជាអាមាត្យឲ្យដើរទូងស្គរប្រកូកប្រកាសរកអ្នកដែលបានជួយនាង។ អាមាត្យម្នាក់វាយស្គរបណ្ដើរហើយប្រកាសថា៖ "ខ្ញុំសូមប្រកាសថា អ្នកណាឈ្មោះអាខ្វាក់អាខ្វិន បានជួយកូនសេដ្ឋី លោកសេដ្ឋីប្រកាសឲ្យរក!"

ឮដូចនោះ អាខ្វិនកំពុងតែដើរនៅក្បែរនោះ ក៏តបថា៖ "ខ្ញុំនឹងហើយ!"

តែអាខ្វាក់ប្រាប់ថា៖ "ឃើអានេះហ្អែងចង់ងាប់មែនឬ! អាខ្វិនអង្គុយវិញមក!"

អាមាត្យនោះថា៖ "ហី ហ្អែងដឹងទេ អាណាករលោកសេដ្ឋី នឹងមានទោសធ្ងន់ណាស់!"

អាខ្វាក់អាខ្វិនតបថា៖ "ចុះបើខ្ញុំខ្វាក់ខ្វិនមែន!"

អាមាត្យនោះថា៖ "ចុះបើហ្អែងខ្វាក់ខ្វិន ម៉េចភ្នែកហ្អែងភ្លឺ ជើងហ្អែងដើររួច?"

"ព្រោះអីខ្ញុំជួយនាងបានពេលនោះខ្ញុំខ្វាក់ភ្នែក នាងចែកទ្រព្យសម្បត្តិឲ្យខ្ញុំ ចែកគ្នាទុកចាយ !" អាខ្វាក់

អាខ្វិនតប។

អាមាត្យសួរបន្ថែម៖ "ចុះហ្អែងមានកស្តុតាងអីមកបង្ហាញ?"

អាខ្វាក់អាខ្វិនចង្អុលបង្ហាញ៖ "នេះមាសប្រាក់ដែលនាងឲ្យមកខ្ញុំ។"

អាមាត្យសង្ស័យ៖ "អញអត់ជឿហ្អែងទេ!"

អាខ្វាក់ហ្នឹងនិយាយថា៖ "បើលោកអត់ជឿខ្ញុំ ខ្ញុំនិយាយក៏បាន កាលនៅកន្លែងដើមក្រសាំងចែកមាសគ្នាហ្នឹង ផ្លែក្រសាំងទុំមួយធ្លាក់មកចំក្បាលខ្ញុំ ដោយសារមានការយល់ច្រលំគ្នា ក៏វាយគ្នាទៅ រហូតដល់ភ្នែកខ្ញុំភ្លឺ ហើយជើងអាខ្វិនក៏ដើរបាន។"

និយាយហើយ អាមាត្យក៏នាំពីរនាក់ហ្នឹងទៅផ្ទះសេដ្ឋី ដោយតុបតែងមាសប្រាក់ ស្លៀកពាក់ខោអាវស្អាតៗឲ្យ។ ពេលទៅដល់ លោកសេដ្ឋីក៏លើកកូនស្រីឲ្យរៀបការជាមួយអាខ្វាក់ទៅ។ ចំណែកអាខ្វិននោះវិញ វាត្រឡប់រកនាងក្រមុំដែលមានផ្ទះនៅជិតទឹកជ្រោះនោះ ហើយក៏រៀបការជាមួយនាងនោះទៅ។

អាខ្វាក់អាខ្វិននិងប្រពន្ធទាំងពីរនាក់ក៏រស់នៅជាមួយគ្នាយ៉ាងសុខសាន្តទៅ។

# ៩- រឿងទន្សាយ និងសីហៈ

## និទានដោយលោក កែវ សុខា ហៅ ម៉ៃ [10]

កាលពីព្រេងនាយមានសត្វសីហៈមួយតែងតែដើរចាប់សត្វទាំងអស់មកធ្វើជាចំណី។ សត្វសីហៈនោះឈ្មោះបឹងគន្ធាក់។ វាដើរពាតត្បាតសម្លាប់ស៊ីគ្រប់សត្វទាំងអស់ ធ្វើឲ្យសត្វក្នុងព្រៃស្ទើរតែហិនហោចអស់។ ដូច្នេះសត្វដទៃក៏ធ្វើការប្រជុំមួយឡើង ដោយសម្រេចថាហ្នឹងដាក់វេណគ្នា មួយថ្ងៃមួយៗទៅឲ្យសត្វសីហៈហ្នឹងវាស៊ី។

ដល់ថ្ងៃមួយ មានទន្សាយមួយដើរទៅព្រៃបានឃើញអណ្ដូងមួយ វាឈ្ងោកមើលអណ្ដូងនោះបានឃើញស្រមោលខ្លួនវា ស្រមោលនេះវាធ្វើកាយវិការយ៉ាងម៉េច គឺវាធ្វើតាមទាំងអស់។ ថ្ងៃនេះគឺដល់វេណទន្សាយត្រូវទៅឲ្យសត្វសីហៈស៊ី តែវាមិនទៅពីព្រលឹមទេ ឧទាហរណ៍ថាម៉ោង៧ត្រូវទៅអញ្ចឹង តែវាអត់ទៅទេថ្មើហ្នឹងគឺចាំរហូតដល់ម៉ោង១០ឬ១១ គឺទុកឲ្យសត្វសីហៈហ្នឹងហេវខ្លាំង។

នេះបើតាមច្បាប់បុរាណគេថា "គេនិយាយតែមួយបន្តិចឆាប់ខឹង ព្រោះដល់ម៉ោង១១ វាហេវមែនទែន ចាំឲ្យតែមកដល់ចាំ តែគ្រឹបតែម្ដង។"

ចំណែកឯទន្សាយ ពេលមកដល់ធ្វើអាការៈ ទ្រោមៗ ធ្វើជាខ្លាច គោរពឱនលំទោន ហើយនិយាយថា៖"ខ្ញុំចង់មកពីព្រលឹមដែរ តែមានសីហៈមួយទៀតនៅក្នុងព្រៃឃាត់មិនឲ្យខ្ញុំមកទេ ព្រោះគេថាបងឯងមិនមាន

---

10 ភូមិហនុមាណខាងត្បូង ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

ឥទ្ធិពលអីទេ មិនមែនធំអីតែឯងនោះទេ គឺមានគេធំជាងនេះទៅទៀត។

សីហៈឮដូច្នេះ ក៏សួរទៅទន្សាយថា៖ "សីហៈនោះនៅឯណា ឈ្មោះអី?"

សីហៈនោះវាខឹងព្រោះដល់ពេលហៅផង។

ទន្សាយប្រាប់ថា៖ "វានៅក្នុងព្រៃ!"

សីហៈថា ៖ "អញ្ចឹងឯងនាំអញទៅជួបវា!"

ទន្សាយក៏នាំសីហៈទៅ។ ពេលទៅដល់ សីហៈក៏សួរថា៖ "វានៅឯណា?"

ទន្សាយតប៖ "នៅក្នុងអណ្ដូងហ្នឹង!"

ដល់ទៅមើលជិតអណ្ដូងអត់ឃើញ តែដល់សីហៈឈ្ងោកមុខទៅក្នុងអណ្ដូងបានឃើញមានសីហៈមួយទៀតនៅក្នុងអណ្ដូង។ ពេលឈ្ងោកមុខទៅ សីហៈឃើញស្រមោលខ្លួនវា ក៏គិតថាអាស្រមោលនោះជាសីហៈផ្សេងទៀតដែលឈ្ងោកមកវិញ។ ដល់ពេលវាស្រែកទៅ ស្រមោលសីហៈនៅក្នុងអណ្ដូងក៏ស្រែកតបវិញ។ អានោះធ្វើម៉េច! វាធ្វើដូចអញ្ចឹងដែរ! សីហៈខឹងខ្លាំងពេក ក៏លោតចូលអណ្ដូងភ្លក់ ហើយអណ្ដូងនោះមានទឹកស្រាប់ផង សីហៈនោះលោតចូលទៅក៏ជាប់នៅក្នុងហ្នឹងទៅ៕

# ១០- រឿងអាចឹកឡូវខែវ

## និទានដោយ លោកតា សៅ វណ្ណី [១]

ខ្ញុំចូលចិត្តរឿងដែរ តែទាល់មកសួរអញ្ចឹងទៅ ដូចជារកនឹកមិនឃើញទេ! ខ្ញុំមានរឿងកំប្លែងច្រើនដែរ តែដល់ចាស់ទៅខ្ញុំនិយាយតែពីរឿងធម៌អាថ៌វិញៗ រឿងអាចឹកឡូវខែវនេះ តាពិនទិនតាកេនក៏ធ្លាប់បានយកទៅឲ្យគេបោះពុម្ពនៅក្នុង កម្ពុជសូរិយារួចហើយដែរៗ

រឿងនេះនិទានថា ជនជ្ញាឡូវនៅឃុំវាលពន្ធមានប្រពន្ធមួយឈ្មោះសារិកាកែវៗ ដំបូងគាត់រកស៊ីដើររែកនំអាកោរលក់ៗ បន្តិចមកគាត់ក៏រកស៊ីលក់នំគុយទាវម្ដងៗ របរនេះកាក់កបមានដើមទុនហើយគាត់ក៏បែកគំនិតមករកស៊ីរបៀបស្រុកស្រែគឺទិញអង្ករ ទិញស្រូវពីអ្នកស្រុកមកលក់ របហូតធ្វើឲ្យគាត់មានជីវភាពធូរធារខ្លាំងណាស់ៗ ចឹកឡូវមាននៅសល់លុយសុទ្ធតែប្រាក់រៀលធំៗ មួយរៀលៗ និង ប្រាក់ណែនជាច្រើនទៀតៗ គាត់យកវាទៅកប់ទុកទាំងអស់ៗ

ប្រពន្ធចឹកឡូវហ្នឹងក្មេង ឯចឹកឡូវហ្នឹងរាងចាស់បន្តិចៗ លុះបានកូនមួយពីរ ថ្ងៃមួយនាងជាប្រពន្ធអាយុប្រហែល៤០ក៏ស្លាប់ទៅៗ លុះប្រពន្ធស្លាប់ដូច្នេះ គាត់មានចិត្តអាឡោះអាល័យប្រពន្ធហ្នឹងជាខ្លាំង ពីព្រោះប្រពន្ធគាត់ហ្នឹងធ្លាប់កម្សត់កម្រណាស់ រកស៊ីមានបានមកហើយមិនទាន់បានចាស់ប៉ុន្មានផងក៏ស្លាប់ចោលគាត់ទៅៗ អញ្ចឹងគាត់ក៏ឲ្យលោកគ្រូវត្តទៅផ្ទះរបស់គាត់ ដើម្បីធ្វើបុណ្យបង្សុកូលសង្ឃាយនាបីយប់បីថ្ងៃតាមរបៀបខ្មែរ

---

១ អាយុ ៨២ ឆ្នាំ នៅភូមិវត្តពោធិ៍ ឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ

យើង។ អ្នកស្រុកក៏ជួយទំនុកបំរុងពិធីរហូត ដល់បញ្ចុះសពអីរួចហើយ ទើបចឹកឡូវខែវនិមន្តលោកទៅបង្សុកូលបញ្ចប់នៅកន្លែងម៉ុងឲ្យប្រពន្ធ។ ចឹកឡូវបានយកប្រាក់សុទ្ធរាងមូលៗ ជាប្រាក់មួយរៀលៗសម័យឆ្នាំ ១៩៤០ មួយតៅដាក់នៅពីមុខផ្នូរ។

លោកគ្រូសង្ឃរាជវត្តទី១ ក៏និមន្តមកដល់។ ពេលមកដល់ចឹកឡូវបញ្ជាក់ថា៖ "លោកគ្រូបង្សុកូលឲ្យដល់ប្រពន្ធខ្ញុំករុណា បើដល់ប្រគេនលុយមួយតៅ បើមិនដល់ទេ ករុណាប្រគេនតែមួយរៀលទេ!"

លោកគ្រូសង្ឃរាជក៏ចាប់ផ្តើមសូត្រ។ ពេលសូត្រ លោកសូត្រដូចយើងសូត្ររាល់ថ្ងៃអញ្ចឹង គឺអនិច្ចា វដ្តសង្ខារ....។ ចឹកឡូវខែវខំស្តាប់ធម៌លោកសូត្រតែមិនឮសូត្រឈ្មោះប្រពន្ធគាត់សោះ។ លុះសូត្រចប់ចឹកឡូវតបថា៖ "មិនដល់ប្រពន្ធខ្ញុំទេលោកគ្រូ!"

ដល់អញ្ចឹងទៅចឹកឡូវក៏លែងអោយប្រាក់មួយតៅនោះ ហើយដកតែមួយរៀលប្រាក់សុទ្ធនោះអោយទៅព្រះសង្ឃរាជអង្គនោះ រួចក៏និមន្តទៅ។ លោកសង្ឃអង្គវត្តផ្សេងមកពី៥វត្តទៀតក៏សូត្រដូចអង្គទី១គ្រប់តែអង្គ។ ចឹកឡូវខែវក៏ប្រគេនតែប្រាក់មួយរៀលគ្រប់ៗតែអង្គ។ លុះដល់អង្គទី៧ ប្រហែលទ្រង់ចាស់បន្តិចផង ពេលនិមន្តមកដល់លោកគិតថា៖ "យី! លោក៦វត្តហើយ យកលុយមួយតៅហ្នឹងអត់បាន អញគិតបង្សុកូលយ៉ាងម៉េចឲ្យដល់?"

បន្តិចក្រោយមក លោកអង្គនេះក៏នឹកឃើញថា៖ "យី! ប្រពន្ធវាឈ្មោះមីសារិកាកែវ អាចិនហ្នឹងឈ្មោះអាចឹកឡូវ។"

លុះលោកនិមន្តមក ដល់ហៅសួររកចឹកឡូវខែវ៖ "ឯណាអាចឹក! អ្ហែងមកចាំស្តាប់អញ អញនឹងបង្សុ

កូលឲ្យដល់ ចាំស្ដាប់ណា!"

"ករុណាលោកគ្រូៗ! បើបង្សុកូលឲ្យដល់មែន ករុណានឹងប្រគេនលុយមួយតៅហ្នឹងដល់តេជគុណ!" ចឹកឡូវតបៗ

លោកក៏សូត្រ៖ "អនិច្ចា វដ្ដមីសារិកាកែវ បង្សុកូលអោយអាចឹកឡូវខែវ រូបសមោ សុខោ រួចហើយក៏តទៅអនិច្ចា វដ្ដសង្ខារ .... រហូតដល់ចប់ទៅៗ"

ចឹកឡូវខែវស្ដាប់ហើយក៏ថា៖ "អើត្រូវហើយលោកគ្រូ អើ សូត្រអញ្ចឹងដល់ហើយ!"

ព្រះសង្ឃអង្គនេះក៏បានលុយមួយតៅហ្នឹងទៅៗ

# ១១- រឿងមនុស្សពាល

## និទានដោយលោកតា ស៊ុំ សារុំ[11]

ដូចជាមានរឿងមួយទៀត រឿងមនុស្សពាលជាបោកប្រាសលោក។ ថ្ងៃមួយហ្នឹងមនុស្សពាលទៅវត្ត ប្រាប់លោកថា៖ "ខ្ញុំករុណាធ្វើបុណ្យបង្សុកូលរៀបបន្ទុងនោះណាស់ ពេលរៀបចំសព្វគ្រប់អស់ហើយនៅខ្វះតែ ត្រៃចីវរ តើព្រះព្រះតេជគុណចង់បានត្រៃចីវរប្រភេទណា? អញ្ចឹង បើព្រះតេជគុណមិនទើសទាល់អីទេ សូម ព្រះតេជគុណនិមន្តទៅជាមួយករុណា ខ្ញុំករុណាទៅផ្សារទិញក្រណាត់ដើម្បីបំពេញបំណងរបស់ព្រះតេជ គុណ។"

តេជគុណតបថា៖ "អាត្មាខ្វះត្រៃចីវរមួយសម្រាប់ដែរ បើអញ្ចឹងចាំអាត្មាទៅជាមួយញោមចុះ!"

តេជគុណក៏ប្រើក្មេងពីរនាក់ ឲ្យចុះទូកទៅក្នុងទន្លេទៅ។ អញ្ចឹងកូនសិស្សលោកពីរនាក់ជាអ្នកចែវទូក តេជគុណនិងចៅពាលក៏នាំគ្នាចុះទូកទៅ។ លុះចែវទៅដល់ត្រើយខាងលិច ចៅពាលនិងលោកគ្រូចៅអធិការក៏ និមន្តទៅលើមាត់ច្រាំង ទុកឲ្យកូនសិស្សពីរនាក់នៅចាំទូក។ លុះដល់ហាងចៅកែលក់ក្រណាត់ ចៅកែក៏បាន និមន្តលោកឆាន់តែឆាន់អីអញ្ចឹងតាមសមគួរ។ រួចចៅកែហាងហ្នឹងក៏រើសក្រណាត់មើលឲ្យតេជគុណរើស មើល។ រើសៗទៅ លោកប្រទះឃើញក្រណាត់ព្រៃ លោកក៏ពេញចិត្តព្រោះគិតថាអាចសមជាត្រៃចីវរបាន។

ពាលហ្នឹងថា៖ "អញ្ចឹងព្រះតេជគុណមិនអីទេ តែខ្ញុំករុណាខ្វះលុយ អញ្ចឹងព្រះតេជគុណនៅចាំខ្ញុំករុណា

11 ភូមិព្រះម្លប់ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ

ត្រង់ហ្នឹងហើយ ខ្ញុំករុណាទៅភូមិលើដើម្បីទៅខ្ចីលុយពីបងខ្ញុំករុណាសិនទើបគ្រប់!"

អាពាលហ្នឹងមានទៅរកលុយបងវាឯណា វាចុះទៅទូកហើយប្រាប់កូនសិស្សទាំងពីរហ្នឹងថាព្រះតេជគុណឲ្យទៅយកលុយនៅឯកុដិៗ កូនសិស្សពីរនាក់នៅចាំទូកក៏ជឿមែន រួចក៏អុំទូកទៅកុដិលោកវិញដើម្បីយកលុយៗ ដល់កុដិៗលោកហ្នឹង អាពាលហ្នឹងមិនទាន់បាននិយាយអីផង អាកូនសិស្សពីរនាក់ប្រាប់ទៅលោកកាន់សោរកុដិថា៖ "ព្រះតេជគុណឲ្យយកលុយ៥០រៀល!"

លោកនោះស្មានតែតេជគុណឲ្យយកលុយមែន ក៏ចាក់សោរយកលុយ៥០រៀលមកឲ្យថៅពាលហ្នឹងទៅៗ

លុះបានលុយហើយ ថៅពាលចុះមកជិះទូកនាំកូនសិស្សទាំងពីរនាក់នោះមកដល់ត្រើយខាងលិចហើយប្រាប់ថា៖ " អានាងឯងនៅចាំត្រង់ហ្នឹងហើយ ចាំអញយកលុយប្រគេនតេជគុណ!"

ដាក់កូនសិស្សពីរហ្នឹងចុះហើយ អាពាលចេញទូកទៅបាត់តែម្តងៗ

និយាយពីលោកឯណោះនៅចាំមើល ចាំៗទាល់តែព្រលប់ ក៏ថ្ងល់ថា៖" អើវាព្រលប់ណាស់ហើយ អត់ឃើញថៅពាលហ្នឹងត្រលប់បកមកវិញសោះ?"

តេជគុណក៏និមន្តទៅវត្តវិញៗ លុះទៅដល់វត្ត នៃចុះទូកៗ កូនសិស្សទាំងពីនោះថា៖ "ម្នាក់ដែលទៅជាមួយតេជគុណ ហើយតេជគុណបានប្រើឲ្យមកយកលុយនោះ មានឃើញទេ?"

តេជគុណ៖ "អ្ហាក! អញមានប្រើឲ្យមកយកលុយឯណា?"

លោកថ្ងល់ ក៏និមន្តទៅសួរលោកកាន់សោរកុដិៗ ពេលទៅដល់ លោកស្រែកបន្ទោសថា៖ "ម៉េចក៏ឲ្យ

លុយទៅគេអញ្ចឹង?"

លោកថា៖ "ទេ! ខ្ញុំករុណាមិនដឹងដែរ ឃើញកូនសិស្សពីរនាក់ហ្នឹងប្រាប់ថាតេជគុណឲ្យមកយកលុយ ករុណាក៏ឲ្យទៅ!"

តេជគុណហួសចិត្តថា៖ "អូ! លុយហ្នឹងចប់ហើយអញ្ចឹង ចៅពាលហ្នឹងវាបោកប្រាសទេតើ អ្ហា! គិតទៅពាលមែន វាមិនទៀងទាត់ទេណាស់!" ។ អារឿងហ្នឹងក៏ចប់ត្រឹមហ្នឹងទៅ៕

# ១២- រឿងសុភាទន្សាយ

## និទានដោយ អាចារ្យ ប៉ែន ផាន[12]



12 ភូមិពពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ

រឿងសុភាទន្សាយហ្នឹងក៏តាបានដឹងតិចៗដែរ  អាហ្នឹងគឺបទកុជង្គ  នេះនឹងតំណាលដំណើរពីកាលព្រេងនាយចាស់លោកនិយាយតពីបុរាណ។

មានកាលថ្ងៃមួយដែលចាស់នោះឯងទៅថ្កាន កូនអើយ យើងគ្មានកូនចៅហើយក្រសត់ផង។ យាយតាទៅកាប់ចំការដាំចេក អាសត្វទន្សាយនេះឃើញយាយទូលចេកទៅលក់ វាធ្វើពុតជាងាប់ យាយឃើញដូចនេះក៏លើកដាក់លើល្អីជាមួយចេកបន្តដើរទៅមុខទៀត។  អាទន្សាយដឹងនៅលើល្អីក៏ចាប់បកចេកស៊ីអស់ទៅ។ ដល់យាយដើរទៅដល់ផ្ទះអ្នកស្រុកប្រុងនឹងលក់ចេក  អាទន្សាយឯណោះក៏លោតផ្លោតបោលចូលព្រៃបាត់ទៅ។ យាយអត់ដឹងខ្លួនទេ ចេះតែដើរទៅ លុះពេលដាក់ល្អីចុះមក ក៏ឃើញអស់ចេករលីង ហើយទន្សាយក៏បាត់ទៀត នៅតែសំបកចេក។

យាយខឹងណាស់ក៏ត្រលប់មកផ្ទះវិញ  មិនបានលក់ចេកទេ  ហើយទូលពិតប្រាប់តាថា៖ "តា!  ទៅដាក់អន្ទាក់អាទន្សាយកំហូចទៅ វាស៊ីចេកយើងអស់មិនបានលក់ទេ។"

តាក៏ព្រមធ្វើអន្ទាក់យកទៅដាក់នៅក្បែរផ្លូវ។ អាទន្សាយក៏ទៅជាប់អន្ទាក់តាមែន។ លុះជាប់អន្ទាក់តាទៅទន្សាយកិតភ័យមែនទែនមិនដឹងធ្វើម៉េចទេ  ស្រាប់តែឃើញគីង្គក់មួយលោតផ្លោតនៅក្បែរនោះ  វាក៏ស្រែកហៅគីង្គក់ថា៖ "ឯងជួយដោះអញឲ្យរួចពីអន្ទាក់ទៅ អញនឹងជួយមើលស្រែងឯងពីណាពីណែមកឲ្យជា។"

គ្រាន់តែឮអញ្ចឹងគីង្គក់អរណាស់  ក៏យល់ព្រមជួយដោះទន្សាយ។  ពេលដែលគីង្គក់ជួយទន្សាយឲ្យរួចពីអន្ទាក់ហើយ ទន្សាយបោកគីង្គក់ឲ្យប្រចបាច់ដៃប្រចបាច់ជើងវា ព្រោះវាត្រូវអន្ទាក់រឹតចុកដៃចុងជើងណាស់។ គីង្គក់ក៏ធ្វើតាមទៀត  លុះគីង្គក់ប្រចបាច់ដៃប្រចបាច់ជើងឲ្យវាអស់ចិត្តអស់ចង់ហើយ វាស្រែកថា៖  "អាអឺយ  អាគីង្គក់

ស្រែងឯងពីដូនតា គ្មានអាណាមើលឯងជាទេ!"

គីង្គក់ទឹងណាស់ អត់មាត់អត់កអីទេ ក៏លោតទៅវិញ ព្រោះទន្សាយរកជាក់រកទាត់ផង។ តាក៏ទៅមើលអន្ទាក់ថា៖" យីអើ! អាណាអញ្ចេះ ទន្សាយបាត់អន្ទាក់ក៏បាត់ខ្ចាត់ខ្ចាយអស់ អត់អីទេវែង អញនឹងរកកន្ទែងដាក់ទៀត។"

តាចាស់ដាក់ទៀត ទន្សាយក៏ជាប់អន្ទាក់តាជាលើកទីពីរទៀត ហើយជួបគីង្គក់ទៀត។ គីង្គក់ឃើញ ទះដៃផ្ទង់ហើយស្រែកថា៖ "អាចង្រៃ! អាអប្បលជាប់អន្ទាក់តាទៀតហើយហ្អែង!!"

ទន្សាយខំអង្វរគីង្គក់ឲ្យជួយដោះអន្ទាក់ខ្លួនទៀត តែគីង្គក់ថា៖"អញអត់ដោះឯងទេ ព្រោះឯងបោកអញម្ដងហើយ។"

តាំងពីគីង្គក់ចេញបាត់ទៅ ទន្សាយក៏ធ្វើពុតជាងាប់។ តាមកឃើញទន្សាយជាប់អន្ទាក់ គាត់ក៏ដោះយកទៅផ្ទះ។ យាយថា៖ "អើ អាហ្នឹងហើយថ្ងៃមុនបោកអញ!"

យាយទឹងណាស់ចង់បោកវា តែតាថា៖ " កុំបោកវាយាយ! នាំតែបែកថ្មោក បែកសាវាទេ។"

យាយក៏ដាក់វាលើគ្រែ ឯតាទៅរកស្លឹកថ្នឹងប្រុងនឹងស្ងោរជាមួយសាច់ទន្សាយឆ្ងាញ់ម្ដងជាមួយយាយ។ យាយរវល់តែក្លេចខ្លួន ទន្សាយក៏លបលួចលូនចុះទៅបាត់ទៅ។

និយាយពីពពែមួយខ្វាក់ភ្នែកហើយគ្នាវាកំព្រើកំព្រាព្រាត់ម៉ែព្រាត់ឪអត់ភ្នែក មើលអីអត់ឃើញទេ ចេះតែដើរទៅ។ អាទន្សាយវាបាក់ក្ដៅមួយក៏ទៅជួបនិងពពែខ្វាក់ភ្នែកហើយសាកសួរគ្នា។ ពពែសួរ៖ "ម៉េចបានជាឯងបាក់ជើងបាក់ដៃអញ្ចឹង។"

ទន្សាយថា៖ "មកពីខ្ញុំជាប់អន្ទាក់តា តែខ្ញុំរត់គេចពីតាបាន អញ្ចឹងឥឡូវយើងសហការពីរនាក់គ្នាទៅ ព្រោះយើងបាក់ជើង ឯឯងខ្វាក់ភ្នែក។ បងពពែឯងជាជើង ឯខ្ញុំជាភ្នែក ខ្ញុំឡើងជិះលើខ្នងបងឯង ហើយដើររកស៊ីទាំងអស់គ្នាទៅ!"

ពពែក៏ព្រមតាម។ ទាំងពីរនាក់ក៏ដើររកស៊ីជាមួយគ្នា ដើររកកន្លែងណាដែលមានស្មៅល្អ។ ចេះតែជិះគ្នាដើរៗទៅ ក៏ទៅប្រទះឃើញមានស្មៅមួយកន្លែងមានដំបូកមួយក៏នាំគ្នាឈប់សំរាក ឲ្យពពែស៊ីស្មៅ ឯទន្សាយលោតទៅឈរនៅលើដំបូក។ ស្រាប់តែមានខ្លាធំមួយឃើញពពែកំពុងស៊ីស្មៅក៏ចង់ស៊ីពពែ។ ទន្សាយឃើញ ក៏ស្រែកប្រាប់ពពែថា៖ "ឥឡូវមាន ខ្លាធំណាស់ វាលបៗដើរមករកបងឯងហើយ!"

ពពែថា៖ "ពេលនឹង ស្រេចតែបងឯងទេ ជួយខ្ញុំផង ខ្ញុំមើលមិនឃើញទេ។"

លុះខ្លាដើរជិតមកដល់ហើយ ទន្សាយគ្រហែមថា៖ "ហែមៗ! ម្សិលមិញស៊ីខ្លា៥មិនឆ្អាំផ្ទៃសោះ ឥឡូវស៊ីគ្រាប់មូលប៉ុនមេដៃស្អា ក វាល់ល្ងាចតែម្ដង!"

អាខ្លាឮហើយគិតក្នុងចិត្តថា៖ "យីខ្លាធំ៥ហើយនៅ ស៊ីមិនឆ្អែត ចុះទំរាំអញតែម្នាក់ឯងផងម៉េចនឹងឈ្នះវា!"

គិតហើយក៏រត់ក្តុងទៅជួបនឹងស្វាមួយកំពុងនៅលើចុងឈើ។ ស្វាក៏ស្រែកសួរថា៖" អើខ្លា! រត់អីហ្នឹងនៅកណ្ដាលថ្ងៃត្រង់ហ្នឹង។"

ខ្លាតបទាំងហត់ថា៖ "អ្ហា! កុំអាលសួរអី អញភ័យណាស់!"

"ភ័យយ៉ាងម៉េចហ្នឹង?" ស្វាសួរ ។

"យីកុំតែគេចទាន់ កុំអីអាទន្សាយស៊ីបាត់ៗ" ខ្លាថា។

"យី! អាទន្សាយស៊ីយ៉ាងម៉េច? យីឈប់សិនបងខ្លា ចាំខ្ញុំចុះសិន!" ស្វាថា។

ស្វាចុះមកក៏សួរថា៖ "មើលនៅឯណា? ជូនខ្ញុំទៅមើលមើ!"

ខ្លាតបថា៖ "យី! អត់ហ៊ានទៅទេ ព្រោះខ្លាចអាទន្សាយស៊ី! អ្ហែ មិនទៅទេ! ខ្លាចបងឯងរត់ចោលខ្ញុំព្រោះបងអ្ហែងចេះឡើងដើមឈើហើយខ្ញុំអត់ចេះឡើងទេ!"

អញ្ចឹងស្វាថា៖ " អញ្ចឹងអញ្ចេះយើងចងជាប់កន្ទុយជាប់គ្នាទៅៗ"

ស្វានិងខ្លាក៏នាំគ្នាដើរទៅរកទន្សាយ។ លុះមកដល់ ទន្សាយងើបក្លែតបន្ទឹថា៖ "អ្ហែអាជួយម៉ែ អាទោចអាស្វា ខ្ញុំអញ្ជតាំងពីជូនតា ឯងយកខ្លាកញ្ចាស់មកឲ្យអញជាម្ចាស់វាតើ!"

ខ្លាឮ ក៏បោលក្តុងក្រវ៉ាត់កន្ទុយវាទៅគ្រវីគ្រវាត់ស្វាបោកបែកក្បាលចេញឈាមងាប់ហ៊ាមាត់ស្មេញ។ ខ្លាងាកទៅឃើញស្វាដូចនេះក៏ថា៖ "អញប្រឹងរត់សឹងងាប់! វានៅធ្វើធ្មេញស្មេញស៊ីស្វាម្ហូមាត់ឡើងក្រហមឈិល!!"

ខ្លាក៏ខំប្រឹងរត់បោលចូលព្រៃបាត់ទៅ។ គេនិយាយពីរឿងពពែ ហើយនឹងទន្សាយវិញ។ ទន្សាយថា៖ "ឥឡូវបងយើងនៅទីនេះមិនបានទេ បើខ្លារត់មកតាមក្រោយយើង ងាប់យើងហើយព្រោះយើងបានបោកវាពីរដងហើយ បើអញ្ចឹងយើងគិតនាំគ្នាឆ្លងស្ទឹងទៅត្រើយឯណោះវិញ កុំឲ្យតាមដានដល់យើងទៀតណា។"

តែទន្សាយថា៖ "មិនដឹងជាឆ្លងយ៉ាងម៉េចទេ!"

ចំពេលនោះទន្សាយឃើញក្រពើមួយ មួយកំពុងតែហែលទឹកផុងចុះឡើងៗនៅក្នុងស្ទឹង។

ពពែងឹតភ្នែកអត់ឃើញអីនោះថា៖ "អើ ខ្ញុំក៏មិនដឹងដែរ ស្រេចតែបងឯងចុះ!"

ទន្សាយថា៖ "អើ អញ្ចឹងបងឯងធ្វើតែតាមខ្ញុំប្រាប់ទៅ បើកាលណាខ្ញុំថាឲ្យខ្លាច បងធ្វើជាខ្លាចទៅ បើបញ្ជាឆ្វេងទៅឆ្វេងស្ដាំទៅស្ដាំតាមខ្ញុំចុះ!"

ពពែក៏ព្រមតាម ទន្សាយក៏ចុះទៅមាត់ច្រាំងហៅក្រពើមកសួរនិយាយគ្នា ទន្សាយក៏សុំថា៖ "បងចម្លងខ្ញុំទៅត្រើយខាងនោះផង ខ្ញុំនឹងឲ្យពពែបងឯងស៊ីៗ"

ក្រពើកំពុងតែឃ្លានផង ក៏យល់ព្រមៗ ទន្សាយមុននឹងឡើងជិះលើក្រពើ វាកាត់ស្លឹកឈើមកទ្រាប់លើខ្នងក្រពើអង្គុយ ព្រោះវាខ្ពើមខ្លាចមុតក្អិតវាៗ ក្រពើថា៖"មិនបាច់ទេ! បងកុំខ្លាចប្រឡាក់អី!"

ទន្សាយថា៖ "ទេ! ខ្នងបងអ្នែងដូចមាសដូចប្រាក់ឲ្យខ្ញុំអង្គុយផ្ទាល់យ៉ាងម៉េច! កាច់ស្លឹកឈើទ្រាប់អង្គុយទើបបានៗ"

ក្រពើនោះហែលកាត់បឹងធំណាស់ ធ្វើឲ្យវាហត់ណាស់ ទន្សាយក៏លើកទឹកចិត្តថា៖ "ទៅប្រឹងបង ឆាប់បានស៊ី!"

ពេលទៅដល់ច្រាំង ក្រពើថា៖ "ដល់ហើយបងទន្សាយ!" ទន្សាយប្រាប់ឲ្យពពែលោតឡើងទៅលើច្រាំងមុន វាទៅតាមក្រោយៗ

ក្រពើចាំយូរបាត់មិនឃើញ ស្រាប់តែទន្សាយស្រែកថា៖ "ហ្អើយ! អញមិនឲ្យស៊ីទេព្រោះពួកម៉ាក់អញកម្សត់កម្រតាំងពីតូចដល់ធំនេះ អញមិនឲ្យស៊ីទេៗ

ក្រពើខឹងណាស់ ពេលទន្សាយបោកខ្លួនយ៉ាងនេះក៏គិតម្នាក់ឯងថា៖ "គិតលេងល្បិចយ៉ាងម៉េចដើម្បីនឹង

ស៊ីទន្សាយទីងពពែឲ្យបាន។"

ក្រពើក៏គិតធ្វើពុតជាងាប់អណ្ដែតបណ្ដោយទឹក។ ទន្សាយថា៖"អញមិនជឿទេ! មិនដែលក្រពើណាងាប់បណ្ដោយទឹកទេ វាអណ្ដែតច្រាសទឹក។"

ឮដូចនោះ ក្រពើនោះឆោតក៏ធ្វើជាងាប់ម្ដងទៀតហើយអណ្ដែតច្រាសទឹកម្ដង។ ទន្សាយឃើញក៏ថា៖ "ក្រពើងាប់ឯណាដែលអណ្ដែតច្រាសទឹក មានតែក្រពើរស់ទើបអាចអណ្ដែតច្រាសទឹកបាន អញមិនជឿទេ បើឯងងាប់លើគោកទើបអញជឿ!"

ក្រពើចាញ់កលទន្សាយទៀត។ ក្រពើក៏ឡើងមកលើគោកធ្វើជាងាប់មែន។ ទន្សាយទុកពពែឲ្យនៅស៊ីស្មៅនៅឯវាល ឯវាមកសន្ទូរឿងឯណោះជាមួយទីងក្រពើ។ ពេលក្រពើវារឡើងទៅងាប់លើគោក វាហាមាត់ចង្ក្រងរុយរោមអែ ទន្សាយមកឃើញគិតថា៖ "អូ! អានេះងាប់បាត់ អានេះងាប់រឹងស្ដូក!"

វាក៏ឡើងប្រុំឡើងជាក់លើក្រពើរហូតរអិលធ្លាក់ចុះឡើងផ្ទាត់ជើងធ្លាក់ចូលមាត់ក្រពើ។ ក្រពើបានឱកាសខាំគ្រីប។ ក្រពើថា៖ "អើ អញគិតស្រួបគិតលេបទាំងមូលហ្នង។"

ទន្សាយឮទឹកភ័យក៏ឆ្លើយថា៖ "បើឯងស្រួបអញល្អណាស់ អញមានកាំបិតមួយមុខខ្វាកេវ្ដ័ពីដូនតាសំរាប់តែវះយកពោះវៀនឯងមកស៊ីតែម្ដង!"

ក្រពើឮភ័យ ក៏ហាមាត់វិញ ទន្សាយក៏រត់បោលរឹងចេញពីមាត់ក្រពើ។ ដល់បានជួបបងពពែ ទន្សាយថា៖ "យើងនៅអត់បានទេ យើងទៅទៀតព្រោះខ្ញុំមិញ ប៊ិះតែខានឃើញមុខបងអ្ហែង តែបានតម្រិះមួយថាបើបានក្រពើលេប អរណាស់អាងទៅស្រាវយកពោះវៀនក្រពើយកមកស៊ី អានោះឮថាខ្វាចអញទៅស្រាវពោះវា

វាក៏ហាមាត់ព្រេច។

ទន្សាយក៏រត់បែកពីពពែទៅជួបនឹងមាន់ អក ខ្លា បបួលចងគ្នាជាមិត្ត ហើយគិតនាំគ្នាទៅច្រូតស្រូវ។ ទន្សាយថា៖"យើងនាំគ្នាទៅអស់ទៅ តើត្រូវឲ្យនរណាម្នាក់នៅចាំផ្ទះ ចាំដាំស្ល ដាំបាយដាំទឹកនៅពេលធ្វើការច្រូតស្រូវ។"

ទាំងអស់គ្នាក៏យល់ព្រមឲ្យមាន់ចាំមុនធ្វើម្ហូបមុនគេ។ មាន់មិនដឹងបានអីមកធ្វើម្ហូប វាក្រាបយកមាន់ពងខ្លួនឯងឲ្យគេស៊ីអញ្ចឹងទៅ ហើយក៏បានចប់មួយវគ្គអញ្ចឹងទៅ។ ស្អែកឡើងគេឲ្យអកចាំម្ដង អ្នកឯទៀតទៅកាត់ស្រូវ។ អកក៏ចេញទៅចាប់ត្រីចាប់អីមកស្លស្ងុកអាំងឲ្យគេស៊ីទៅ។ ថ្ងៃក្រោយមកទៀតដល់វេនខ្លានៅចាំផ្ទះដណ្ដាំស្ល ឯអ្នកផ្សេងនាំគ្នាទៅច្រូតស្រូវ។ លុះគេនាំគ្នាទៅអស់ទៅ ខ្លាដើរលបៗទៅចាប់សត្វឈ្លូសប្រើសរមាំងអីអញ្ចឹងបានមកធ្វើម្ហូបឲ្យគេស៊ីទៅ។

ថ្ងៃមួយ ដល់វេនទន្សាយៗមិនដឹងគិតធ្វើយ៉ាងម៉េចហ្នឹងគេនឹងរកបានអីមកធ្វើម្ហូបឲ្យគេស៊ី។ បន្ទាប់ពីដាំបាយឆ្អិនហើយ វាក៏ធ្វើតាមអក សំកុកលើគល់ឈើឃើញត្រីរស់ ត្រីសន្ទាយអីអញ្ចឹង ក៏លោតទៅចាប់តែអត់បាននឹងគេទេ។ រួចក៏តាំងធ្វើតាមខ្លាទៀត ខ្លានឹងគេលបអញ្ចឹង គេចាប់សត្វឈ្លូស ចាប់សត្វរមាំងអីអញ្ចឹងទន្សាយក៏លបៗ ឃើញឈ្លូសមួយ ក៏ខំរត់ស្ទុះទៅចាប់មិនបាន បែរជាខ្លួនដួលត្រលប់ត្រឡិនបាក់ដៃបាក់ជើងទៅ។ បន្ទាប់មក ក៏ខំក្រាបពងដូចមាន់ ពងមិនចេញដូចគេទេ។ ធ្វើតាមអក មាន់ ខ្លា តែមិនបានការអីសោះទន្សាយអស់តម្រិះ មិនដឹងបានអីឲ្យគេស៊ីទេ ហើយជិតដល់ម៉ោងទៀត អញ្ចឹងវាគិតចេញកូនគំនិតមួយគឺជុះអាចម៍ដាក់ចានចំហុយធ្វើជាផ្អក។ ហើយយកកូនផ្គៅមកធ្វើជាដានដំរីអ្នកលក់ផ្អកទុកឲ្យគេស៊ី ដល់ហើយវាធ្វើ

ពុតជាគ្រុនជណ្ដប់ក្តួយផ្ទុងសំពន្ធហើយថ្ងូរហឹៗៗ ដល់ពេលគេត្រលប់មកពីច្រូតស្រូវវិញ វាប្រាប់គេថា៖ "រៀបចំបាយទឹកជួសខ្លួនឯងស៊ីទៅណ៎ា! ព្រោះខ្ញុំគ្រុនញាក់ហើយ អត់ហូបបានទេ!"

ចុះវាស៊ីអាចម៍ឯង ស៊ីម៉េចបានៗ ដល់មាន់ អក ខ្វាសួរថា៖ " បានអីស៊ី?"

ទន្សាយនិយាយញ៉រទេទ្រើកថា៖ "បានផ្អកពីអ្នកហ្មជំរី គេមកជូរ"

ពួកនោះក៏ជឿព្រោះឃើញដានដំរីមែន ហើយនាំគ្នាស៊ីទាំងអួលអាក់ទៅៗ អាទន្សាយធ្វើជាថ្ងូរ៖ "ហឹៗៗៗ ពួកឯងស៊ីអាចម៍អញៗ!"

ពួកនោះឮអញ្ចឹងសួរទៅវិញថា៖ "ម៉េច! ម៉េចទន្សាយ អាណាស៊ីអាចម៍អញ?"

ទន្សាយថា៖ "ខ្ញុំមមើរទេ!"

ស្រាប់តែមួយសន្ទុះទៀតទន្សាយថ្ងូរទៀតថា៖ "អឺ! មើលបងខ្វាស៊ីអាចម៍អញៗ"

អក មាន់ ខ្វា សួរពីរបីដងៗ ទន្សាយនៅតែឆ្លើយថា៖ "ខ្លួនខ្ញុំមមើររវើរវាយនិយាយអត់ដឹងទេៗ!"

អីហើយក៏ចប់សព្វគ្រប់ទៅៗ បន្ទាប់មកទន្សាយនិងខ្វាទៅច្រូតស្រូវជាមួយគ្នាៗ ពេលច្រូតស្រូវបានពេញរទេះហើយ ទន្សាយធ្វើជាអ្នកបររទេះ ឯខ្វាជាអ្នកជាអ្នកដឹកស្រូវៗ នៅពេលបររទេះទន្សាយយកដែកធឹកមកគូសក្រឹកៗៗៗ ខ្វាឮដូចនេះក៏សួរទៅទន្សាយថា៖ "ស្អីឮក្រឹកៗហ្នឹង?"

ទន្សាយថា៖ "អ្ហា! ចានវាវណ្ដំគ្នាហ្នឹងណា !"

ទន្សាយនៅគូសក្រឹកៗទៀត ធ្វើឲ្យខ្វាឆ្ងល់ខ្វាក៏សួរទៀត ទន្សាយក៏ប្រាប់ដូចមុនទៀតៗ ទន្សាយចេះតែគូសក្រឹកៗនៅក្រោយរទេះរហូតទាល់តែឆេះស្រូវនៅលើរទេះៗ ឃើញឆេះដូចនេះទន្សាយក៏រត់ចុះពីរទេះ ទុក

បណ្ដោយឲ្យខ្លាខាំអូសរទេះម្នាក់ឯងៗ ស្បូវឆេះឡើងរហូតដល់តែរលោកខ្នងខ្លា បានជាខ្លាមកដល់ឥឡូវវាមានស្នែ្បកពពីងពពាលដោយសារឆេះភ្លើងដែលទន្សាយវាដុតស្បូវឲ្យទីមរលត់ហ្នឹងៗ អាហ្នឹងបុរាណអ្នកប្រាជ្ញគេចងក្រងទុកមកអញ្ចឹង រឿងនេះចប់ទៅៗ

# ១៣- រឿងសត្វកុក

## និទានដោយលោកតាព្រាប ស្រស់ [13]

*មានកុកមួយ ហេតុតែវាចង់ស៊ីត្រីនិងមច្ឆាផ្សេងៗក្នុងត្រពាំងមួយដែលជិតរីង វាក៏ទៅបញ្ចុះបញ្ចូលពួកមច្ឆាទាំងនោះថា៖ "ហឺចុះបងត្រី បងក្ដាម បងខ្យងឯងនៅទីនេះធ្វើអីទៀត បន្ដិចទៀតត្រពាំងនេះ រីងទឹកអស់ហើយ! ហឺបើបងឯងទៅតាមខ្ញុំទៅ នៅត្រពាំងឯណោះសប្បាយណាស់ ថ្លាហើយទឹកក៏ជ្រៅទៀត មានចក មានឈូក មានព្រលិត មានអីទាំងអស់ ហើយធំមិនងាយរីងទេ!*

*កុកទុំនៅលើមែកអំពិលទឹកបារាំងចេះតែតាមសួររឿយៗ។ ពពួកត្រីខ្វាយខ្វល់ក៏ប្រជុំហៅទាំងកំពិស ហៅទាំងស្អីៗមកជុំគ្នា។ ត្រីមួយថា៖ "អញ្ចឹងឲ្យត្រីណាទៅស៊ើបមុន?"*

*ត្រីផ្សេងៗថា៖ "មានតែ បងត្រីក្រាញ់ទេ អត់ចេះស្លូតស្រេការ ដូច្នេះគួរឲ្យត្រីក្រាញ់ទៅ!"*

*អង្គប្រជុំសម្រេចដូច្នេះហើយ មច្ឆាទាំងឡាយក៏ចាត់ឲ្យកុកពាំត្រីក្រាញ់ពីរក្បាល ដើម្បីទៅពិនិត្យមើលលំនៅថ្មី។*

*កុកក៏ពាំត្រីក្រាញ់ទាំងពីរទៅយ៉ាងរហ័សនៅក្នុងត្រពាំងធំមួយ។ ទៅដល់ភ្លាម កុកក៏ទម្លាក់ត្រីក្រាញ់ទាំងពីរទៅក្នុងបឹងនោះ ហើយប្រាប់ថា៖ "បងឯងហែលមើលចុះ! ហើយបងត្រីឯងត្រូវត្រលប់មកជួបខ្ញុំត្រង់នេះវិញកុំខាន!"*

---

13 *នៅភូមិក្រាំងធ្នុង ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ*

ត្រីក្រាញ់ស្ដាប់បានហើយ ក៏ហែលជាគួរចុះទៅ ហែលចុះហែលឡើង ពិនិត្យថាទឹកវាពិតជាត្រជាក់ ទឹកវាពិតជំ អស់ចិត្តអស់ចង់ហើយ ត្រីក្រាញ់ក៏មកជួបកុកវិញ។ កុកក៏ពាំត្រីក្រាញ់ មួយគួរនេះមកទម្លាក់នៅក្នុងត្រពាំងចាស់វិញ។ ពេលត្រលប់មកដល់ មច្ឆាទាំងឡាយក៏នាំគ្នាសួរពីត្រពាំងថ្មីនោះ។ ត្រីក្រាញ់វាឃើញយ៉ាងម៉េច ក៏ថាអញ្ចឹង។ ត្រីខ្វះសួរបញ្ជាក់ថា៖ "ពិតជាអញ្ចឹងមែនឬបងត្រីក្រាញ់?"

ត្រីក្រាញ់ថា៖ "មែនណា យី! សប្បាយណាស់ អត់ចេះរីងហើយទឹកថ្លាទៀត! ស្អែកនេះខ្ញុំឲ្យបងកុកនាំខ្ញុំទៅមុន គេហើយ!"

ស្អែកឡើងកុកក៏មកមែន។ វាចាប់ត្រីក្រាញ់យកទៅមុនគេ។ វាហើរចុះ ហើរឡើង បំភាន់ដាន។ វាធ្វើហើរវៀច ធ្វើដើរក្រេងក្រេងក់ មិនរហ័សរហួនដូចលើកមុនទេ។ ទៅដល់ដើមអំពិលទឹកបារាំង វាចុះទុំលើមែកហើយក៏ចឹកស៊ីត្រីក្រាញ់ហ្នឹងអស់ ដោយមិនឲ្យត្រីក្រាញ់និងមច្ឆាឯទៀតដឹងខ្លួនមុន។ ស៊ីរួច កុកក៏ត្រលប់ទៅបោកប្រាស់មច្ឆាឯទៀតមានតាំងពីកំពឹស ខ្យងខ្ចៅ ដែលរស់នៅក្នុងត្រពាំងនោះជារៀងរាល់ថ្ងៃ តាមឧបាយចាស់របស់វា។ វាស៊ីខ្ទេចអស់មួយត្រពាំង នៅតែក្ដាមមួយវារគើមៗចេញពីរន្ធមក។ កុកឃើញក្ដាមភ្លាមក៏និយាយទៅកាន់ក្ដាមថា៖ "ហីបងក្ដាមឯងខំនៅត្រដរខ្យល់អីទៀតទីនេះ ឃើញទេ មួយត្រពាំងគេទៅអស់រលីងហើយហ្នឹង នៅតែបងឯងមួយ!"

ក្ដាមតបទៅកុក៖ "បងឯងយកខ្ញុំទៅម៉េចនឹងកើត បើខ្ញុំមានជង្គៀបមានអីអញ្ចឹងក្រែងខ្ញុំគាបបងឯងទេដឹង!

កុកថា៖ "ហេ..."

"ឲ្យតែបងកុកឯងធ្វើម៉េចពាំខ្ញុំទៅបាន ខ្ញុំសុខចិត្តទៅជាមួយបងឯងហើយ!" ក្ដាមបន្ត។

កុកឮដូច្នោះ ក៏និយាយឡើងថា៖ "ឥឡូវបងក្ដាមឯងយកជើងទាំងអស់ គាបខ្ញុំបន្តិចៗបានហើយ កុំគាបឈឺពេក ចាំខ្ញុំពាំយកទៅ!

ក្ដាមក៏ធ្វើតាមបង្គាប់កុក។ កុកនាំក្ដាមហើរចុះហើរឡើងលើអាកាស។ ក្ដាមវាក្រលេកឃើញមែកអំពិលទឹកបារាំងសុទ្ធតែស្រកានិងក្បាលខ្មោចត្រីទាំងអស់មួយគំនរ ស្គាល់ជាក់ថាជាបងប្អូនក្នុងត្រពាំងជាមួយគ្នា ក៏កើតក្ដីសង្ស័យឡើង។ ក្ដាមគិតថា៖ "បើខ្លួនលែងដៃពីកុក កុកប្រាកដជាស៊ីខ្លួនមិនខាន ដូច្នេះក្ដាមក៏ខំប្រឹងគាប ក កុកបន្ថែមទៀត។ កុកឈឺក៏និយាយថា៖ "ម៉េចក៏បងឯងគាប ក ខ្ញុំខ្លាំងម្ល៉េះ?"

ក្ដាមតបថា៖ "ហេ... មិនទាន់ដល់កន្លែងទឹក លែងម៉េចនឹងកើត គាបថែមបន្តិចព្រោះខ្ញុំខ្លាចធ្លាក់!"

កុកក៏នៅស្ងៀម។ បន្តិចក្រោយមកកុកថា៖ "អ្នកគាប ក អញខ្លាំងហើយធ្ងន់ទៀត ពាំអ្នកមកយូរពេកអញហត់ណាស់ សម្រាកបន្តិចសិន!"

សម្រាកបានបន្តិច ក្ដាមក៏ចេះតែគាប ក កុកបន្តិចទៀត ហើយតឿនកុកឲ្យបន្តដំណើរ។ កុកថា៖ "ហេ! បើឯងគាប ក អញខ្លាំងដូច្នេះ ធ្លាយបំពង់ កអញ ម៉េចអញពាំអ្នកទៅកើត!"

ក្ដាមតបថា៖ "ហេ តែឯងមិនទៅ ក្ដៅអញផាប់ឥលូវហ្នឹង!"

ក្ដាមក៏ចេះតែខំគាបក កុកបន្ថែមទៀត។

ធុញផងឈឺផង កុកក៏ថា៖ "តោះអញនាំអ្នកទៅ ដឹងអញហ្នឹងមិនខ្ចីយកអ្នកមកទេ!"

ទៅដល់ត្រពាំងហើយ កុកចុះទឹកត្រឹមជង្គង់ហើយបង្គាប់ឲ្យក្ដាមចុះ ចំណែកឯទេវតានៅលើមែកអំពិល

ទឹកបារាំងវិញ ក៏នាំគ្នាចាំមើលថាតើឧបាយកលកុកនិង កលល្បិចក្ដាមអ្នកណាឈ្នះអ្នកណាចាញ់ៗ ក្ដាមដឹងថាបើចុះត្រឹមហ្នឹងកុកនឹងស៊ីខ្លួនបាន ទើបក្ដាមនិយាយថា៖ "អញអត់យកទេ បើអ្អែងចុះទឹកត្រឹមហ្នឹង!"

ក្ដាមក៏គាបកកុកបន្ថែមៗ កុកសួរ៖ "ចុះត្រឹមណា?"

"ចុះឲ្យលិចដល់ត្រឹមក ដល់ដាបពោះអ្អែងបាន អញស្រណុកព្រលែងខ្លួនចូលទឹក!" ក្ដាមឆ្លើយហើយបន្ថែមទម្ងន់គាបៗ

កុកក៏ធ្វើតាមបញ្ជាក្ដាមៗ គ្រាន់តែកុកចុះដល់ដាបពោះភ្លាម ក្ដាមក៏ទាញរឹបជ្រមុជចំពុះ ភ្នែកនិងត្រចៀកកុកឲ្យលិចទៅក្នុងទឹក កុកក៏ឈ្លក់ទឹកងាប់ក្នុងទឹកនាពេលនោះទៅៗ

# ១៤- រឿងក្រពើចង់ស៊ីបេះដូងស្វា

## កុមារ ពេជ្រ ភន [14]

*កាលនោះមួយមានដើមឈើមួយដើមនៅដុះនៅប្របមាត់ស្ទឹងហ្នឹង។ មានស្វាមួយនៅលើដើមឈើនោះ។ និយាយពីក្រពើមួយក្បាលនឹកចង់ស៊ីស្វានោះ វាក៏ធ្វើល្បិចថានឹងនាំស្វាទៅកោះមួយ។ ពេលក្រពើហែលមកក្បែរស្វា ក៏ស្រែកសួរថា៖ អើ បងស្វាខ្ញុំមានរឿងមួយ!"*

*ស្វាឮ ក៏ចុះពីដើមឈើមក។*

*ក្រពើសួរ៖ "តើបងចង់ទៅលេងកោះៗអណ្ដែតស្ទឹងទេ?*

*បងស្វានឹកក្នុងចិត្តចង់លេងដែរ ក៏ព្រមទៅ។*

*បងក្រពើក៏ឲ្យស្វាឡើងជិះលើខ្នងខ្លួន។ ក្រពើយកស្វាទៅ និយាយរឿងបណ្ដើរពីនេះពីនោះប្រាប់ស្វា។ ដល់ពាក់កណ្ដាលស្ទឹង ក្រពើក៏សួរ៖ "តើបងស្វាឯងមានបេះដូងទេ ខ្ញុំចង់សុំបេះដូងបងស្វាឯងយកមកធ្វើថ្នាំព្យាបាលជម្ងឺខ្ញុំ?"*

*ឮដូចនេះ ស្វាគិតថា៖ "យី ក្រពើនេះចង់ស៊ីអញតើ! អញ្ចឹងអញមានតែកុហកលេងល្បិចនឹងវាសិន។"*

*រួចក៏តបទៅក្រពើថា៖ "អូ បងក្រពើ! ខ្ញុំភ្លេចបាត់ទៅហើយៗ ភ្លេចយកវាមកទៅហើយ វានៅឯចុងឈើឯនោះ!"*

---

14 *នៅវត្តហង្សាបិតិព្រែកស្ដី ភូមិព្រែកស្ដី ឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិ៍សាត់*

ក្រពើក៏នឹកឃើញក្នុងចិត្តថា៖ ពេលនេះអញបានស៊ីហើយ អញ្ចឹងអញនឹងយកវាត្រលប់ទៅដើមឈើវិញសិន!"

តែទៅដល់ ស្វាក៏មានល្បិចដែរ វាបញ្ឆោតក្រពើឲ្យយកខ្លួនត្រលប់ទៅដើមឈើនោះវិញដើម្បីយកបេះដូងខ្លួន។ គ្រាន់តែទៅដល់ជិតត្រើយ ស្វានោះលោតឡើងដើមឈើរត់ទៅវិញទៅ ឯក្រពើស្មានថាស្វាលោតទៅយកបេះដូងឲ្យខ្លួនមែន តាមពិតស្វាវាលោតព្រេចរត់បាត់ទៅ។

# ១៥- រឿងទំពែក៤ នាក់

និទានដោយលោក នូ សុងហួន [15]

15 ភូមិព្រៃជា ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ

ខ្ញុំឆ្ងល់រឿងមួយទៀតដូចជារឿងថាបុរសពីនាក់ចង់បានប្រពន្ធគេនោះ លោកតាមានចាំទេរឿងនិង? អត់ចាំទេនិង បើបុរស៤នាក់មានប្រពន្ធមួយអាហ្នឹងបានចាំ ។

អាហ្នឹងយ៉ាងម៉េចដែរលោកតា?

គេថាអាទំពែក៤ នាក់ហ្នឹងជាសំឡាញ់នឹងគ្នា។ អញ្ចឹងពេលជាសំឡាញ់នឹងគ្នា  ស្រាប់តែយកប្រពន្ធតែមួយជាមួយគ្នា។ ស្រីម្នាក់ប្ដី៤នាក់អញ្ចឹងទៅ។ អាមួយអ្នករកអង្ក អាមួយអ្នកបុកជាន់អង្ក អាមួយអ្នកដាំបាយ ហើយអាមួយទៀតអ្នករែកទឹក ហើយប្រពន្ធមិនឲ្យធ្វើអីទេគឺឲ្យនៅតែស្ងៀមទៅ ទុកឲ្យប្ដីអ្នករាប់រងទាំងអស់។

និយាយពីបុរសម្នាក់ឈ្មោះវាចាក់ស្នុក។  អាចាក់ស្នុកហ្នឹងគិតថាជីវិតរកស៊ីរបស់វានឹងពិបាកណាស់ វាចេះតែវិជ្ជាចាក់ស្នុកទេ។ វាឡើងទៅកាប់ស្លឹកត្នោតយកមកចាក់ស្នុកអញ្ចឹង ម្ដងៗពិបាកណាស់ ដូចនេះយូរទៅៗ វាគិតឡើងលើចុងត្នោតកាប់ស្លឹកហើយចាក់ស្នុកនៅនោះតែម្ដង។ កំពុងតែចាក់ស្នុកអញ្ចឹង វាគិតថា៖  "បើអញធ្វើបានច្រើនហើយទើបអញយកទៅលក់តែម្ដង អញនឹងបានលុយច្រើន។ ពេលបានលុយមកហើយ អញនឹងទិញមេមាន់មួយ។ ពេលមេមាន់ពងបាន១០ម្ដង អញនឹងយកទៅលក់ ហើយអញនឹងបានលុយ។ ពេលអញបានលុយមកហើយ អញនឹងយកលុយទៅដណ្ដឹងប្រពន្ធ។ ពេលអញបានប្រពន្ធហើយ អញនឹងមានកូនទៀត។ ពេលអញកំពុងដេកសៀវភៅ  អាកូននោះវាតែស្រែករកអញ  អញស្រែកប្រាប់ប្រពន្ធអញឲ្យជួយយកកូនទៅមើលទៅ កុំទុកឲ្យនៅទើសទែងអញ! ប្រពន្ធនឹងវាមិនឮ ធ្វើនៅប្រិមប្រុម ថៅចាក់ស្នុកថាអេ! អញតែប្រិមប្រុមអញជាក់ប្រពន្ធនឹងឥឡូវ!"

ដល់ទៅជាក់ប្រពន្ធទៅ  ថៅចាក់ស្នុកភ្លេចខ្លួនថាខ្លួននៅលើចុងត្នោតស្រមើស្រម៉ៃ  ក៏របូតជើងធ្លាក់មក

តែដៃគោងជាប់ស្វឹកត្នោត ឯខ្លួនធ្លាក់សំយុងតេកតោកៗមកក្រោម តែត្នោតមិនខ្ពស់ប៉ុន្មានទេ។ មានបុរសម្នាក់ជិះដំរីដើររកមនុស្សស៊ីឈ្នួលម្នាក់ឲ្យមកជួយធ្វើការជាកម្មករនៅផ្ទះ។ ហ្មដំរីកំពុងតែជិះដំរី ថៅចាក់ស្មុកធ្លាក់តេកតោកៗនោះឃើញក៏ស្រែកហៅថា៖ "អូ! លោកអើយជួយខ្ញុំរួចពីចុងត្នោតផង!"

ហ្មដំរីថា៖ "យី! អញកំពុងតែស្វែងរកកម្មករ ឥឡូវអញបានហើយតើ!!"

អញ្ចឹងហ្មដំរីក៏ព្រម។ គាត់ក៏យកដំរីដាក់ខាងក្រោមដើមត្នោត នឹកថាក្រោកឈរនៅលើខ្នងដំរីហើយតោងជើងអាថៅចាក់ស្មុកនៅលើចុងត្នោត រួចប្រាប់ទៅអាចាក់ស្មុកថា៖ "ចាំខ្ញុំស្រែកឲ្យលែងស្វឹកត្នោតចាំលែង។"

ហ្មដំរីមិនទាន់បានស្រែកផង អាជើងដូចជារាងទ្រេតទ្រោតៗដូចជាដេញដំរី ដំរីក៏ដើរហួសទៅ។ ហ្មដំរីក៏តោងជាប់នឹងអាថៅចាក់ស្មុកបន្តជាប់នៅចុងស្វឹកត្នោតទៀត។ ពីរនាក់ហ្នឹងក៏តោងធ្លាក់តេកតោកៗពីលើចុងត្នោត។

និយាយពីប្ដីប្អូននាក់ដែលមានប្រពន្ធតែមួយហ្នុង ថ្ងៃមួយបុរសទាំងបួនហ្នឹងបែបចេញទៅរកអុសហើយ។ បុរសទាំងបួននោះឲ្យតែទៅណាចេះតែដាក់កំណាត់ជំមួយទៅតាមខ្លួនគ្រាន់ទុកធ្វើជាជម្រករុំខ្លួនដេកទាំងអស់គ្នាទៅ។ លុះដើរៗទៅ ក៏ទៅជួបនឹងអាពីរនាក់កំពុងតែនៅតែធ្លាក់តែកតោកៗ។ ពីរនាក់នោះក៏ស្រែកជំណាលគ្នាថា៖ "បើអ្នកឯងជួយខ្ញុំឲ្យបានរស់ ខ្ញុំសុខចិត្តធ្វើខ្ញុំអ្នកឯងមួយជីវិត!"

បុរសទាំងបួនថា៖ "អឺបានហើយ បានម្ដងពីរនាក់តែម្ដង យើងនឹងបានធូរបន្តិច!"

ព្រដូចនោះ គ្នាបួននាក់នោះ គិតគ្នាថា៖ អញ្ចឹងមានតែឲ្យគាត់លែងដៃទម្លាក់ខ្លួនម្ដងមួយមក តែវាធ្លាក់មក

ដូចនេះ វាក្រែងលោងាប់អញ្ចឹងបានខ្ញុំបម្រើមកពីណា បើអញ្ចឹងយើងទាំងបួននាក់កាន់ជាយកំណាត់ម្ខាងម្នាក់ឲ្យគ្រប់បួនជាយទៅព្រោះកំណាត់យើងវាងដូចចតុកោណកែងស្មើគ្នាណាស់!"

ស្រាប់តែម្នាក់លាន់មាត់ថា៖ "អេ!កាន់អញ្ចឹងក្រែងលោរបូតដៃមកវាឈឺ ឈឺទៅយើងយកទៅប្រើការម៉េចហ្នឹងកើត អញ្ចឹងក៏ប្រាប់ថាយើងចងកំណាត់ ចងករជាប់រៀងខ្លួនៗទៅហើយឲ្យវាលោតមកម្នាក់ម្តងៗ!"

អាពីរនោះតោងយូរៗទៅ វាពេយដៃពេកហើយវាគិតគ្នាថា៖ "អ្នកទ្រនៅក្រោមវានៅជើងវាជាប់ដីទេ វាមិនអីទេ មកយើងលោតធ្លាក់ទាំងពីរនាក់តែម្តងទៅ ព្រោះធ្លាក់មកនៅចំកណ្តាលកំណាត់ហ្នឹងវាមិនទេ!"

ពេលអាពីរនាក់នោះទម្លាក់ខ្លួនមក បុរសទាំងបួននាក់ចាំទ្រធ្ងន់ពេក វាទាំងបួននាក់ក៏ងោកទាញទង្គិចបុកក្បាលគ្នារហូតដល់ងាប់ទាំងបួននាក់នោះទៅ ឯពីរនាក់នោះវិញបានរួចខ្លួន អត់បានទៅធ្វើខ្ញុំអ្នកណាទេ ហើយនាំគ្នារត់ទៅផ្ទះរៀងខ្លួនទៅៗ ។

# ១៦- រឿងសត្វកុក និង ចចក

## និទានដោយលោក រួញ ឡេង[16]

*អញ្ចឹងរឿងទាក់ទងនិងសត្វដូចគ្នាសត្វក្រពើអី លោកគ្រូមានចាំរឿងណាមួយ ?*

*អត់បានចាំរឿងរាវនិងដែរបាទ នៃចាំរឿងរាវអញ្ចេះមួយ ខ្ញុំពីកុមារមកលោកគ្រូគាត់និទានរឿងមួយ។*

*និទានរឿងកុកហើយនិងចចក។ កុកនិងចចកជាសំឡាញ់និងគ្នារាបអានគ្នាជិតស្និទណាស់។ ដល់រាប់អានជិតស្និត អញ្ចឹង ចចកថា៖ "អើ បងកុកឯងទៅលេងផ្ទះខ្ញុំម្ដងទៅ!"*

*កុកក៏យល់ព្រមល្មមទៅ។ ដល់ពេលគេរៀបបាយរៀបទឹកអីអញ្ចឹងទៅ ចចកគេហូបនឹងចាន។ ចចកក៏រៀបម្ហូបអាហារបបូរពោរពាសរបស់គេមែនដាក់នឹងចានទៅ ហើយកុកវាហូបម៉េចនឹងកើត បើវាចឹកម្ហូបនៅលើចានទៅខ្ទាតប្រឡាក់ប៉េសប៉ូសៗចេញពេញចាន។ ដល់អញ្ចឹងចចកនោះមានញាតិមិត្តច្រើនណាស់មក គេល្អកល្អើនណាស់ គេម្នាក់នាំគ្នាហូបឆ្ងាញ់ណាស់ក្នុងក្រុមគេ។ ចចកនិងហ្វូងសត្វឯទៀតចេះតែនាំគ្នាហូបទៅ ហើយកុកនៅឈរប្រឆ្ងវៗទៅហូបមិនកើត ព្រោះខ្លួនមានតែចំពុះសំរាប់ចឹកហូប។ ហើយចចកនោះនិយាយថា៖ "ចុះបងកុកចាំអីទៀត ម៉េចក៏មិនហូបទៅ!"*

*កុកថា៖ "ហីមិនសូវឃ្លានដែរទេ!"*

*តែតាមពិតពោះវាឃ្លាណាស់ តែហូបអត់កើតចេះតែធ្វើយដោះសាអញ្ចឹងទៅ។ ឯគេទៀតគិតតែនាំគ្នាស៊ី*

---

16 *ភូមិពត់សរ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ*

ផឹកៗ ឆ្អែតអស់ៗ កុកនោះហើរណាស់ត្រលប់ទៅផ្ទះវិញទាំងពោះទទេរ។

សម័យថ្ងៃមួយ កុកក៏គិតនាំបរិវារធ្វើម្ហូបធ្វើម្ហាចំណីចំណុករៀបចំជប់លៀងម្ដង ហើយគិតថា៖ "ហេបើអញ្ជើញអញគិតបបួលបងចចកមកជប់លៀងផ្ទះអញម្ដង។"

កុកក៏រៀបចំធ្វើដូចចចកអញ្ជើញ រៀបចំកន្លែងទទួលភ្ញៀវបានហូរហែរម្ហូបអាហារឆ្ងាញ់ច្រើន តែម្ហូបដាក់ក្នុងថូទាំងអស់ល្មមសម្រាប់ចំពុះកុកលូកចឹកស៊ីបាន។ ចចកមកចូលរួមពិធីដែរ តែវាហូបមិនកើត អង្គុយមើលតែថូ ក្បាលចចកវាធំ ហើយមាត់ថូតូចល្មមតែចំពុះកុកលូកចូលបាន។ ឯពួកកុកវិញនាំគ្នាចឹកហូបដូចចង្កឹះអញ្ជើញចាប់ដាក់ៗ។

កុកសួរថា៖ "ចុះបងចចកឯងចាំអីទៀត! អញ្ជើញហូបទៅ! ពិសាទៅ! ញាតិមិត្តយើងមកជួបជុំគ្នាអស់ហើយ!"

ចចកឯណោះចេះតែថា៖ "បាទៗ! ខ្ញុំៗ ហូបអត់កើតបើដាក់ថូអញ្ជើញ!"

បើអញ្ជើញក្នុងផ្ទៃរឿងហ្នឹងប្រហែលជាដេញបញ្ញាគ្នាឬក៏មានគំនុំក្នុងចិត្ត ឬក៏សាកល្បងផ្ចាញ់គ្នាវិញម្ដង។ បាទរឿងនេះលោកគ្រូខ្ញុំគាត់និទានរឿងប៉ុណ្ណឹង ខ្ញុំឮចេះចាំរឿងនេះកាលពីខ្ញុំនៅពីក្មេងមក ៕

# ១៧- រឿងគ្រូ និងសិស្ស

## និទានដោយលោក គឹម ងួនជា[17]

*រឿងគ្រូនិងសិស្សគឺចំណងជើងវាអញ្ចឹង។ លោកគ្រូហ្នឹងជាព្រះសង្ឃ លោកមានកូនសិស្សម្នាក់ឈ្មោះវាអាប្ញូង។ ថ្ងៃមួយហ្នឹងលោកគ្រូគិតថា៖ "តើយើងគួរទិញរបស់អីដែលអាចទុកឆាន់បានយូរ?"*

*អញ្ចឹងអាប្ញូងនោះក៏ប្រាប់ថា៖ "ករុណាជីង!"*

*លោកតា៖ "ស្អីអា! ទុកឆាន់បានយូ?"*

*កូនសិស្សថា៖ "អំបិល!"*

*គិតហើយលោកគ្រូក៏ទៅទិញអំបិលយកមកទុក តាមកូនសិស្សប្រាប់។ ដល់បានមកហើយ គិតថា៖ "យើអញទិញអំបិលមួយការុងអញ្ចឹង តិចគេលួចទេដឹង អញ្ចឹងយកទៅលាក់ឯណាកុំអោយគេឃើញ?"*

*សិស្សឲ្យយោបល់ទៀតថា៖ "យកទៅលាក់ក្នុងទឹក មិនមាននរណាឃើញទេ!"*

*គ្រូក៏ធ្វើតាមសិស្សទៀត យកអំបិលមួយការុងនឹងទៅទំលាក់ក្នុងទឹកទៅ។ ដល់ពេលត្រូវការឆាន់ ឲ្យអាប្ញូងទៅយកមក។ ដល់ទៅយកមក អំបិលនោះរលាយអស់ រួចឃើញត្រីកញ្ចុះមួយនឹងវាស្លាប់នៅទីហ្នឹង អាប្ញូងរាយការណ៍ប្រាប់លោកគ្រូថា៖ "អំបិលមួយការុងនេះប្រហែលជាត្រីនេះឯងស៊ីអស់ហើយ!"*

*ដូច្នេះអាប្ញូងក៏យកត្រីហ្នឹងទៅប្រគេនលោក។ លោកក៏សួរថា៖ "ឯណាអំបិល?"*

---

17 *ភូមិសំរោងស្នោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង*

កូនសិស្សអត់ប្រាប់ថាអំបិលរលាយបាត់អស់ទេ គឺទម្លាក់កំហុសទៅលើអាត្រីកញ្ចុះមួយនេះឯងជាអ្នកស៊ីអំបិលហ្នឹង។

ឮដូច្នោះ លោកក៏ទះកំភ្លៀងត្រីនោះ ព្រោះខឹងនឹងវាស៊ីអំបិលអស់មួយការុង។ ទះទៅក៏មុតដៃនឹងឆ្អុងត្រីកញ្ចុះចេញឈាមលោកគ្រូលាន់មាត់ថា៖ "អេ! អានេះឆាប់ហើយកាចទៀត អញ្ចឹងឯងយកវាទៅអាំងឲ្យអញ។"

អាប្អូនយកត្រីកញ្ចុះទៅអាំង។ អាំងឆ្អិនហើយវាស៊ីអស់រលីង។ ស៊ីអស់ហើយ ក៏វាយរុយមួយដាក់ទីហ្នឹង ហើយប្រាប់លោកថា៖ "នៅពេលខ្ញុំអាំងហើយ រុយនឹងស៊ីអស់!"

អញ្ចឹងលោកគ្រូឲ្យអាប្អូនដើរវាយរុយ ទោះនៅឯណាក៏ដោយ វាយឲ្យងាប់អស់ ចៃដន្យរុយមួយនៅលើខ្នង់ប្រមុះលោក លោកមិនហ៊ានថារុយនៅលើខ្នង់ប្រមុះលោកទេ លោកគ្រូចង្អុលប្រមុះខ្លួនឯងហើយឲ្យសញ្ញាថា៖ "អឺ អឺៗៗ។"

អាកូនសិស្សមើលឃើញរុយនៅលើខ្នង់ប្រមុះលោកដូច្នោះ ក៏វាយផូងៗចំខ្នង់ប្រមុះលោក លោកក៏ប្រកាច់ស្អឺៗៗ។

ដល់អញ្ចឹងទៅ ដល់ពេលឆាន់ អាប្អូនវាលើកថាសមក វាប្រគេនលោកច្រលំ ទៅដាក់លើព្រះកេសលោក តាមពិតចិត្តនឹងវាចង់ធ្វើអញ្ចឹង ហើយលោកសួរថា៖ "ម៉េចបានឯងលើកដាក់ព្រះកេសអញ?"

"ខ្ញុំករុណាមើលមិនឃើញ!" កូនសិស្ស ។

"អែងនិយាយលេង ក៏និយាយមែន?" លោកសង្ឃ។

"ករុណានិយាយមែន ករុណាមើលអត់ឃើញ ករុណាគ្មានបំណងអីដាក់អញ្ចឹងទេ!" កូនសិស្ស។

"អញ្ចឹងមានតែអញចេះកំបាំងខ្លួន?" លោកសង្ឃ។

"ករុណាមិនដឹងថាតេជគុណចេះកំបាំងខ្លួនផង!!" កូនសិស្ស ។

ដល់អញ្ចឹងទៅលោកថា៖ "បើអញចេះកំបាំង ឯងមើលមិនឃើញអញ្ចឹង ពេលអញទៅឆាន់នៅផ្ទះគេ អញអត់ស្លៀកស្បង់ទេ អញគ្រងតែចីវរទៅបានហើយ។"

ដល់ថ្ងៃមួយ គេនិមន្តលោកទៅឆាន់នៅផ្ទះ។ ដល់ទៅឆាន់ទៅ ស្រាប់តែលោកមិនស្លៀកស្បង់ទេ លោកតែគ្រងតែចីវរទេ ព្រោះគិតថាខ្លួនចេះកំបាំងខ្លួន។ លុះលោកគង់ទៅ លេចចេញកេរ្ដិ៍ខ្មាសឲ្យឧបាសកឃើញ។ ឧបាសកនាំគ្នាដេញវាយលោក។ លោករត់មកកុដិវិញយ៉ាងលឿន ហើយសួរអាប្អូនថា៖ "ម៉េចឯងថាមើលអញមិនឃើញ ឥឡូវម៉េចគេឃើញអញ? គេឃើញទាំងប្រដាប់អញទៀតផង!"

សិស្សតបថា៖ "ខ្ញុំករុណាមិនដឹងដែរ ចុះព្រះអង្គកាលមន្ដទៅ មន្ដដើរកាត់តាមណាដែរ? "

លោកគ្រូថា៖ "អូ អញដើរតាមនេះ!!"

សិស្សបញ្ឆោតគ្រូទៀតថា៖ "អូ!! ដើរក្រោមដើមស្ពឹអញ្ចឹង បានជាសាបអស់!"

# ១៨- រឿងអាឡេវ

## និទានដោយលោកតា ស៊ូ ឡាង [18]



18 នៅភូមិអង្គញជី ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម

លោកតាធ្លាប់ស្ដាប់រឿងអាឡេវទេ?

រឿងអាឡេវ ពីដើមចាស់ៗច្រើននិយាយលេងដែរតើ!

លោកតាជួយនិទានរឿងអាឡេវឲ្យចៅស្ដាប់បន្ដិចមើល! ខ្ញុំចង់ដឹង! រឿងអាឡេវហ្នឹងយ៉ាងម៉េចលោកតា?

បាទ! អាឡេវហ្នឹងវាជាមនុស្សខ្ជិលខ្ជះអីខ្ជះអញ្ចឹងទៅ ជួនវាត្រង់ពេក ជួនវាវៀចពេក។

ក្នុងគ្រួសារមួយមានកូនប្រុសម្នាក់ឈ្មោះអាឡេវ។ ដល់កូនហ្នឹងធំអាយុប្រហែល៧-៨ឆ្នាំ ឪពុកម្ដាយយកវាឲ្យទៅនៅវត្ត បម្រើលោកដើម្បីនឹងបានរៀនសូត្រខ្លះ។ ដល់ពេកលោកនិមន្ដទៅបិណ្ឌបាតម្ដងៗ លោកតែងតែបញ្ជាឲ្យកូនសិស្សលោកនៅចាំកុដិ ចាំវិហារកុំឲ្យឆ្កែវាឡើងទៅជុះអាចម៍ដាក់។ ដល់ចាំៗអញ្ចឹងទៅថ្ងៃមួយនោះដល់វេនអាឡេវហ្នឹងចាំវិហារ លោកតាប្រាប់វាថា៖ "ឯងចាំវិហារណ៎ា កុំឲ្យឆ្កែឡើងជុះអាចម៍ដាក់ឲ្យសោះណា បើមិនអញ្ចឹងទេ អញនឹងឲ្យឯងស៊ីអាចម៍វាឲ្យអស់ហើយ។"

ថាហើយលោកតាក៏ចេញបាត់ទៅ។ អាឡេវក៏ស្ដាប់តាម។ វាក៏ទៅឲ្យម៉ែវាធ្វើនំល្ងឲ្យច្រើនយកមកទុកធីនៅវត្ត។ ដល់ពេលបាននំហ្នឹងមក អាឡេវវាចាំបញ្ឆោតលោកតា វាយកនំហ្នឹងទៅពូតពំនូតតូចៗប៉ុនមេដៃ ដាក់ពង្រាយពីរបីដុំៗជុំវិញព្រះវិហារ។ រួចដល់ពេលលោកនិមន្ដត្រឡប់ពីបិណ្ឌបាតវិញ ឃើញសុទ្ធតែអាចម៍ឆ្កែជុំវិញព្រះវិហារដូច្នេះក៏ខឹងណាស់ ក៏វាយអាឡេវឲ្យស៊ីសាច់ឆ្កែនោះ។ ចុះអាឡេវាខ្លាចអីនឹងស៊ី បើជានំល្ង។ ដល់វាស៊ីទៅ វាថា៖"ឆ្ងាញ់ៗ!"

លោកឲ្យអាឡេវស៊ីមួយពំនូតវាយមួយខ្វាប់ៗ រហូតទាល់តែនៅសល់មួយពំនូតចុងក្រោយ លោកលាន់

មាត់ថា៖ "យី អាឡេវស៊ីដូចឆ្ងាញ់!"

អាឡេវក៏រើសឲ្យលោកមួយដុំភ្លក់ៗ ដល់ភ្លក់អញ្ចឹងទៅ លោកក៏លាន់មាត់ថា៖ "យីអាចម៍ឆ្កែផ្អែម អញ្ចឹងបានជាអាឡេវស៊ី!"

រួចលោកក៏លួចលោមអាឡេវដោយសួរថា៖ "អាចម៍មេមួយណា ឯរកមកទៀតមក?"

អាឡេវតបថា៖ "អាចម៍មីខ្មៅ!"

ឮដូចនេះ លោកក៏ប្រាប់អាឡេវបំប៉នមីខ្មៅដោយឲ្យចំណីស៊ីឲ្យបានច្រើនដើម្បីឲ្យបានអាចម៍ច្រើនដែរៗ ហើយលោកក៏យកចានស្រាក់ទៅចងដាក់នៅពីក្រោមគូថឆ្កែ ដើម្បីឲ្យវាជុះអាចម៍ដាក់ៗ

ថ្ងៃមួយមានមិត្តភក្រលោកពីរបីអង្គមកលេង ហើយលោកមិនជាមានអីទទួល ក៏ឲ្យអាឡេវយកនំដែលនៅក្នុងចានស្រាក់ដែលស្រាយយកចេញពីគូថមីខ្មៅមកៗ ដល់ពេលលោកជជែកគ្នាបន្តិចទៅ លោកក៏ឆាន់ទឹកតែ ហើយក៏យកអាចម៍ឆ្កែមួយដុំមកឆាន់ ស្រាប់តែក្អួតនោះក្អួតព្រោះអីអាចម៍ឆ្កែស្អុយខ្លាំងណាស់ៗ លោកតាខឹងអាឡេវយ៉ាងខ្លាំង ព្រោះអីលោកអ្នកមានមុខមានមាត់មកលេងផង ដូច្នេះក៏ដេញវាយអាឡេវ ហើយបញ្ឈប់វាឲ្យនៅវត្តទៀតៗ

ពេលនោះអាឡេវក៏ទៅនៅជាមួយម៉ែឪវាវិញៗ និយាយចាប់ពីពេលវាទៅនៅជាមួយម៉ែឪវាវិញ នៅថ្ងៃមួយនោះវាចង់ស៊ីសម្លតាំងហ៊ុន វាមិនដឹងធ្វើយ៉ាងម៉េចៗ ចំណែកឯឪពុកវាទៅសង់ខ្ទមនៅឯស្រែដើម្បីចាំស្រែ ហើយម្ដាយវានៅចាំផ្ទះៗ ធ្លៀតពេលនោះ អាឡេវប្រាប់ម៉ែវាថា៖ "ម៉ែៗ ឪពុកស្លាប់ហើយ ដូច្នេះម៉ែត្រូវធ្វើបាយធ្វើសម្លទៅសែន ហើយស្លសម្លតាំងហ៊ុនផងៗ"

ចំណែកម៉ែអាឡេវឯណោះ មិនសួរនាំអីច្រើនទេ ក៏ធ្វើតាមអាឡេវប្រាប់ទៅ។ ពេលអាឡេវបាននំចំណីបាយសម្លស៊ីឆ្អែតហើយ វាក៏ធ្វើដំណើរទៅខ្ទមឪពុកវានៅឯស្រែ ហើយវាក៏ប្រាប់ឪវាថា៖ "ម៉ែងាប់ហើយៗ! ហើយឲ្យឪឯងធ្វើបាយសម្លសែនព្រេនម៉ែទៅ!"

អញ្ចឹងអាឡេវវាបានស៊ីឆ្ងាញ់រាល់ថ្ងៃអញ្ចឹងទៅ។ លុះបានស៊ីឆ្អែតឆ្អន់រួចហើយ។ វានឹកបបួលឪពុកវាឲ្យយកប្រពន្ធមួយទៀត។

ឪពុកនិយាយថា៖ "ទៅរកឯណាបាន បើឪចាស់ហើយ!"

អាឡេវតបថា៖ "អ្ហា... ឲ្យតែឪឯងថាយក ខ្ញុំរកឲ្យបាន!"

ហើយវាក៏ទៅបបួលម្ដាយវាទៀតថា៖ "ម៉ែឯងគួរយកប្ដីមួយទៀតទៅ ព្រោះខ្លួនជាស្រីនៅម្នាក់ឯងពិបាកណាស់!"

ម្ដាយតបថា៖ "អើ អញតាមតែឯងជួយគិតគូរទេកូន ធ្វើម៉េចស្រួលធ្វើទៅ ស្រេចលើកូនឯងហើយ!"

ឮដូច្នេះអាឡេវបានឱកាស ក៏ទៅប្រាប់ឪពុកវាថា៖ "ឪៗ! ខ្ញុំរកប្រពន្ធឲ្យឪបានហើយ ប៉ុន្តែគេឲ្យការពេលយប់!"

ដល់អញ្ចឹងទៅ ក៏ព្រមព្រៀងគ្នាធ្វើបាយធ្វើទឹកសែនព្រេនការនៅពេលយប់ទៅ។ ពេលយប់មកដល់ ក៏រៀបចំពិធីការហ្នឹងឡើង។ ហើយដល់ពេលសំពះផ្ទឹម ឪពុកវាថា៖ "ចុម ដូចម៉ែអាឡេវ!"

ម៉ែថា៖ "ចុម! ដូចឪអាឡេវ!"

ឆ្ងល់រៀងខ្លួន ក៏អុជចង្កៀងបំភ្លឺមើលទៅ ឃើញឪអាឡេវ ម៉ែអាឡេវមែនៗ ម៉ែឪលាន់មាត់ថា៖ "ឃើ

អាឡេវវាបញ្ឆោតយើងទេតើ!"

ពេលដឹងអញ្ចឹង ម៉ែហ្នឹងក៏ដេញវាយអាឡេវៗ ពេលនោះអាឡេវក៏រត់ទៅសុំលោកនៅវត្តទៀតៗ លោកក៏ព្រម ព្រោះយូរថ្ងៃហើយ លោកក៏បាត់ខឹងដែរៗ

ថ្ងៃមួយវាសួរលោកតាថា៖ "តេជគុណចង់បានស្រីទេ?"

លោកតបថា៖ "នែឯងកុំថាអញ្ចឹង អញជាអ្នកបួសត្រូវតែបោះបង់ស្រីញី ហើយឯងទៅនិយាយអីទៀត!"

ប៉ុន្តែតាមពិតទៅលោកចង់បានដែរនឹងណាស់ តែលោកធ្វើជាថាអញ្ចឹងទៅ ហើយម្យ៉ាងបើឯងយកមកឲ្យអញ រួចឯងដើរនិយាយប្រាប់គេអញឈប់ឲ្យបាយឯងស៊ីហើយ ៗ អាឡេវថា៖ "ទេ! ចាំករុណាជួយលាក់ឲ្យតែលោកតាឲ្យប្រាក់ខ្ញុំខ្លះមកៗ"

លោកតាថា៖ "ឯងយកប៉ុន្មាន?"

អាឡេវ៖ "យកលុយមួយបាទ[19]ៗ"

ដល់អញ្ចឹងទៅអាឡេវនឹងមិនដឹងជាទៅរកឯណា ក៏ទៅជួបនិងចិនប្រុសម្នាក់ៗ អាឡេវក៏សួរចិនចាស់នឹងថា៖ "ចង់បានស្រីទេ បើចង់បានខ្ញុំទៅរកស្រីមកឲ្យ?"

ចំណែកអាចិននោះវាចង់បានស្រីដែរ ក៏ប្រាប់ទៅអាឡេវៗ ពេលសន្មត់គ្នាហើយ ក៏ទៅប្រាប់លោកថា៖ "ស្រីរកបានហើយ គេឲ្យលោកទៅជួបនៅក្នុងព្រះវិហារៗ"

ដល់ម៉ោងប្រហែល ៧-៨យប់ អាឡេវវានាំស្រីហ្នឹងមកមែនៗ តាមពិតគឺនាំចិនហ្នឹងមកទេៗ ដោយយប់

19 ឈ្មោះប្រាក់បុរាណតម្លៃ៦០សេន៖ ប្រាក់បាទ, វចនានុក្រមខ្មែរ, ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

មើលមិនសូវច្បាស់ លោកមើលទៅស្មានថាចិនហ្នឹងជាស្រី ឯចិនស្មានថាលោកហ្នឹងជាស្រីដែរ ក៏ស្ទុះទៅចាប់ឱបប្រចបាច់គ្នា ប្រាកគ្នា។ ដោយសារតែលោកខ្សាយជាងចិនហ្នឹង លោកក៏ចាញ់ចិនដួលទៅ ពេលនោះចិនបើកមើលទៅឃើញមានប្រជាប់ដូចខ្លួន ដឹងថាប្រុសក៏ខ្មាស់គ្នា ចេញទៅបាត់ទៅ។

ចំណែកឯចិននោះក៏បានទៅរករឿងអាឡេវ រកយកលុយវិញ តែអាឡេវគម្រាមថានឹងដើរប្រាប់គេ ឯលោកតាវិញ ពេលដឹងថាចាញ់ប្រាកអាឡេវក៏រករឿងដេញវាយអាឡេវ តែអាឡេវថា ៖"ឲ្យតែហ៊ានវាយមក ខ្ញុំករុណាៗនឹងប្រាប់ប្តឹងគេ ប្តឹងថាលោកតាចង់ស្រីមែន។"

លោកតាចាញ់ប្រាកអាឡេវ ក៏រកលុយឲ្យអាឡេវមួយបាត្រលោកមែន គឺមិនមែនមួយបាត្រមួយកាក់ឯណា។ ដូច្នេះលោកក៏ខំប្រមូលលុយដាក់ពេញមួយបាត្រលោក យកទៅឲ្យអាឡេវទៅ។ ពេលវាបានលុយហើយ វាក៏ត្រឡប់មកផ្ទះវិញ។ មកតាមផ្លូវ វារើសបានខ្ទឹមច័ន្ទដែលគេយកទៅធ្វើទឹកអប់ទុក។

ពេលមកដល់ផ្ទះ ឪវាសួរថា៖ "របងឯងបានលុយពីណាមកហ្នឹង ហើយក្រអូបៗម្ល៉េះ?"

អាឡេវថា៖ "ខ្ញុំលក់ផោមឲ្យចិន បានលុយអញ្ចឹង។"

ឪវាសួរទៀតថា៖ "ធ្វើម៉េចឲ្យផោមឯងក្រអូបអញ្ចឹងអាឡេវ?"

អាឡេវថា៖ "គ្រាន់តែខំស៊ី ខំផឹក ស៊ីបបរ ស៊ីបង្អែមអីឲ្យណែនពោះទៅ ផោមវាក្រអូបហើយ!"

ឪពុកវាក៏ខំធ្វើតាមពាក្យអាឡេវ រកអីស៊ីឲ្យពេញពោះដើម្បីឲ្យបានផោមក្រអូប យកទុកលក់ឲ្យចិន។ ដល់ពេលគាត់បានស៊ីពេញពោះហើយក៏ឈឺផោម ក៏រត់ទៅផ្សារស្រែកប្រាប់គេថា៖ "ចង់ទិញផោមទេៗៗ??"

ចិនៗគិតថា៖ "យី! ផោមកូនក្រអូបប៉ុណ្ណឹងហើយ ចុះទំរាំផោមឪទៀត ក្រអូបប៉ុណ្ណាទៅ?"

ដូចនេះក៏នាំគ្នាទៅរោមទិញផោមៗ ពេលទិញអ្នកទិញត្រូវយកទូមកដាក់ផោមៗ ពេលបើកទូដាក់ផោមទៅ គាត់ដាក់គូថផ្អិបនឹងទូស្រាប់តែចេញមករូវៗៗ ព្រោះបានស៊ីបបរស្ពៃច្រើនផង។ វាមិនចេញផោមអី ចេញមកសុទ្ធតែអាចម៍ពេញទូ។ គេនាំគ្នាដេញវាយគ្រប់គ្នា។ ពេលគេដេញវាយអញ្ចឹង ឪអាឡេវរត់ទៅជួបអាឡេវក៏បន្ទោសអាឡេវថា៖ "ឯម៉េចបញ្ឆោតអញ ឲ្យគេដេញវាយអញអញ្ចឹង!!"

អាឡេវតប៖ "គេមានដេញវាយអ្នកលក់ផោមឯណា គេដេញវាយអ្នកបញ្ចេញក្ដក្រឡឹតឲ្យគេមើលទេតើ!"

ឪពុកហ្នឹងរត់បន្ដទៅទៀតៗ មានចាមពីរនាក់ស្ពាយសម្ពាយដើរមក ពេលឃើញមនុស្សរត់ដេញវាយឪអាឡេវក៏ចូលសួរអាឡេវថា៖ "គេរត់ធ្វើអី គេហ្នឹង?"

អាឡេវឆ្លើយ៖ "គេរត់ដេញប្រើសៗ"

ឮដូចនេះ ចាមក៏ផ្ញើសម្ពាយនឹងអាឡេវ រួចក៏រត់ទៅជួយដេញនឹងគេដែរ ព្រោះគិតថានឹងបានសាច់ប្រើសស៊ីដែរ។ រត់ទៅៗ ឪពុកអាឡេវដួល ឪពុកអាឡេវភ័យពេកក៏លើកដៃសំពះអង្វរថា៖ "កុំធ្វើបាបខ្ញុំអី ក្រឡិតតែបន្ដិចទេ!"

ព្រោះស្មានថាគេដេញតាមអ្នកលក់ក្ដក្រឡិតដូចអាឡេវថាមែន មានបានដឹងថាគេដេញចាប់ប្រើសឯណា។

ចំណែកឯអាឡេវឯណោះបានសម្ពាយរបស់ចាម ហើយក៏រត់វឹងទៅដល់កំពង់ទឹក ឃើញយាយម្នាក់កំពុងតែនាំចៅស្រីក្រមុំជិះទូកដើររកកាប់អុស ក៏សុំទូកយាយនឹងឆ្លងដែរ។ យាយក៏សួរថា៖ "ចៅឯងទៅណា

មកណា ហើយនៅឯណា ឈ្មោះអីដែរ?"

អាឡេវតប៖ "ខ្ញុំឈ្មោះអាជីថៅប្រសារ។"

ឆ្លើយហើយ អាឡេវនៅនឹងមាត់ច្រាំង ក៏ខំស្ទុះរត់ចុះទូកឲ្យបានមុនយាយព្រោះឃើញថៅស្រីយាយនោះចាំនៅលើទូកស្រាប់។ ដល់លើទូកហើយអាឡេវក៏ចាប់អុំទូកនាំថៅស្រីយាយទៅជាមួយ ទុកចោលយាយហ្នឹងនៅនឹងមាត់ច្រាំងតែម្នាក់ឯង។ ចំណែកឯយាយច្រាំងនេះ ឃើញដូចនេះក៏ស្រែប្រាប់អ្នកស្រុកថា៖ "អ្នកស្រុកអើយ! ជួយខ្ញុំផង អាជីថៅប្រសារយកថៅខ្ញុំទៅហើយៗ!"

រួចចុះមាននរណាគេទៅជួយ បើគាត់ស្រែកថាអាជីថៅប្រសារគាត់ទៅហើយ។ ដល់អញ្ចឹងទៅថៅហ្នឹងក៏បានជាប្រពន្ធអាឡេវទៅ៕

# បញ្ជីឈ្មោះប្រជាជនដែលបានផ្តល់បទសម្ភាសន៍

| | |
|---|---|
| **លោក អ៊ឹម ឈាង** | *នៅភូមិសំរោងស្នោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង* |
| **លោក អ៊ឹម ឌឿន** | *នៅភូមិថ្មី ឃុំរការគយ ស្រុកកងមាស ខេត្តកំពង់ចាម* |
| **លោក តាអិន អៀន** | *នៅភូមិសំបូរមាស២ ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម* |
| **លោកតា ប៉ែន អយ** | *នៅភូមិត្រពាំង ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ* |
| **លោក ជា ជឿន** | *នៅភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម* |
| **លោកអាចារ្យ  អឿង** | *នៅភូមិទន្លេបាទី ឃុំក្រាំងធ្នង ស្រុកបាទី ឃុំក្រាំងធ្នុង* |
| **ស្រីលក្ខណ៍** | *នៅភូមិហនុមាណខាងត្បូង ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ* |
| **លោក កែវ សុខា ហៅ ម៉ៃ** | *នៅភូមិហនុមាណខាងត្បូង ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ* |
| **លោកតាសៅ  វល្លី** | *អាយុ ៨២ ឆ្នាំ នៅភូមិវត្តពោធិ៍ ឃុំវាំងចាស់ ស្រុកឧដុង្គ  ខេត្តកំពង់ស្ពឺ* |
| **លោកតា ស៊ុំ សារុំ** | *នៅភូមិព្រះម្លប់ ឃុំកណ្ដឹង ស្រុកបាទី  ខេត្តតាកែវ* |
| **អាចារ្យ ប៉ែន ផាន** | *នៅភូមិពពែភ្នំ ឃុំស្វាយក្រវ៉ាន់ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ* |

| | |
|---|---|
| **លោកតាព្រាប ស្រស់** | *នៅភូមិក្រាំងធ្នុង ឃុំក្រាំងធ្នុង ស្រុកបាទី ខេត្តតាកែវ* |
| **កុមារ ពេជ្រ ភន** | *នៅវត្តហង្សរាបិតិព្រៃកស្ដី ភូមិព្រៃកស្ដី ឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិសាត់* |
| **លោក នូ សុងហួន** | *នៅភូមិព្រៃជា ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ* |
| **លោក រួញ ឡេង** | *នៅភូមិពត់សរ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ* |
| **លោកតា ប៊ុន ប៉ា** | *នៅភូមិថ្មី ឃុំរកាគយ ស្រុកកងមាស ខេត្តកំពង់ចាម* |
| **លោក គឹម ងួនជា** | *នៅភូមិសំរោងស្ពោ ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង* |
| **លោកតាស៊ូ ឡាង** | *នៅភូមិអន្លង់ញជី ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម* |